ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ.................

CAMBODIA
Kingdom of Wonder
feel the warmth

ថ្ងៃ.................ខែ.................ឆ្នាំ.................ស័ក ព.ស. ២៥.........

រាជធានីភ្នំពេញ, ថ្ងៃទី.................ខែ.................ឆ្នាំ២០.........

# របៀបវារៈ

## សន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងទេសចរណ៍

ថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០២៥

នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍អន្តរជាតិ ជ្រោយចង្វា (OCIC)

| ម៉ោង | របៀបវារៈ |
|---|---|
| **ថ្ងៃទី១៖ ថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥** | |
| **ពិធីបើក សន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍** | |
| *ពេលព្រឹក* | |
| ០៨:០០-០៨:៣០ | ចុះឈ្មោះអ្នកចូលរួម |
| | ការអញ្ជើញដល់របស់ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងគណៈអធិបតី |
| ០៨:៣០-០៨:៣៥ | គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា |
| ០៨:៣៥-០៨:៥៥ | សុន្ទរកថាបើកសន្និបាតរបស់ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ |
| ០៨:៥៥-០៩:២៥ | របាយការណ៍សង្ខេបស្តីពី លទ្ធផលការងារ ឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ (ដោយឯកឧត្តម ទិត ចន្ថា រដ្ឋលេខាធិការប្រចាំក្រសួងទេសចរណ៍) |
| ០៩:២៥-០៩:៤០ | ការចូលរួមរបស់ផ្នែកឯកជនក្នុងវិស័យទេសចរណ៍ (ដោយឧកញ៉ា លូ ម៉េង សហប្រធានក្រុមការងារផ្នែកទេសចរណ៍ឯកជន) |
| ០៩:៤០-១០:១០ | ថតរូបអនុស្សាវរីយ៍ |
| | សម្រាកអាហារសម្រន់ |
| *វគ្គទី១*: វឌ្ឍនភាពនៃការគ្រប់គ្រង និងការសម្រួលការធ្វើដំណើរទេសចរណ៍ | |
| ១០:១០-១០:២៥ | បទបង្ហាញស្តីពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងដំណោះស្រាយនៃការសម្រួលការធ្វើដំណើរចូលមកកម្ពុជា (ដោយតំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍) |
| ១០:២៥-១០:៤០ | បទបង្ហាញស្តីពីយុទ្ធសាស្ត្រជំរុញជើងហោះហើរជាតិ-អន្តរជាតិ (ដោយតំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល) |
| ១០:៤០-១១:៥៥ | កម្មវិធីសំណួរ-ចម្លើយ |
| | សម្រាកអាហារថ្ងៃត្រង់ |

| | |
|---|---|
| *ពេលរសៀល* | |
| វគ្គទី២: ការគ្រប់គ្រងកិត្តិនាមកម្ពុជា និងយុទ្ធនាការទាក់ទាញទេសចរណ៍កម្ពុជា | |
| ១៤:០០-១៤:១៥ | បទបង្ហាញស្តីពីវឌ្ឍនភាពផែនការនិងសកម្មភាពទាក់ទាញទេសចរណ៍របស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ដោយលោក អ៊ិត វិជិត នាយកប្រតិបត្តិក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា) |
| ១៤:១៥-១៤:៣០ | បទបង្ហាញស្តីពីការគាំទ្ររបស់វិស័យឯកជនក្នុងការពង្រឹង និងពង្រីកកិត្តិនាមកម្ពុជា (ដោយលោក ឱន សុមេធារិទ្ធ ប្រធានសហព័ន្ធទេសចរណ៍កម្ពុជា) |
| ១៤:៣០-១៥:០០ | កម្មវិធីសំណួរ-ចម្លើយ |
| | សម្រាកអាហារសម្រន់ |
| វគ្គទី៣: ការគ្រប់គ្រង និងការពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍ | |
| ១៥:១៥-១៥:៣០ | បទបង្ហាញស្តីពីការគ្រប់គ្រង និងពង្រឹងគុណភាពអាជីវកម្ម-សេវាកម្មទេសចរណ៍ (ដោយឯកឧត្តម ឈុន មករា ប្រធានទទួលបន្ទុករួមអគ្គនាយកដ្ឋាន ឧស្សាហកម្មទេសចរណ៍) |
| ១៥:៣០-១៥:៤៥ | បទបង្ហាញស្តីពីការបណ្តុះបណ្តាល<br>និងយុទ្ធសាស្រ្តអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍<br>(ដោយឯកឧត្តម ឆាយ យុនឡុង នាយកសាលាវិជ្ជាជីវៈទេសចរណ៍) |
| ១៥:៤៥-១៦:១៥ | កម្មវិធីសំណួរ-ចម្លើយ |
| ១៦:១៥-១៩:០០ | - ពិធីបំពាក់មេដាយ និងគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការក្រសួងទេសចរណ៍<br>- ពិធីចែកបណ្ណសរសើរដល់អង្គភាពចំណុះក្រសួងទេសចរណ៍<br>- ពិធីចែកបណ្ណសរសើរជូនអ្នកមានឥទ្ធិពលលើបណ្តាញសង្គម (Influencers) |
| ថ្ងៃទី២៖ ថ្ងៃព្រហស្បតិ៍ ០១កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៥ | |
| *ពេលព្រឹក* | |
| ០៨:០០-០៨:៣០ | ចុះឈ្មោះអ្នកចូលរួម |
| | ការអញ្ជើញដល់របស់**ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងគណៈអធិបតី |
| ០៨:៣០-០៨:៣៥ | មតិដឹកនាំរបស់**ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ |
| វគ្គទី៤: ស្ថានភាពទេសចរតាមកញ្ចប់ទស្សនកិច្ច និងការវិភាគផលសេដ្ឋកិច្ចនៃវិស័យទេសចរណ៍ | |
| ០៨:៣៥-០៨:៥០ | បទបង្ហាញស្តីពីស្ថានភាពទេសចរតាមកញ្ចប់ទស្សនកិច្ចទេសចរណ៍ និងការព្យាករឆ្នាំ២០២៥ (ដោយលោកជំទាវ ឆាយ ស៊ីវលីន ប្រធានសមាគមទេសចរណ៍កម្ពុជា) |
| ០៨:៥០-០៩:០៥ | បទបង្ហាញស្តីពីខ្សែច្រវាក់តម្លៃ និងតម្លៃបន្ថែមនៃអាជីវកម្មទេសចរណ៍ (ដោយលោក ធួន ស៊ីណាន ប្រធានសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា) |

| | |
|---|---|
| ០៩:០៥-០៩:៣០ | កម្មវិធីសំណួរ-ចម្លើយ |
| | សម្រាកអាហារសម្រន់ |

**ពិធីបិទ**
**សន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥**
**ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត**
**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

*ពេលរសៀល*

| | |
|---|---|
| ១៣:៣០ | ការអញ្ជើញដល់របស់ភ្ញៀវកិត្តិយស និងគណៈអធិបតី |
| ១៤:៣០ | - ការអញ្ជើញដល់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា<br>- របាយការណ៍លទ្ធផលសន្និបាត ដោយ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួង ទេសចរណ៍<br>- សន្ទរកថាបិទសន្និបាត **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា<br>- ពិធីបំពាក់គ្រឿងឥស្សរិយយសជូនថ្នាក់ដឹកនាំក្រសួងទេសចរណ៍<br>- គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>- ដំណើរនិវត្តន៍របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា |

***កម្មវិធីនេះរក្សាសិទ្ធិកែប្រែ ក្នុងករណីចាំបាច់។*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សន្និបាត
# បូកសរុបលទ្ធផលការងារ
# ឆ្នាំ២០២៤
# និងលើកទិសដៅការងារឆ្នាំ២០២៥
# របស់ក្រសួងទេសចរណ៍

"ទេសចរណ៍ដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីទេសចរណ៍ "

"ម្នាក់ៗ ជាអ្នកផ្សព្វផ្សាយទេសចរណ៍កម្ពុជា ម្នាក់!"

ថ្ងៃទី២៦ - ២៧ ខែកុម្ភៈ ឆ្នាំ២០២៥

សេចក្តីព្រាង

# មាតិកា

ទំព័រ


I. **សេចក្តីផ្តើម**............................................................................................១
II. **សភាពការណ៍ទេសចរណ៍**.............................................................................៣
១. សភាពការណ៍ទេសចរណ៍សកល និងតំបន់ .....................................................៣
២. សភាពការណ៍ទេសចរណ៍កម្ពុជា ..................................................................៣
៣. ចក្ខុវិស័យទេសចរណ៍កម្ពុជា .....................................................................៤
III. **លទ្ធផលការងារទេសចរណ៍ ឆ្នាំ២០២៤**..........................................................៥
១. ការអភិវឌ្ឍទេសចរណ៍ ការវិនិយោគ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍និងយុទ្ធនាការទាក់ទាញទេសចរ ..........................................................................................៥
១.១. ការអភិវឌ្ឍទេសចរណ៍ និងការវិនិយោគ.....................................................៥
ក. ការងារអភិវឌ្ឍផលិតផលទេសចរណ៍.......................................................៥
ខ. ការងារផែនការអភិវឌ្ឍទេសចរណ៍..........................................................៥
គ. ការងារផែនការទេសចរណ៍មូស្លីម...........................................................៦
ឃ. ការងារវិនិយោគទេសចរណ៍...................................................................៧
ង. ការងារបរិវត្តកម្មឌីជីថល.......................................................................៨
១.២. ការពង្រឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ ................................................ ១១
ក. កិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខណ្ឌអាស៊ាន ................................ ១១
ខ. កិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខណ្ឌអនុតំបន់...............................១២
គ. កិច្ចសហប្រតិបត្តិការទេសចរណ៍កម្ពុជា-ចិន...............................................១៣
ឃ. កិច្ចសហប្រតិបត្តិការទេសចរណ៍តំបន់អាស៊ីប៉ូឞ៉ា.........................................១៤
ង. កិច្ចសហប្រតិបត្តិការទេសចរណ៍តំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក.......................១៤
១.៣. ការជំរុញសកម្មភាពសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ............................ ១៤
២.ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងការពង្រឹងគុណភាពអាជីវកម្ម សេវាកម្មទេសចរណ៍ .....១៨
២.១. ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ...................................................... ១៨
២.២. ការពង្រឹងគុណភាពអាជីវកម្ម និងសេវាកម្មទេសចរណ៍ ................................. ១៨
២.៣. ការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍................. ១៩
៣.ការពង្រឹងយន្តការអភិបាលកិច្ចទេសចរណ៍.........................................................២២
៣.១. ការពង្រឹងការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងទេសចរណ៍ ....................................២២
ក. ការងាររដ្ឋបាល និងកិច្ចការទូទៅ ..........................................................២២
ខ. ការងារគ្រប់គ្រងធនធានមនុស្ស .............................................................២៣
គ. ការងារសន្តិសុខ និងសុវត្ថិភាពទេសចរ .....................................................២៤
ឃ. ការងារគណនេយ្យ និងហិរញ្ញវត្ថុ ..........................................................២៤
ង. ការងារលទ្ធកម្ម..................................................................................២៥
៣.២. ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងទេសចរណ៍...................២៥

៣.៣. ការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងទេសចរណ៍ ..... ២៦
៣.៤. ការពង្រឹងយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ..... ២៧
ក. ការងារនីតិកម្ម ..... ២៧
ខ. អធិការកិច្ច ..... ២៩
គ. ការងារសវនកម្មផ្ទៃក្នុង ..... ២៩
៤.យន្តការគាំទ្រវិស័យទេសចរណ៍ ..... ៣០
៤.១. គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ..... ៣០
៤.២. គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ..... ៣០
៤.៣. ការសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរតាមច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិ ..... ៣២
៤.៤. គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ..... ៣២
៤.៥. ការងារវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យទេសចរណ៍ ..... ៣៤
៤.៦. ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងវិស័យទេសចរណ៍ និងបរិស្ថានគ្មានផ្សែងបារី ..... ៣៤
៤.៧. ការងារសុវត្ថិភាពកុមារ ជំងឺអេដស៍ និងសកម្មភាពជនមានពិការភាព ..... ៣៦
៤.៨. ការងារនារី និងយេនឌ័រក្នុងវិស័យទេសចរណ៍ ..... ៣៦
៤.៩. ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងវិស័យទេសចរណ៍ ..... ៣៨
៤.១០. ការងារគ្រឹះស្ថានអង្គរ ..... ៣៩
ក. ប្រតិបត្តិការប្រមូលចំណូលពីការលក់បណ្ណ ឆ្នាំ២០២៤ ..... ៣៩
ខ. ប្រតិបត្តិការចំណាយឆ្នាំ២០២៤ ..... ៣៩
គ. ការកែទម្រង់ប្រព័ន្ធលក់សំបុត្រ ..... ៣៩
៤.១១.ការងារសាលាវិជ្ជាជីវៈទេសចរណ៍ ..... ៤០
IV. **ការវិភាគទេសចរណ៍ និន្នាការ ឧស្សុនវិស័យ និងគោលនយោបាយទេសចរណ៍** ..... ៤១
V. **បញ្ហាប្រឈមគន្លឹះត្រូវសិក្សាដោះស្រាយ** ..... ៤៣
VI. **ទិសដៅការងារឆ្នាំ២០២៥** ..... ៤៤
១.ការអភិវឌ្ឍទេសចរណ៍ ការវិនិយោគ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ និងយុទ្ធនាការទាក់ទាញទេសចរ ..... ៤៤
២.ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងការពង្រឹងគុណភាពអាជីវកម្ម សេវាកម្មទេសចរណ៍ ..... ៤៩
៣.ការអភិវឌ្ឍធនធានមនុស្ស ការងារស្ថិតិទេសចរណ៍ និងគោលនយោបាយ ..... ៤៩
៤.ការគ្រប់គ្រង និងសម្រួលការធ្វើដំណើរទេសចរណ៍ ..... ៥០
៥.ការពង្រឹងយន្តការអភិបាលកិច្ចទេសចរណ៍ ..... ៥០
៦.យន្តការគាំទ្រវិស័យទេសចរណ៍ ..... ៥១
៧.ការងារវិជ្ជាជីវៈទេសចរណ៍ ..... ៥១
VII. **សេចក្តីសន្និដ្ឋាន** ..... ៥២
VIII. **ឧបសម្ព័ន្ធ**

## I. សេចក្តីផ្តើម

រយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ គឺក្រោយពេលដែលមាតុភូមិកម្ពុជាទទួលបាននូវសុខសន្តិភាពពេញលេញតាមរយៈនយោបាយបង្រួបបង្រួមជាតិ *"ឈ្នះ ឈ្នះ"* ជាប្រវត្តិសាស្ត្រ នាថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងកិច្ចអភិវឌ្ឍប្រទេសជាតិ ដោយការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក ព្រមជាមួយនឹងការប្តេជ្ញារក្សាឱ្យបាននូវស្ថិរភាពជាតិ សុខសន្តិភាព សុវត្ថិភាព ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម លើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ពិសេសគឺគោលបំណងដ៏ធំធេងឥតងាករេក្នុងការជំរុញ និងប្រែក្លាយកម្ពុជា ជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។

ឆ្នាំ២០២៤ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាព ដោយសេដ្ឋកិច្ចកម្ពុជាងើបឡើងក្នុងអត្រាកំណើន ៦% ធៀបនឹង ៥% ក្នុងឆ្នាំ២០២៣ ដោយសារការត្រឡប់ទៅរកភាពល្អប្រសើរឡើងវិញនៃសេដ្ឋកិច្ចសកល ជាពិសេសប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ស្របពេលដែលសេដ្ឋកិច្ចក្នុងស្រុកនៅបន្តរក្សាស្ថិរភាព និងនិន្នាការល្អ។

វិស័យទេសចរណ៍កម្ពុជា ជាវិស័យអាទិភាពដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រសិទ្ធនាមថាជា **"មាសបៃតង"** ដែលចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការបង្កើតឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់ និងដោយប្រយោល ជំរុញការនាំចេញនៅនឹងកន្លែង ទាក់ទាញការវិនិយោគ បង្កើនចំណូលជាតិ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ចូលរួមកាត់បន្ថយភាពក្រីក្រ ផ្តល់អំណាចដល់សហគមន៍ និងគាំទ្រដល់ការអភិរក្សធនធានវប្បធម៌ ធម្មជាតិ និងបរិស្ថាន ជាពិសេសចូលរួមចំណែកក្នុងការកសាងកម្ពុជាឱ្យមានភាពប្រកួតប្រជែងខ្ពស់ និរន្តរភាព និងបរិយាបន្ន។

រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងគ្រប់ជ្រុងជ្រោយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្របន្តពីយុទ្ធសាស្ត្រត្រីកោណ និងចតុកោណទាំងបួនដំណាក់កាលនោះគឺ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ "ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព"** ដែលមានការកែទម្រង់ និងការពង្រឹងអភិបាលកិច្ចជាស្នូល និងមានអាទិភាពគន្លឹះ៥ គឺ **"មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា"**។

ស្ថិតក្នុងអភិក្រមនៃសសរស្តម្ភទាំងប្រាំនេះ រាជរដ្ឋាភិបាលនៅតែបន្តចាត់ទុកវិស័យទេសចរណ៍ជា **"មាសបៃតង"** និងជាវិស័យអាទិភាពសេដ្ឋកិច្ចមួយដ៏សំខាន់។ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានយកចិត្តទុកដាក់ខ្ពស់លើការធានាចីរភាពកំណើននៃវិស័យជាសារវន្តនេះ។ ជាក់ស្តែង នាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ កន្លងទៅ រាជរដ្ឋាភិបាលបានសម្រេចជាប្រវត្តិសាស្ត្រក្នុងការបើកការដ្ឋានសាងសង់ **"ព្រែកជីកហ្វូណន តេជោ"** ជាផ្លូវការ ដែលនេះជាសមិទ្ធផលថ្មីជាប្រវត្តិសាស្ត្រសម្រាប់ជាតិ ក្នុងនោះរួមមានវិស័យទេសចរណ៍ ព្រមទាំងគោលដៅពហុទេសចរណ៍ថ្មីៗ

ដែលនឹងផុសលេចត្រដែតឡើង អមតាមមាត់ព្រែកជីកហ្វូណនតេជោនាអនាគតដ៏ខ្លីខាងមុខ។ បន្ថែមទៀតនោះ សមិទ្ធផលថ្មីៗសំខាន់ជាច្រើនទៀតបានលេចចេញរូបរាងជាបន្តបន្ទាប់ សម្រាប់បម្រើឱ្យវិស័យទេសចរណ៍ រួមមានអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ លំដាប់4E អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ដែលទើបតែធ្វើបច្ចុប្បន្នភាពឱ្យត្រូវស្តង់ដាអន្តរជាតិដែលមានផ្លូវរត់ហូតដល់ ៣ ៣០០ ម៉ែត្រ និងជាពិសេស អាកាសយានដ្ឋានអន្តរជាតិតេជោ លំដាប់4F ដែលអាចឱ្យគ្រប់ប្រភេទយន្តហោះទាំងអស់ចុះចតបាន នឹងត្រូវបើកឱ្យដំណើរការក្នុងដំណាក់កាលទី១ ក្នុងឆ្នាំ២០២៥ នេះ។

ទន្ទឹមនោះ រាជរដ្ឋាភិបាល ក៏ដូចជាបណ្តាក្រសួង ស្ថាប័ននានា ពិសេស ក្រសួងទេសចរណ៍ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានបន្តដាក់ចេញនូវវិធានការគន្លឹះ យុទ្ធនាការ និងការរៀបចំព្រឹត្តិការណ៍ជាច្រើនដែលជួយជំរុញ គាំទ្រដល់វិស័យទេសចរណ៍ ដូចជា យុទ្ធនាការ **"ឆ្នាំទស្សនាសៀមរាប ២០២៤" "ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន"** និង **"ឆ្នាំទេសចរណ៍ កម្ពុជា-ឥណ្ឌា លើកទី១ ឆ្នាំ២០២៤"** ការជំរុញផ្សព្វផ្សាយសក្តានុពលគោលដៅទេសចរណ៍កម្ពុជា តាមរយៈការចូលរួមពិព័រណ៍ ព្រឹត្តិការណ៍ វេទិកាទេសចរណ៍ទាំងក្នុងនិងក្រៅប្រទេស ជួបធ្វើសវនាការ ប្រជុំពិភាក្សាជាមួយបណ្តាអង្គទូត ស្ថានទូត អង្គការដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុន ផ្នែកឯកជន ជំរុញការឃោសនាផ្សព្វផ្សាយទេសចរណ៍គ្រប់រូបភាព តាមបណ្តាញសង្គម ប្រព័ន្ធឌីជីថល ជំរុញការធ្វើពិពិធកម្មផលិតផលទេសចរណ៍ ប្រកបដោយគុណភាព ស្តង់ដា យុទ្ធនាការចុះពង្រឹងគុណភាពមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ជាដើម។ល។

ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងទាំងនេះ និងឈរនៅលើមូលដ្ឋាននៃទិសស្លោក **"រួមគិត រួមធ្វើ រួមទទួលខុសត្រូវ"** ប្រកបដោយស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្ម ពិសេសក្រោមការយកចិត្តទុកដាក់ដោយផ្ទាល់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** វិស័យទេសចរណ៍កម្ពុជា បានវិលត្រឡប់មកដល់ឆ្នាំកំពូលវិញ (មុនការគ្រោងទុក) គឺឆ្នាំ២០១៩ (មុនវិបត្តិកូវីដ-១៩) ដែលយើងទទួលបានទេសចរអន្តរជាតិប្រមាណ ៦,៦លាននាក់ ហើយក្នុង ឆ្នាំ២០២៤ ចំនួនទេសចរអន្តរជាតិដែលបានមកទស្សនាព្រះរាជាណាចក្រកម្ពុជាមានរហូតដល់ទៅ ៦,៧ លាននាក់ ជាមួយនឹងទេសចរក្នុងស្រុកប្រមាណ ២២,៥ លាននាក់បន្ថែមទៀត។

ក្រសួងទេសចរណ៍ក្រោមការដឹកនាំរបស់ **ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍** បានបន្តជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ តាមរយៈការបន្តអនុវត្តនូវផែនការមេអភិវឌ្ឍទេសចរណ៍សៀមរាប ឆ្នាំ២០២១-២០៣៥ ផែនការមេអភិវឌ្ឍទេសចរណ៍មណ្ឌលគិរី ឆ្នាំ២០២២-២០៣៥ ផែនការអភិវឌ្ឍទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥ និងបន្តសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធតាមរយៈយន្តការគណៈកម្មការនានារួមមាន (១) គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា (២) គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា (៣) គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍន៍អេកូទេសចរណ៍ (៤) គណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរនិងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស។ នៅថ្នាក់ក្រោមជាតិ ក្រសួងទេសចរណ៍ក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត ដែលដើរតួនាទីជាអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (DMOs) ដោយបានសហការរៀបចំផែនការអភិវឌ្ឍទេសចរណ៍រាជធានីខេត្ត និងបានតាមដានត្រួតពិនិត្យ និងវាយតម្លៃជាទៀងទាត់។ លើសពីនេះទៅទៀត ក្រសួងទេសចរណ៍

បានរៀបចំសិក្សា និងបន្តការដាក់ចេញបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍទេសចរណ៍ ដូចជា៖ គោលនយោបាយស្តីពីទេសចរណ៍ពិសិដ្ឋ ផែនការអភិវឌ្ឍទេសចរណ៍មូស្លីមឆ្នាំ២០២៣-២០២៧ ស្របតាមគោលនយោបាយ និងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រក្រោមទិសស្លោក "**ទេសចរណ៍ដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីទេសចរណ៍**" និង "**ម្នាក់ៗជាអ្នកផ្សព្វផ្សាយទេសចរណ៍កម្ពុជាម្នាក់!**" សំដៅជំរុញកំណើនទេសចរណ៍ប្រកបដោយចីរភាព បរិយាបន្ន និងការប្រកួតប្រជែង ដើម្បីបង្កើតនិងបង្កើនឱកាសការងារ ជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។

## II. សភាពការណ៍ទេសចរណ៍

### ១. សភាពការណ៍ទេសចរណ៍សកល និងតំបន់

យោងតាមរបាយការណ៍អង្គការសហប្រជាជាតិទេសចរណ៍ (UN Tourism) ឆ្នាំ២០២៤ មានទេសចរអន្តរជាតិបានធ្វើដំណើរកម្សាន្តជុំវិញពិភពលោកសរុប **១ ៤៤៥** លាននាក់ កើនឡើង ១០,៧% ធៀបនឹងឆ្នាំ២០២៣ ដែលស្មើនឹង ៩៨,៦% ជិតស្មើកាលគ្រាមុនជំងឺកូវីដ-១៩ ឆ្នាំ២០១៩។ ក្នុងនោះ ទ្វីបអឺរ៉ុបទទួលបានទេសចរអន្តរជាតិ ៧៤៧,៣ លាននាក់ កើនឡើង ៥,៥% ទ្វីបអាស៊ីនិងប៉ាស៊ីហ្វិក ទទួលបាន ៣១៥,៩ លាននាក់ កើនឡើង ៣២,៩% ទ្វីបអាម៉េរិកទទួលបាន ២១៣,៥ លាននាក់ កើនឡើង ៦,៧% ទ្វីបអាហ្វ្រិកទទួលបាន ៧៣,៦ លាននាក់ កើនឡើង ១២,២% និងមជ្ឈិមបូព៌ាទទួលបាន ៩៤,៨ លាននាក់ កើនឡើង ១,៤% ជាមួយនឹងចំណូលទេសចរណ៍អន្តរជាតិប្រមាណ ១ ៥៩០ ពាន់លានដុល្លារ។ តាមការព្យាករ និងវាយតម្លៃរបស់អង្គការ UN Tourism វិស័យទេសចរណ៍ឆ្នាំ២០២៥ នេះនឹងមានអត្រាកំណើនល្អ ហើយនឹងលើសកាលគ្រាមុនវិបត្តិជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២៥ នេះនឹងមានអត្រាកំណើនចន្លោះពី ៣% ទៅ ៥% ធៀបនឹងឆ្នាំ២០២៤។

ដោយឡែកតំបន់អាស៊ានឆ្នាំ២០២៤ ទទួលបានទេសចរអន្តរជាតិសរុប ១២១,៧ លាននាក់ កើនឡើង ២៣,០% ធៀបឆ្នាំ២០២៣ និងឆ្នាំ២០២៥នេះ អង្គការសហប្រជាជាតិទេសចរណ៍ បានវាយតម្លៃថា ទេសចរអន្តរជាតិនឹងធ្វើដំណើរកម្សាន្តក្នុងអត្រាកំណើនចន្លោះពី ១០% ទៅ១៥% ធៀបនឹងកម្រិតមុនគ្រាមានវិបត្តិ ហើយស្ថិតិនេះអាចនឹងប្រែប្រួល អាស្រ័យលើស្ថានភាពសេដ្ឋកិច្ច សន្ទុះងើបឡើងវិញនៃការធ្វើដំណើររបស់បណ្តាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ការវិវត្តនៃវិបត្តិសង្គ្រាមរវាងអ៊ុយក្រែន-រុស្ស៊ី និងកត្តាផ្សេងៗទៀត។ តែបើទោះជាយ៉ាងណាក៏ដោយ ក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិទេសចរណ៍បានវាយតម្លៃទៀតថា តំបន់អាស៊ានមានកំណើនទេសចរណ៍ល្អជាងតំបន់ផ្សេងៗទៀត ហើយនឹងវិលមករកស្ថានភាពដូចកាលគ្រាមុនមានជំងឺកូវីដ-១៩ លឿនជាងសេណារីយ៉ូព្យាករណ៍១ឆ្នាំ។

### ២. សភាពការណ៍ទេសចរណ៍កម្ពុជា

**ក.** ឆ្នាំ២០២៤ កម្ពុជាទទួលបានទេសចរអន្តរជាតិសរុប **៦,៧០** លាននាក់ (៦ ៧០០ ១២៥ នាក់) កើនឡើង ២២,៩% ធៀបឆ្នាំ២០២៣ កើនឡើង ១,៤% ធៀបឆ្នាំ២០១៩។ ក្នុងនោះ មធ្យោបាយធ្វើដំណើរ៖

- ផ្លូវអាកាស ២ ៣៩៦ ៩៣៧ នាក់ កើនឡើង ២៨,៤% ស្មើនឹង ៣៥,៨% នៃចំនួនសរុប
- ផ្លូវគោក ៤ ២១៨ ៨១១ នាក់ កើនឡើង ១៩,៨% ស្មើនឹង ៦៣,០% នៃចំនួនសរុប
- ផ្លូវទឹក ៨៤ ៣៧៧ នាក់ កើនឡើង ២៧,៣% ស្មើនឹង ១,៣% នៃចំនួនសរុប

ប្រភពទីផ្សារទេសចរណ៍សំខាន់ៗ៖ ទ្វីបអាស៊ីប៉ាស៊ីហ្វិក ៥ ៧២៩ ៨៧១ នាក់ កើនឡើង ២៣,៨% ស្មើនឹង ៨៥,៥% នៃចំនួនសរុប ក្នុងនោះ អាស៊ាន ៤ ២៣៥ ៦៣១ នាក់ កើនឡើង ១៩,៣% ស្មើនឹង ៦៣,២% នៃចំនួនសរុប ទ្វីបអឺរ៉ុប ៦៦៣ ៣៥៩ នាក់ កើនឡើង ១៧,៩% ស្មើនឹង ៩,៩% នៃចំនួនសរុប ទ្វីបអាម៉េរិក ២៨៩ ៦៣៥ នាក់ កើនឡើង ១៦,៦% ស្មើនឹង ៤,៣% នៃចំនួនសរុប ទ្វីបអាហ្វ្រិក ១៣ ៧១៥ នាក់ កើនឡើង ២៣,៧% ស្មើនឹង ០,២% នៃចំនួនសរុប និងមជ្ឈឹមបូព៌ា ៣ ៥៤៥ នាក់ កើនឡើង ១៦,៣% ស្មើនឹង ០,១% នៃចំនួនសរុប។

- ទេសចរផ្ទៃក្នុង៖ (១)ទេសចរជាតិ ប្រមាណ ២២,៥២ លាននាក់ (២២ ៥១៩ ៧៨៨ នាក់) កើនឡើង ២០,១% ធៀបឆ្នាំ២០២៣ (៩៨,៩% ធៀបឆ្នាំ២០១៩) និង(២)ទេសចរបរទេស ប្រមាណ ៣,៩៩ លាននាក់ (៣ ៩៨៦ ០៥៥ នាក់) កើនឡើង ៥៤,៣% ធៀបឆ្នាំ២០២៣
- ទេសចរជាតិចេញក្រៅ ចំនួន ១,៨៥ លាននាក់ (១ ៨៤៥ ៤៦២ នាក់) កើនឡើង ១,៤% ធៀបនឹងឆ្នាំ២០២៣
- ទីផ្សារទេសចរណ៍សំខាន់ៗទាំងដប់ របស់កម្ពុជារួមមាន៖ (១) ទេសចរថៃ ២ ១៤៦ ៦៧៤ នាក់ ស្មើនឹង ៣២,០% នៃចំនួនសរុប (២) ទេសចរវៀតណាម ១ ៣៤០ ៥៨៧ នាក់ ស្មើនឹង ២០,០% (៣) ទេសចរចិន ៨៤៨ ៩៥២ នាក់ ស្មើនឹង ១២,៧% (៤) ទេសចរឡាវ ៣៣៤ ៤៤៨ នាក់ ស្មើនឹង ៥,០% (៥) ទេសចរអាម៉េរិក ២១៤ ៥២៩ នាក់ ស្មើនឹង ៣,២% (៦) ទេសចរកូរ៉េ ១៩២ ៣០៥ នាក់ ស្មើនឹង ២,៩% (៧) ទេសចរឥណ្ឌូនេស៊ី ១៦៦ ៧៩៥ នាក់ ស្មើនឹង ២,៥% (៨) ទេសចរបារាំង ១៣១ ៧៣៨ នាក់ ស្មើនឹង ២,០% (៩) ទេសចរអង់គ្លេស ១១៥ ១៤៨ នាក់ ស្មើនឹង ១,៧% និង(១០) ទេសចរជប៉ុន ១១២ ៧១៨ នាក់ ស្មើនឹង ១,៧%។

**ខ.** បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ប្រាសាទកោះកេរ និងកំពង់ផែចុងឃ្នៀស៖

- ទេសចរទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរសរុប ១ ០២៣ ៦៨៨ នាក់ កើនឡើង ២៨,២៧% និងទទួលបានចំណូលសរុប **៤៧ ៨២៦ ៩៨១** ដុល្លារអាម៉េរិក កើនឡើង ២៨,៥៧% ធៀបនឹងឆ្នាំ២០២៣
- ទេសចរទិញបណ្ណចូលទស្សនាប្រាសាទកោះកេរសរុប **២១ ៩៣៥** នាក់ និងទទួលបានចំណូលសរុប **៣២៩ ០២៥** ដុល្លារអាម៉េរិក
- ចំណូលពីការលក់សំបុត្រទូកចុងឃ្នៀសសរុប **៧៩៤ ៣៤៨** ដុល្លារអាម៉េរិក ដោយក្នុងនោះចំនួនទូកសរុប **២៨ ៨៧១** (ទូកតូច ១៩ ៩៤៣ ទូកកណ្តាល ៧ ៨១៥ និងទូកធំ ១ ១១៣)។

**គ.** ក្រុមហ៊ុនអាកាសចរណ៍ បាននិងកំពុងប្រតិបត្តិការមានចំនួន ៣២ ក្រុមហ៊ុន ក្នុងនោះ៖

- ក្រុមហ៊ុនអាកាសចរណ៍ជាតិ មានចំនួន ៤ ក្រុមហ៊ុន ដែលមានជើងហោះហើរអន្តរជាតិចូលសរុប ២៥ ១៧៥ ជើង។

## ៣. ចក្ខុវិស័យទេសចរណ៍កម្ពុជា

ក្នុងឆ្នាំ២០២៥ កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណពី ៧,២ ទៅ ៧,៥ លាននាក់ និងទេសចរជាតិប្រមាណពី ២២,៦៣ ទៅ ២៣ លាននាក់ និងនៅឆ្នាំ២០២៨ អាចទទួលបានទេសចរអន្តរជាតិ

ប្រមាណ ៨,៥ លាននាក់ ជាមួយនឹងទេសចរជាតិប្រមាណពី ២៣ ទៅ ២៤ លាននាក់ (តារាងព្យាករណ៍សូចនាករទេសចរណ៍ ឆ្នាំ២០២៤-២០២៨ ជាឧបសម្ព័ន្ធទី១)។

## III. លទ្ធផលការងារទេសចរណ៍ ឆ្នាំ២០២៤

### ១. ការអភិវឌ្ឍទេសចរណ៍ ការវិនិយោគ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ និងយុទ្ធនាការទាក់ទាញទេសចរ

### ១.១. ការអភិវឌ្ឍទេសចរណ៍ ការវិនិយោគ

#### ក. ការងារអភិវឌ្ឍន៍ផលិតផលទេសចរណ៍

- បានចុះថតស្ប៉តផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍នៅតាមបណ្តាសហគមន៍ទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍មួយចំនួនក្នុងខេត្តកំពង់ចាម
- បានចុះអនុវត្តគម្រោងដែលមានឥទ្ធិពលរហ័សក្រោមហិរញ្ញប្បទានរបស់ស្ថានទូតឥណ្ឌាប្រចាំកម្ពុជាចំនួន៣គម្រោង រួមមាន៖ **ទី១៖** គម្រោងលើកកម្ពស់សកម្មភាពអេកូទេសចរណ៍នៅសហគមន៍អេកូទេសចរណ៍ផាត់សណ្តាយ ស្ថិតនៅក្នុងឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលបច្ចុប្បន្នអនុវត្តសម្រេចបានប្រមាណ ៤០% **ទី២៖** គម្រោងលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍នៅសហគមន៍ទួលព័ន្ធតាឡីបឹងស្នេហ៍ ស្ថិតនៅក្នុងឃុំជាយ ស្រុកបាភ្នំ ខេត្តព្រៃវែង និង**ទី៣៖** គម្រោងអភិវឌ្ឍកម្មវិធីទូរស័ព្ទ (Mobile App) ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយសក្តានុពល និងផលិតផលនៅក្នុងសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ទូទាំងប្រទេស ដែលបច្ចុប្បន្នអនុវត្តសម្រេចបានប្រមាណ ៣៥%
- បានរៀបចំបើកវគ្គបណ្តុះបណ្តាលជំនាញសុវត្ថិភាព និងអនាម័យចំណីអាហារសម្រាប់សហគមន៍ទេសចរណ៍ចំនួន ២ រួមមាន៖ សហគមន៍អេកូទេសចរណ៍ទួលព័ន្ធតាឡីបឹងស្នេហ៍ និងសហគមន៍កសិកម្មមានជ័យ ដែលមានសិក្ខាកាមសរុបចំនួន ៥២ នាក់ (ស្រី ២០ នាក់)
- បានចូលរួមរៀបចំកម្មវិធីសំខាន់ៗចំនួន ២ រួមមាន៖ កម្មវិធីបណ្តែតកន្ទោង និងកម្មវិធីលែងកូនត្រីនិមិត្តរូប ដើម្បីចូលរួមអបអរសាទរពិធីបុណ្យទន្លេលើកទី៨ ឆ្នាំ២០២៤ ខេត្តសៀមរាប
- បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី **"ភូមិទេសចរណ៍គំរូ"** និងបានដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់នៅខេត្តសៀមរាបដែលមានអ្នកចូលរួមចំនួន ១៥០ នាក់
- បានរៀបចំកម្មវិធីដាំដើមឈើអនុស្សាវរីយ៍អបអរសាទរពិធីបុណ្យសមុទ្រលើកទី១១ ឆ្នាំ២០២៤ ក្រោមប្រធានបទ "**អបអរបេតិកភណ្ឌ និងចីរភាពនៃតំបន់ឆ្នេរ**" ដែលមានអ្នកចូលរួម សរុប ៣០០ នាក់។

#### ខ. ការងារផែនការអភិវឌ្ឍទេសចរណ៍

- បានផ្តល់ធាតុចូលសំខាន់ៗដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធលើឯកសារ រួមមាន៖ (១) សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០២៤-២០២៨ ដែលរៀបចំដោយក្រសួងផែនការ (២) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍មហាអនុតំបន់មេគង្គ ឆ្នាំ២០៣០ (៣) កម្មវិធីការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីសម្រាប់ការអភិវឌ្ឍប្រកប

ដោយចីរភាពនៅតំបន់ទន្លេសាប តំបន់ទេសភាពសៀមរាបគូលែន ក្រោមការសម្របសម្រួលរបស់អង្គការ UNDP និងក្រសួងបរិស្ថាន (៤) របាយការណ៍វឌ្ឍនភាពនៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ (៥) គោលនយោបាយមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ (៦) ឯកសារសម្រាប់ការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO)

- សហការជាមួយគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត រៀបចំផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម ឆ្នាំ២០២១-២០២៥ បានចំនួន ២៣រាជធានីខេត្ត
- បានចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មពាក់កណ្ដាលអាណត្តិ នៃការអនុវត្តផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម ឆ្នាំ២០២១-២០២៥ របស់រដ្ឋបាលខេត្តចំនួន ២៣ ដំណាក់កាលទី១ និងដំណាក់កាលទី២
- បានរៀបចំសេចក្ដីព្រាង និងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើសេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពីការរៀបចំផែនការអភិវឌ្ឍទេសចរណ៍រាជធានីខេត្ត
- បានសហការជាមួយអង្គការផ្លាស់ប្ដូរអនុផលព្រៃឈើ (NTFP-EP) និងអង្គការ WWF ដោយអនុវត្តបានលទ្ធផលការងារសំខាន់ៗ រួមមាន៖ (១) ការរៀបចំផែនទីទស្សនាមេគង្គ ដើម្បីភ្ជាប់ការទស្សនាផលិតផល និងសេវាកម្មទេសចរណ៍ពីខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងប្រទេសឡាវ (២) រៀបចំផែនការមេគ្រប់គ្រងសហគមន៍អេកូទេសចរណ៍កោះសាមសិប ខេត្តក្រចេះ និងសហគមន៍អេកូទេសចរណ៍កោះព្រះ ខេត្តស្ទឹងត្រែង និង(៣) រៀបចំគោលការណ៍ណែនាំស្ដីពីការកសាង និងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ អេកូទេសចរណ៍តំបន់មេគង្គលើ។

## គ. ការងារផែនការទេសចរណ៍មូស្លីម

- បានផលិតវីដេអូ ដើម្បីផ្សព្វផ្សាយអំពីសក្ដានុពលវិស័យទេសចរណ៍មូស្លីមក្នុងប្រទេសកម្ពុជាទៅកាន់គោលដៅទីផ្សារទេសចរណ៍មូស្លីមអន្តរជាតិ
- បានរៀបចំឯកសារបណ្ណផ្ទត់ "Cambodia Muslim Friendly Tourism Leaflets" បានចំនួន ៥៥០ ច្បាប់ សម្រាប់ចែកជូនដល់មជ្ឈដ្ឋានទូទៅ និងនៅតាមគោលដៅមួយចំនួន
- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីនិន្នាការ និងតម្រូវការទេសចរមូស្លីមទៅកាន់វិស័យឯកជន និងភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ទៅតាមគោលដៅរាជធានីខេត្តចំនួន ៤ ដែលមានអ្នកចូលរួមទាំងអស់ចំនួន ៥០០ នាក់
- សហការជាមួយស្ថានទូតម៉ាឡេស៊ីរៀបចំកម្មវិធី "Ramadan BaZaar Malaysia" នៅផ្សារទំនើបអ៊ីអនភ្នំពេញ (AEON Mall) រាជធានីភ្នំពេញ
- បានរៀបចំវេទិកាទេសចរណ៍មូស្លីមកម្ពុជា ឆ្នាំ២០២៤ ក្រោមមូលបទ "**ភាពស្រស់ស្អាតនៃសុខដុមនីយកម្ម និងគោលដៅទេសចរណ៍មូស្លីម**" ដែលមានអ្នកចូលរួមចំនួន ៣៩៦ នាក់
- បានចុះសម្របសម្រួលក្នុងកម្មវិធី FAM Trip ជាមួយក្រុមការងារផលិតកម្ម Dubai Production មកពីសាធារណរដ្ឋកាហ្សាក់ស្ថាន ដែលបានមកទស្សនា ថតរូបភាព និងផលិតជាវីដេអូខ្សែភាពយន្តនៅតំបន់ទេសចរណ៍នានា នៅក្នុងខេត្តសៀមរាប

- បានចុះសិក្សា និងប្រមូលទិន្នន័យក្នុងការកំណត់ទីតាំង (ZONING) សម្រាប់ការអភិវឌ្ឍតំបន់ទេសចរណ៍មូស្លីមតាមបណ្ដាខេត្តគោលដៅដែលមានសក្ដានុពលទេសចរណ៍រួមមាន៖ ខេត្តកំពត ខេត្តត្បូងឃ្មុំ ខេត្តសៀមរាប និងខេត្តបាត់ដំបង
- បានរៀបចំស្តង់ព័ត៌មាន ដើម្បីផ្សព្វផ្សាយពីទេសចរណ៍មូស្លីមក្នុងពិធីបុណ្យសមុទ្រលើកទី១១ ឆ្នាំ២០២៤ នៅខេត្តកំពត ក្រោមប្រធានបទ "អបអរបេតិកភណ្ឌ និងចីរភាពនៃតំបន់ឆ្នេរ"
- បានជួបពិភាក្សាការងារជាមួយ ឯកឧត្តមឯកអគ្គរាជទូតម៉ាឡេស៊ី ឯកឧត្តមឯកអគ្គរដ្ឋទូតឥណ្ឌូនេស៊ី លោកជំទាវឯកអគ្គរដ្ឋទូតតួកគី ឯកឧត្តមឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីត ឯកឧត្តមឯកអគ្គរដ្ឋអាហ្វ្រាបាហ្សង់ និង ឯកឧត្តមឯកអគ្គរដ្ឋទូតកាហ្សាក់ស្ថាន ប្រចាំកម្ពុជា ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការ និងកិច្ចការងារអភិវឌ្ឍទេសចរណ៍មូស្លីម
- បានជួបពិភាក្សាការងារជាមួយ លោក Mohammed Alqasim "Country Manager" អាកាសចរណ៍ Emirate Airline ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទេសចរណ៍រវាងប្រទេសទាំងពីរ ក្នុងការជំរុញទេសចរណ៍ដោយបង្កើនជើងហោះហើរពី Dubai មកកាន់គោលដៅទេសចរណ៍ផ្សេងៗទៀតក្នុងកម្ពុជា។

### ឃ. ការងារវិនិយោគទេសចរណ៍

- ឆ្នាំ២០២៤ គម្រោងវិនិយោគលើវិស័យទេសចរណ៍មានចំនួន ៤ គម្រោង និងគម្រោងគាំទ្រលើវិស័យទេសចរណ៍ចំនួន ១ គម្រោង ដែលមានទុនវិនិយោគសរុប ៧៤៤ លានដុល្លារអាមេរិក និងផ្តល់ឱកាសការងារសរុបចំនួន ៦ ១១៦ កន្លែង
- បានបញ្ចប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ សម្រាប់កំណើនប្រកបដោយបរិយាបន្នក្នុងមហាអនុតំបន់ ដំហាន២ (2nd GMS TIIG 3701-CAM (COL) គម្រោងនេះផ្តោតសំខាន់លើ (១) ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖ អនុវត្តដោយក្រសួងសាធារណការ និងដឹកជញ្ជូន រួមមាន ទីលានកប់សំរាម ផ្លូវបណ្តោយឆ្នេរខេត្តកែបប្រវែង ១២,៧៥ គ.ម និងកំពង់ផែទេសចរណ៍កោះទន្សាយ (២) ផ្នែកស្តង់ដាទេសចរណ៍អាស៊ាន៖ ការអនុវត្តលើស្តង់ដាចំនួន ៥ រួមមាន ស្តង់ដាទីក្រុងស្អាត ស្តង់ដាសណ្ឋាគារបៃតង ស្តង់ដាបង្គន់អនាម័យសាធារណៈ ស្តង់ដាផ្ទះស្នាក់សហគមន៍ និងស្តង់ដាសហគមន៍ទេសចរណ៍ (៣) ផ្នែកទេសចរណ៍៖ ការរៀបចំស្ថាប័នសម្រាប់គ្រប់គ្រងគោលដៅទេសចរណ៍ ការប្រតិបត្តិ និងគ្រប់គ្រង ដែលការងារសម្រេចបានរួមមានការធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តតំបន់ឆ្នេរ ផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្មខេត្តតំបន់ឆ្នេរ ឆ្នាំ២០២១-២០២៥ ផែនការទីផ្សារទេសចរណ៍ខេត្តតំបន់ឆ្នេរ ឆ្នាំ២០២៣-២០២៥ និងការរៀបចំតម្លើងក្រមប្រតិបត្តិឆ្នេរចំនួន ៣០ ផ្ទាំង
- បានចូលរួមចុះត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃគម្រោងវិនិយោគទេសចរណ៍តាមបណ្តាកោះ និងឆ្នេរកម្ពុជា ដែលបានអនុម័តពីរាជរដ្ឋាភិបាលសរុបចំនួន ២៧ គម្រោង (ខេត្តកោះកុង ៨ គម្រោង ខេត្តព្រះសីហនុ ១៨ គម្រោង និងខេត្តកែប ១ គម្រោង)
- បានចុះសិក្សាពិនិត្យស្ថានភាពជាក់ស្តែងនៅលើគម្រោងធ្វើឱ្យប្រសើឡើងកំពង់ផែទេសចរណ៍

តាមដងទន្លេ តាមយន្តការវិនិយោគសាធារណៈ និងយន្តការវិនិយោគភាពជាដៃគូរដ្ឋ និងឯកជន ដែលទទួលបានការអនុម័តគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ឆ្នាំ២០២៥-២០២៧ ពីរាជរដ្ឋាភិបាលកម្ពុជា នៅខេត្តចំនួន ៥

- បានរៀបចំសិក្ខាសាលាស្ដីពីការរៀបចំគម្រោង៣ឆ្នាំរំកិល ឆ្នាំ២០២៥-២០២៧ ជាមួយការបង្ហាញ អំពីច្បាប់ស្ដីពីវិនិយោគ ការលើកទឹកចិត្ត វិនិយោគនៅកម្ពុជា និងចងក្រងសៀវភៅសក្ដានុពល វិនិយោគទេសចរណ៍រាជធានី-ខេត្ត
- បានរៀបចំសិក្ខាសាលាស្ដីពីតំបន់ភាគខាងត្បូង ក្រោមប្រធានបទការវិនិយោគទេសចរណ៍បៃតង "Green Tourism Investment" សម្រាប់ ឆ្នាំ២០២៤ ដោយមានអ្នកចូលរួមចំនួន ២០០ នាក់
- បានរៀបចំសៀវភៅសក្ដានុពលវិនិយោគវិស័យទេសចរណ៍តាមបណ្ដារាជធានីខេត្ត
- បានរៀបចំគម្រោងសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍន៍សហគមន៍អេកូទេសចរណ៍កំពង់ភ្លុក
- បានសម្របសម្រួលជាមួយក្រុមហ៊ុន K.I.T.P Development Co., Ltd ក្នុងការរៀបចំកម្មវិធី បើកដំណើរការបណ្ដោះអាសន្នកំពង់ផែទេសចរណ៍អន្តរជាតិកំពត
- បានចុះពិនិត្យវាយតម្លៃ និងអនុម័តគម្រោងជាប់គាំងនៅខេត្តព្រះសីហនុចំនួន ៧៧ លើ ២១៣ គម្រោង ដែលបានស្នើសុំលើកទឹកចិត្ត រួមមាន ពាក់ព័ន្ធនឹងពន្ធដារមាន ៣៨ គម្រោង គយ និងរដ្ឋាករមាន ៦ គម្រោង សំណង់មាន ១៣ គម្រោងអចលនទ្រព្យមាន ៣ គម្រោង ការចុះ បញ្ជីការសហគ្រាសមាន ១០ គម្រោង និងទេសចរណ៍មាន ៧ គម្រោង។

## ង. ការងារបរិវត្តកម្មឌីជីថល

### ❖ កិច្ចសហប្រតិបត្តិការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានអនុវត្តអនុស្សរណៈនៃការយោគយល់ស្ដីពីកិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើប្រាស់ថ្នាល ផ្ទៀងផ្ទាត់ឯកសារ verify.gov.kh ការរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់អ៊ីនធឺណិត និងការរៀបចំវគ្គបណ្ដុះបណ្ដាលជំនាញឌីជីថលជូនមន្ត្រីក្រោមឱវាទក្រសួងទេសចរណ៍
- បានដាក់ឱ្យប្រើប្រាស់ថ្នាល និងកម្មវិធីរដ្ឋាភិបាលឌីជីថល (Digital Government Products - DGPs) ដែលរៀបចំឡើងដោយគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល (គ.រ.ឌ. ឬ DGC) ក្នុង ក្របខណ្ឌក្រសួងទេសចរណ៍ រួមមាន VERIFY.GOV.KH, GO.GOV.KH, FORM.GOV.KH និងបន្តសហការក្នុងការរៀបចំដាក់ឱ្យប្រើប្រាស់ថ្នាល និងកម្មវិធីដទៃទៀត
- បានធ្វើការសិក្សាអំពីហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៃក្រសួងទេសចរណ៍ ហើយបានកំណត់ និង ដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដែលបានកើតមានឡើងក្នុងបណ្ដាញតភ្ជាប់អ៊ីនធឺណិត និងបានរៀបចំផែនការធ្វើទំនើបកម្មបណ្ដាញអ៊ីនធឺណិត និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល
- បានរៀបចំវគ្គបណ្ដុះបណ្ដាលជំនាញឌីជីថលជូនដល់មន្ត្រីរាជការក្រោមឱវាទក្រសួង ទេសចរណ៍ និងបានបញ្ជូនមន្ត្រីសរុបចំនួន ២៤០ នាក់ (ស្ត្រី ៨៦ នាក់) លើជំនាញ វគ្គភាព ជាអ្នកដឹកនាំ និងបរិវត្តកម្មឌីជីថល វគ្គជំនាញឌីជីថលចាំបាច់ វគ្គអក្ខរកម្មព័ត៌មាននិងប្រព័ន្ធ ផ្សព្វផ្សាយ ជំនាញសន្តិសុខសាយប័រ (Cybersecurity) ជំនាញអភិវឌ្ឍន៍សុសវែរ (Software Development) និងជំនាញរដ្ឋបាលបណ្ដាញ (Network Administration)

- បានទទួលកុំព្យូទ័រចំនួន ២៤០ គ្រឿង ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរួមចំណែកក្នុងការជំរុញបរិវត្តកម្មឌីជីថលនៅក្នុងក្រសួងទេសចរណ៍
- បានបង្ហោះវេបសាយ (Hosting website) និងអ៊ីម៉ែល (Email) ដោយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

❖ **កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន**

➢ ក្រុមហ៊ុន ប្រាវីនយ៉ា អ៊ីសឺវីស (PRAVINYA ESERVICES CO., LTD.)៖
  - បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងក្រសួងទេសចរណ៍ និងក្រុមហ៊ុន ប្រាវីនយ៉ា អ៊ីសឺវីស ស្តីពីការចូលរួមបរិវត្តកម្មឌីជីថលនៃក្រសួងទេសចរណ៍
  - បានសហការរៀបចំប្រព័ន្ធ All-in-one Travel App និងរៀបចំវិបសាយ visitcambodia.com និងបានរៀបចំក្រុមការងារបញ្ចូលខ្លឹមសារ។

➢ ក្រុមហ៊ុន VISA WORLDWIDE PTE. LIMITED
  - បានចុះអនុស្សរណៈនៃការយោគយល់រវាងក្រសួងទេសចរណ៍ និងក្រុមហ៊ុន VISA WORLDWIDE PTE. LIMITED នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤
  - បានពិភាក្សាអំពីផែនការសកម្មភាព និងកិច្ចសហប្រតិបត្តិការរវាងក្រសួងទេសចរណ៍ និងក្រុមហ៊ុន។

➢ ក្រុមហ៊ុន MASTERCARD ASIA/PACIFIC PTE. LTD.,
  - បានជួបប្រជុំជាមួយតំណាងក្រុមហ៊ុន ដើម្បីពិនិត្យលើលទ្ធភាពចុះអនុស្សរណៈនៃការយោគយល់ ដើម្បីចូលរួមជំរុញទេសចរណ៍នៅកម្ពុជា តាមរយៈបទពិសោធរបស់ក្រុមហ៊ុនជាមួយវិស័យសាធារណៈនៅក្នុងតំបន់ និងសកលលោក។

➢ ក្រុមហ៊ុន HUAWEI TECHNOLOGIES (CAMBODIA) CO., LTD.
  - បានសិក្សាអំពីលទ្ធភាពក្នុងការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារ និងសេវូបករណ៍ (Server) របស់ក្រុមហ៊ុន HUAWEI ក្នុងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថលក្នុងក្រសួងទេសចរណ៍
  - បានសិក្សាអំពីថ្នាល និងកម្មវិធីវៃឆ្លាតរបស់ក្រុមហ៊ុន HUAWEI ពាក់ព័ន្ធនឹង Smart Tourism។

❖ **លទ្ធផលផ្សេងៗទៀត**

- បាននិងកំពុងរៀបចំប្រព័ន្ធទូរស័ព្ទ Hotline ដោយប្រើប្រាស់លេខកូដខ្លី ១២២១ សម្រាប់ផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍ជូនប្រជាពលរដ្ឋ ទេសចរជាតិ និងអន្តរជាតិ ដើម្បីសាកសួរ ផ្តល់ និងរាយការណ៍ពីព័ត៌មានទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលការហៅចូលលេខកូដខ្លីនេះ គឺមិនគិតកម្រៃសេវាពីសាធារណជនឡើយ
- បានរៀបចំ Calltune និងសារខ្លី (SMS) ក្នុងប្រព័ន្ធទូរស័ព្ទ ដើម្បីផ្សព្វផ្សាយ និងជំរុញវិស័យទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា

- បាននិងកំពុងរៀបចំក្រុមការងារ និងការចូលរួមសកម្មភាព នៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ពាក់ព័ន្ធនឹងទេសចរណ៍ល្បែងពាណិជ្ជកម្ម។

❖ **ផែនការបរិវត្តកម្មឌីជីថលនៃក្រសួងទេសចរណ៍**

- គោលដៅ៖ ការបង្កើតបាននូវប្រព័ន្ធទេសចរណ៍ឆ្លាត ដោយប្រើប្រាស់បច្ចេកវិទ្យាក្លោដ (Cloud) និងបច្ចេកវិទ្យាឈានមុខផ្សេងៗទៀត ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ថ្នាល និងកម្មវិធីឌីជីថលសម្រាប់គ្រប់គ្រង និងផ្តល់សេវាទេសចរណ៍ ដែលមានស្តង់ដា ប្រសិទ្ធភាព សន្តិសុខ និងសុវត្ថិភាពខ្ពស់
- ដំណើរការនៃបរិវត្តកម្មឌីជីថល ដូចជា៖
  - កសាងមូលដ្ឋានគ្រឹះសម្រាប់ទេសចរណ៍ឆ្លាត ដែលមានជាអាទិ៍ អភិបាលកិច្ច កិច្ចសហការ និងសហប្រតិបត្តិការ និងការរៀបចំរចនាសម្ព័ន្ធស្ថាប័ន
  - សិក្សា រៀបចំផែនការ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ថ្នាល និងកម្មវិធីសម្រាប់វិស័យទេសចរណ៍
  - រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីជំនាញ និងបុគ្គលពាក់ព័ន្ធ។
- ហេដ្ឋារចនាសម្ព័ន្ធឌីជីថល
  - ថែទាំហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលមានស្រាប់ដើម្បីជានាគុណភាពនិងនិរន្តរភាពសេវា
  - រៀបចំហេដ្ឋារចនាសម្ព័ន្ធឌីជីថលថ្មីដែលមានលក្ខណៈទំនើបទាន់សម័យ មានប្រសិទ្ធភាព សន្តិសុខ និងសុវត្ថិភាពខ្ពស់ ដោយប្រើប្រាស់បច្ចេកវិទ្យាក្លោដ
  - រៀបចំបន្ទប់ពិសោធន៍ (LAB) សម្រាប់បម្រើការទូទៅ ទាំងការបណ្តុះបណ្តាល និងការអភិវឌ្ឍថ្នាល និងកម្មវិធី
  - រៀបចំប្រព័ន្ធប្រាស្រ័យទាក់ទងឌីជីថល (បន្ទប់ប្រជុំ និងកិច្ចសហការ)។
- ទេសចរណ៍ឆ្លាត
  - ប្រើប្រាស់បច្ចេកវិទ្យា ទិន្នន័យ ថ្នាល និងនវានុវត្តន៍ ដើម្បីលើកកម្ពស់បទពិសោធ និងផ្តល់សេវាទេសចរណ៍ឱ្យមានភាពងាយស្រួល ទាក់ទាញ ប្រសិទ្ធភាព សន្តិសុខ និងសុវត្ថិភាពខ្ពស់ក្នុងការប្រើប្រាស់។
  - ការងាររៀបចំទេសចរណ៍ឆ្លាត
    - ការបណ្តុះបណ្តាល (ថ្នាល ការអភិវឌ្ឍ និងការគ្រប់គ្រង)
    - ផែនការអភិវឌ្ឍប្រព័ន្ធ
    - ការអភិវឌ្ឍ ដាក់ឱ្យដំណើរការ និងការថែទាំ។
- ប្រព័ន្ធព័ត៌មានចាំបាច់សម្រាប់ក្រសួងទេសចរណ៍
  - ថ្នាលសម្រាប់គាំទ្រដល់ការបង្កើតសេវាទេសចរណ៍ឆ្លាត
  - ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងគោលការណ៍ណែនាំទេសចរណ៍
  - ប្រព័ន្ធគោលដៅទេសចរណ៍ឆ្លាត
  - ផែនទីទេសចរណ៍ឌីជីថល

- ប្រព័ន្ធគ្រប់គ្រងព័ត៌មានផលិតផលទេសចរណ៍
- ប្រព័ន្ធកក់ និងទិញតាមអនឡាញ
- ប្រព័ន្ធគ្រប់គ្រងអាជ្ញាបណ្ណ និងចំណូល
- ប្រព័ន្ធគ្រប់គ្រងរចនាសម្ព័ន្ធ និងលំហូរឯកសារ
- ប្រព័ន្ធគ្រប់គ្រងបុគ្គលិក
- ប្រព័ន្ធសិក្សាពីចម្ងាយ
- ប្រព័ន្ធគ្រប់គ្រងស្តង់ដាទេសចរណ៍ វិញ្ញាបនបត្រ និងអនុលោមភាព

## ១.២. ការពង្រឹងកិច្ចសហប្រតិបត្តិការទេសចរណ៍

### ក. កិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខណ្ឌអាស៊ាន

កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ កាលពីថ្ងៃទី២២-២៨ ខែមករា ឆ្នាំ២០២៤ ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

**❖ កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ានលើកទី២៧**

រដ្ឋមន្ត្រីទេសចរណ៍នៃប្រទេសជាសមាជិកអាស៊ានទាំង១០ និងទីម័រខាងកើតជាប្រទេសសង្កេតការណ៍ បានវាយតម្លៃខ្ពស់ក្នុងការអនុវត្តយុទ្ធសាស្ត្រទេសចរណ៍អាស៊ាន ឆ្នាំ២០១៦-២០២៥ (ATSP 2016-2025) ដោយសម្រេចបានលទ្ធផល ៦០% និងបានផ្តល់ការឯកភាពរួមគ្នាលើសកម្មភាពបន្ត រួមមាន៖

- បានឯកភាពលើសេចក្តីព្រាងស្តង់ដាអេកូទេសចរណ៍អាស៊ាន (ASEAN Ecotourism Standard) ដែលនឹងត្រូវសុំការឯកភាពនាកិច្ចប្រជុំកំពូលអាស៊ាន លើកទី៤៣
- បានអនុម័តលើផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍទេសចរណ៍អាស៊ានប្រកបដោយនិរន្តរភាព
- បានអនុម័តអនុស្សរណៈយោគយល់គ្នារវាងអង្គការទេសចរណ៍សហប្រជាជាតិ (UN Tourism) និងអាស៊ាន
- បានឯកភាពលើការបង្កើតកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទេសចរណ៍អាស៊ាន-ចិន
- បានឯកភាពឱ្យកម្ពុជាធ្វើជាប្រធានដឹកនាំគណៈកម្មាធិការត្រួតពិនិត្យអ្នកជំនាញទេសចរណ៍អាស៊ានសម្រាប់អាណត្តិ ឆ្នាំ២០២៤-២០២៥
- បានឯកភាពឱ្យកម្ពុជារៀបចំឯកសារគោលគំនិតចំនួន ៣ ដូចជា៖ (១) ការបង្កើតគោលការណ៍ណែនាំអាស៊ាន ស្តីពីអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍ (២) ការបង្កើតគោលការណ៍ណែនាំអាស៊ាន ស្តីពីអាជីវកម្មទេសចរណ៍បៃតង និង(៣) ការបង្កើតការណែនាំ ស្តីពីមូលនិធិបៃតងទេសចរណ៍អាស៊ាន ដើម្បីបន្តអនុវត្តសេចក្តីប្រកាសទីក្រុងភ្នំពេញ ស្តីពីបរិវត្តកម្មទេសចរណ៍អាស៊ាន
- បានជំរុញការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍ (MRA-TP) និងបានឯកភាពជំរុញដំណើរការលេខាធិការដ្ឋានដែលមានការិយាល័យនៅទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី។

**❖ កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ានបូកបី លើកទី២៣**

រដ្ឋមន្ត្រីទេសចរណ៍អាស៊ានបូកបី បានឯកភាពលើលទ្ធផលការងារ រួមមាន៖

- ផែនការសកម្មភាពលើកិច្ចសហប្រតិបត្តិការទេសចរណ៍អាស៊ានបូកបី ឆ្នាំ២០២១-២០២៥ សម្រេចបាន ៦១,៥%
- បានដាក់ឱ្យដំណើរការគេហទំព័រផ្សព្វផ្សាយទីផ្សារទេសចរណ៍អាស៊ាន-ចិន
- បានឯកភាពលើលទ្ធផលនៃការរៀបចំកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន-ជប៉ុន
- បានឯកភាពលើលទ្ធផលនៃការរៀបចំវេទិកាគោលនយោបាយកម្រិតខ្ពស់ ស្តីពីទេសចរណ៍ប្រកបដោយនិរន្តរភាព
- បានឯកភាពជំរុញបន្ថែមលើកិច្ចសហប្រតិបត្តិការរួមគ្នា ក្នុងការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ការសិក្សា និងផ្សព្វផ្សាយទីផ្សារ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ឡើងវិញ និងការធ្វើបរិវត្តកម្មឌីជីថលទេសចរណ៍អាស៊ាន។

❖ **កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន-ឥណ្ឌា លើកទី១១**

រដ្ឋមន្ត្រីទេសចរណ៍អាស៊ាន-ឥណ្ឌា បានឯកភាពលើលទ្ធផលការងារ រួមមាន៖

- បានឯកភាពពង្រឹងទំនាក់ទំនងរវាងអាស៊ាន និងឥណ្ឌា លើវិស័យដឹកជញ្ជូនតាមរយៈផ្លូវអាកាស ផ្លូវទឹក និងផ្លូវគោក ដើម្បីបង្កើន និងសម្របសម្រួលការធ្វើដំណើរ និងជំរុញលំហូរទេសចរទៅវិញទៅមក
- បានឯកភាពជំរុញការអនុវត្តផែនការសកម្មភាពរួមអាស៊ាន-ឥណ្ឌា ឆ្នាំ២០២៣-២០២៧ និងជំរុញការបង្កើតសកម្មភាពរួមគ្នា ដើម្បីបន្តពង្រឹងនិរន្តរភាពទេសចរណ៍អាស៊ាន និងឥណ្ឌា។

❖ **កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន-រុស្ស៊ី លើកទី៣**

រដ្ឋមន្ត្រីទេសចរណ៍អាស៊ាន-រុស្ស៊ីបានឯកភាពលើលទ្ធផលការងារ រួមមាន៖

- បានគាំទ្រលើគម្រោងចំនួន ២ រួមមាន (១) ការពង្រីកទំនាក់ទំនងធុរកិច្ចរវាងសហគ្រិនទេសចរណ៍រុស្ស៊ី និងអាស៊ាន តាមរយៈការបណ្តុះបណ្តាលភាសារុស្ស៊ី និងការផ្លាស់ប្តូរបទពិសោធ និង(២) ការពិនិត្យគំនិតផ្តួចផ្តើមក្នុងការជំរុញគោលដៅថ្មី និងមិនសូវមានអ្នកស្គាល់។

❖ **កម្មវិធីប្រគល់ពានរង្វាន់ស្តង់ដាទេសចរណ៍អាស៊ាន ឆ្នាំ២០២៤**

កម្ពុជាបានទទួលពានរង្វាន់ទេសចរណ៍អាស៊ានចំនួន ៤ ប្រភេទ សរុបចំនួន **២៥ ពាន** រួមមាន៖ (១) សណ្ឋាគារបៃតងអាស៊ានចំនួន ៥ (២) ទីក្រុងទេសចរណ៍ស្អាតអាស៊ានចំនួន ៣ (ទីក្រុងកំពត ទីក្រុងកែប និងខណ្ឌដូនពេញ) (៣) ស្តង់ដាអាស៊ានម៉ាយ (MICE) ប្រភេទបន្ទប់ប្រជុំចំនួន ៥ (៤) ប្រភេទទីតាំងពិព័រណ៍ចំនួន ៥ (៥) ប្រភេទទីតាំងរៀបចំព្រឹត្តិការណ៍ចំនួន ៥ និង(៦) ទេសចរណ៍ប្រកបដោយនិរន្តរភាពអាស៊ានចំនួន ២។

## ខ. កិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខណ្ឌអនុតំបន់

❖ **កិច្ចសហប្រតិបត្តិការអេកម៉ិក (ACMECS)**

- **កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ ACMECS លើកទី៦** នៅទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា បានអនុម័តលើផែនការសកម្មភាពស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍អេកម៉ិក (ACMECS)

ឆ្នាំ២០២៥-២០២៦ ដែលកម្ពុជាទទួលបន្ទុកលើ៖ (១) ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ និង(២) ការពង្រឹងក្របខណ្ឌស្ថាប័នទេសចរណ៍អេកមិុក តាមរយៈការសិក្សាក្នុងការបង្កើតលេខាធិការដ្ឋាន ឬការិយាល័យសម្របសម្រួលទេសចរណ៍អេកមិុក

- **កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ CLMV លើកទី៧** នៅទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា បានអនុម័តលើផែនការសកម្មភាព ស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍កម្ពុជា-ឡាវ-វៀតណាម-មីយ៉ាន់ម៉ា CLMV ឆ្នាំ២០២៥-២០២៦ ដែលកម្ពុជាទទួលបន្ទុកលើ៖ (១) ការកសាងសមត្ថភាពសម្រាប់ពង្រឹងសមត្ថភាពមន្ត្រីទេសចរណ៍ និងអ្នកផ្តល់សេវាកម្មរបស់ផ្នែកឯកជន និង(២) កិច្ចសហប្រតិបត្តិការជាមួយភាគីទីបី ដើម្បីទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព
- **កិច្ចប្រជុំស្ថាប័នជាតិទេសចរណ៍កម្ពុជា-ឡាវ-វៀតណាម ( three countries one destination) (កម្រិតអគ្គនាយក)** នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ ទទួលបានលទ្ធផល ៣ចំណុច សំខាន់ៗ៖ (១) សម្រេចបង្កើតលក្ខខណ្ឌអនុវត្តការងារ (TOR) សម្រាប់ក្របខណ្ឌនេះ ដែលដឹកនាំរៀបចំដោយកម្ពុជា (២) ឯកភាពរៀបចំកិច្ចប្រជុំ កម្រិតអគ្គនាយក និងកម្រិតរដ្ឋមន្ត្រី បន្ទាប់ពីរៀបចំ TOR (៣) ពិនិត្យលទ្ធភាព សហការជាមួយដៃគូអភិវឌ្ឍន៍ដូចជា ADB ដើម្បីទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ សំដៅអនុវត្តសកម្មភាពចំពោះកិច្ចសហប្រតិបត្តិការ ៣ប្រទេស ស្របតាមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ប្រមុខថ្នាក់ដឹកនាំកំពូលរបស់ប្រទេសទាំងបី។

❖ **ការងារសហប្រតិបត្តិការមហាអនុតំបន់មេគង្គ (GMS) និងច្រករបៀងទេសចរណ៍ខាងត្បូង (STC)**

- បានចូលរួមវេទិកាទេសចរណ៍មេគង្គ ឆ្នាំ២០២៤ និងកិច្ចប្រជុំក្រុមការងារទេសចរណ៍មហាអនុតំបន់មេគង្គ (GMS) លើកទី៥៣ នៅទីក្រុងលីជាំង ខេត្តយូណាន ប្រទេសចិន និងលើកទី៥៤ នៅខេត្តក្រាប៊ី ប្រទេសថៃ ដោយបានពិនិត្យប្រតិបត្តិការទូទៅរបស់ការិយាល័យសម្របសម្រួលទេសចរណ៍មេគង្គ (MTCO) ផែនការសកម្មភាព ប្រតិបត្តិការហិរញ្ញវត្ថុ ការជំរុញការផ្សព្វផ្សាយទេសចរណ៍មេគង្គកម្រិតតំបន់ និងតាមប្រព័ន្ធបណ្តាញសង្គម និងបានអនុម័តផែនការសកម្មភាពប្រចាំឆ្នាំ២០២៥។

## គ. កិច្ចសហប្រតិបត្តិការទេសចរណ៍កម្ពុជា-ចិន

- សហការជាមួយមជ្ឈមណ្ឌលអាស៊ាន-ចិន (ASEAN-China Centre) រៀបចំទទួលស្វាគមន៍ និងសម្របសម្រួលដំណើរទស្សនកិច្ចផ្សព្វផ្សាយគោលដៅទេសចរណ៍កម្ពុជា Familiarization Trip (FAM Trip) ជូនប្រតិភូក្រុមអ្នកសារព័ត៌មាន ប្រតិបត្តិករទេសចរណ៍ និងInfluencers ល្បីៗ សរុបចំនួន ៦ នាក់ មកពីសាធារណរដ្ឋប្រជាមានិតចិន។ ក្រុមអ្នកសារព័ត៌មាន និងInfluencers ទាំង ៦ នាក់ ក៏បានបង្ហោះពីគោលដៅទេសចរណ៍កម្ពុជា ជាវីដេអូ និងរូបថត បានចំនួន ១១៣ លើក ក្នុងប្រព័ន្ធផ្សព្វផ្សាយចំនួន១២ ទទួលបានអ្នកចូលមើលចំនួន ៤៤,៨ លាននាក់ និងមានអ្នកចុចចូលចិត្ត (Likes) ចំនួន ៦ ម៉ឺន
- បានចុះអនុស្សរណៈយោគយល់គ្នា ស្តីពីកិច្ចប្រតិបត្តិការលើវិស័យទេសចរណ៍រវាងក្រសួង

ទេសចរណ៍ និងក្រុមហ៊ុន China Tourism Group Corporation Limited (CTG) អំឡុងពេលពិព័រណ៍ទេសចរណ៍កម្ពុជា-ចិន នៅខេត្តសៀមរាប កាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយ៖ (១) ក្រុមហ៊ុន Yunnan Provincial Investment Holdings Group Co., Ltd (YIG) ស្តីពីការរួមគ្នាបង្កើនការអភិវឌ្ឍទេសចរណ៍វប្បធម៌ នៅខេត្តសៀមរាប (២) សមាគមទីភ្នាក់ងារទេសចរណ៍ហៃគូ និងសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា
- បានចុះហត្ថលេខាលើកំណត់ហេតុកិច្ចប្រជុំជាមួយរដ្ឋបាលខេត្តហឺណាន ស្តីពី "ការពង្រឹងកិច្ចសហប្រតិបត្តិការទេសចរណ៍គ្រប់ជ្រុងជ្រោយ" និង "គម្រោងវិថីសូត្រផ្លូវអាកាសហឺណាន-កម្ពុជា-អាស៊ាន (Henan-Cambodia-ASEAN Air Silk Road-HCAR)" ។

### ឃ. កិច្ចសហប្រតិបត្តិការទេសចរណ៍តំបន់អាស៊ីបូព៌ា

**❖ កិច្ចសហប្រតិបត្តិការទេសចរណ៍កម្ពុជា-ជប៉ុន**

- បានផ្ញើនូវគម្រោងសកម្មភាពថ្នាក់ជាតិសម្រាប់ឆ្នាំសារពើពន្ធ២០២៤ (ASEAN National Activities For FY2024) ជូនមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន (AJC) ដើម្បីរៀបចំកម្មវិធីពង្រឹងសមត្ថភាពដល់មគ្គុទ្ទេសក៍និយាយភាសាជប៉ុនសម្រាប់តំបន់។

**❖ កិច្ចសហប្រតិបត្តិការទេសចរណ៍កម្ពុជា-កូរ៉េ**

- បានសហការជាមួយមជ្ឈមណ្ឌលអាស៊ាន-កូរ៉េ (ASEAN Korea-Centre) រៀបចំកម្មវិធីទ្វេភាគីការអភិវឌ្ឍទេសចរណ៍ប្រកបដោយគុណភាពឆ្ពោះទៅនិរន្តរភាពអាស៊ាន-កូរ៉េ ក្រោមប្រធានបទ "ការបើកកាលានុវត្តភាពក្នុងយុគសម័យឌីជីថល៖ ភាពរីកចម្រើននៃបច្ចេកវិទ្យា និងការអនុវត្តល្អៗក្នុងការលើកកម្ពស់ឧស្សាហកម្មទេសចរណ៍" នៅខេត្តសៀមរាប។

### ង. កិច្ចសហប្រតិបត្តិការទេសចរណ៍តំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក

- បានស្វាគមន៍ទស្សនវិទូដ៏ល្បីរបស់ឥណ្ឌា **យ៉ូហ្គី និងទស្សនវិទូ Sadhguru** រួមជាមួយនឹងគណៈប្រតិភូ ១៣០ នាក់ ដែលអញ្ជើញមកកាន់ខេត្តសៀមរាប សម្រាប់ព្រឹត្តិការណ៍ "Mystic Musing" នៅឧទ្យានបុរាណវិទ្យាអង្គរ ក្នុងគោលបំណងលើកកម្ពស់ខេត្តសៀមរាបជាគោលដៅទេសចរណ៍សមាធិពិភពលោក
- ជើងហោះហើរត្រង់ និងដំបូង រវាងរាជធានីភ្នំពេញ (ប្រទេសកម្ពុជា) - រដ្ឋធានីញ៉ូដេលី (ប្រទេសឥណ្ឌា) របស់ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា (Air Cambodia) ត្រូវបានសម្ពោធជាផ្លូវការកាលពី**ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៤**។

## ១.៣. ការជំរុញសកម្មភាពសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

**❖ ការផ្សព្វផ្សាយតាមរយៈការចូលរួមតាំងពិព័រណ៍ទេសចរណ៍អន្តរជាតិ**

ក្រសួងទេសចរណ៍បានធ្វើសកម្មភាពជាច្រើន ដើម្បីផ្សព្វផ្សាយទេសចរណ៍កម្ពុជា នៅលើទីផ្សារអន្តរជាតិ ដែលបានចូលរួមចំណែកយ៉ាងសំខាន់ ដល់ការអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា នាំឱ្យកំណើនទេសចរអន្តរជាតិមកទស្សនាកម្ពុជាកាន់តែច្រើន ជាពិសេស បានលើកកម្ពស់កិត្តិនាមកម្ពុជាលើឆាកអន្តរជាតិ ផ្អែកលើភាពសំបូរបែបនៃសក្តានុពល វប្បធម៌ និងធម្មជាតិរបស់កម្ពុជា។

❖ ការផ្សព្វផ្សាយតាមវិធីសាស្ត្រឃោសនាទូទៅ

➢ **ការចូលរួមតាំងពិព័រណ៍ទេសចរណ៍អន្តរជាតិ**

ក្រសួងទេសចរណ៍បានចូលរួមពិព័រណ៍ទេសចរណ៍អន្តរជាតិក្នុងឆ្នាំ២០២៤ ចំនួន ៩ លើក រួមមាន៖ ទីផ្សារអាស៊ាន ៣ លើក ទីផ្សារអឺរ៉ុប ១ លើក ទីផ្សារចិន ២ លើក ទីផ្សារកូរ៉េ ១ លើក ទីផ្សារជប៉ុន ១ លើក និងទីផ្សារឥណ្ឌា ១ លើក។

➢ **ការងាររៀបចំទស្សនកិច្ចសិក្សាស្វែងយល់គោលដៅទេសចរណ៍កម្ពុជាជូនប្រតិភូអន្តរជាតិ (FAM Trip)**

ក្រសួងទេសចរណ៍ បានរៀបចំទទួលប្រតិភូ FAM Trip ចំនួន ៩០៦ នាក់ សរុប ២១ លើក (នាំង Dolous Hope, Raid Amazon, CCTV, EBS, តារាល្បីកូនភ្លោះមកពីប្រទេសអង់គ្លេស (Twins Turner) មកថត Spot របស់ក្រុមហ៊ុន MG Cyberster, ប្រតិភូបវរកញ្ញាអន្តរជាតិ...) មកគោលដៅទេសចរណ៍សំខាន់ៗនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអ្នកសារព័ត៌មាន និង Influencers អន្តរជាតិ។

❖ **កិច្ចសហការជាមួយដៃគូសារព័ត៌មានអន្តរជាតិ**

បានបន្តកិច្ចសហការផ្សព្វផ្សាយទេសចរណ៍កម្ពុជាជាមួយបណ្តាញ ទូរទស្សន៍អន្តរជាតិ CNN (CNN Great Big Story), BBC, Chanel News Asia (CNA), CCTV ក្នុងការជំរុញការផ្សព្វផ្សាយសក្តានុពលទេសចរណ៍កម្ពុជាឱ្យកាន់តែទូលំទូលាយពាសពេញពិភពលោក។

➢ **ការផលិត និងបោះពុម្ពឯកសារផ្សព្វផ្សាយ**

ក្រសួងទេសចរណ៍ បានផលិត និងបោះពុម្ពឯកសារផ្សព្វផ្សាយ សៀវភៅ Official Hand Book ជាភាសាអង់គ្លេស ៤ ៣០០ ក្បាល ជាភាសាចិន ២ ០០០ ក្បាល សៀវភៅ Guide Book ភាសាអង់គ្លេសតំបន់ភ្នំពេញ ១ ២០០ ក្បាល ភាសាអង់គ្លេសតំបន់សៀមរាប ១ ២០០ ក្បាល ភាសាអង់គ្លេសតំបន់ឆ្នេរ ១ ២០០ ក្បាល ភាសាអង់គ្លេសតំបន់ភូមិភាគឦសាន្ត ១ ២០០ ក្បាល និងថង់យួរ Eco-Bag (Portrait) ៣ ០០០ ថង់ ព្រមទាំងវីដេអូផ្សព្វផ្សាយព្រឹត្តិការណ៍កម្ពុជា-ចិន នៅសៀមរាប និងព្រឹត្តិការណ៍កម្ពុជា-ឥណ្ឌា នៅ New Delhi។

➢ **ការពង្រឹង និងគ្រប់គ្រងស្ថានតំណាងក្រសួងទេសចរណ៍នៅក្រៅប្រទេស**

ស្ថានតំណាងក្រសួងទេសចរណ៍ក្រៅប្រទេសមានចំនួន ២៨ រួមមានដូចជា៖

- អនុព័ន្ធទេសចរណ៍អមស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំនៅទីក្រុងប៉េកាំង ១
- ទីប្រឹក្សាក្រសួងទេសចរណ៍កម្ពុជាប្រចាំទីផ្សារជប៉ុន ១
- ទីប្រឹក្សាក្រសួងទេសចរណ៍កម្ពុជាប្រចាំទីផ្សារចិន ៤
- ទីប្រឹក្សាក្រសួងទេសចរណ៍កម្ពុជាប្រចាំទីផ្សាររុស្ស៊ី ១
- ទីប្រឹក្សាក្រសួងទេសចរណ៍កម្ពុជាប្រចាំទីផ្សារបារាំង ១
- ទីប្រឹក្សាក្រសួងទេសចរណ៍កម្ពុជាប្រចាំទីផ្សារអារ៉ាប់រួម ១
- ទីប្រឹក្សាក្រសួងទេសចរណ៍កម្ពុជាប្រចាំទីផ្សារអាស៊ាន ១
- ស្ថានតំណាងទេសចរណ៍កម្ពុជាប្រចាំទីផ្សារចិន ៨
- ស្ថានតំណាងទេសចរណ៍កម្ពុជាប្រចាំទីផ្សារជប៉ុន ១
- ស្ថានតំណាងទេសចរណ៍កម្ពុជាប្រចាំទីផ្សារកូរ៉េ ១

- ស្ថានតំណាងទេសចរណ៍កម្ពុជាប្រចាំទីផ្សារអឺរ៉ុប ៦
- ស្ថានតំណាងទេសចរណ៍កម្ពុជាប្រចាំទីផ្សារអាមេរិក ១
- ស្ថានតំណាងទេសចរណ៍កម្ពុជាប្រចាំទីផ្សារអាមេរិកខាងត្បូង ១។

❖ **ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធឌីជីថល**

ជំរុញការងារផ្សព្វផ្សាយឱ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ ស្របតាមការវិវត្តនៃបដិវត្តន៍ឧស្សាហកម្ម ៤.0 នាពេលបច្ចុប្បន្ន ដោយបន្តចូលរួមផ្សព្វផ្សាយជាប្រចាំនូវព័ត៌មានថ្មីៗ និងព្រឹត្តិការណ៍សំខាន់ៗពាក់ព័ន្ធវិស័យទេសចរណ៍តាមរយៈបណ្តាញព័ត៌មានសង្គម (Facebook, Instagram, YouTube, Mobile App, Website, TikTok, WeChat...) និងប្រព័ន្ធសារព័ត៌មានអនឡាញល្បីៗជាច្រើន។

❖ **ការផ្សព្វផ្សាយតាមរយៈព្រឹត្តិការណ៍ជាតិ និងអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស**

➢ **យុទ្ធនាការ "ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ២០២៤"**

- បានរៀបចំព្រឹត្តិការណ៍សំដែងក្បាច់គុនសៅលីញ និងគុនល្បុក្កតោនៅអង្គរ (When Shaolin Meets Bokator at Angkor) នៅបរិវេណខាងជើង ប្រាសាទបាយ័ន ខេត្តសៀមរាប
- បានរៀបចំវេទិកាទេសចរណ៍កម្ពុជា-ចិន (Cambodia-China Tourism Forum) នៅខេត្តសៀមរាប
- បានរៀបចំពិព័រណ៍ម្ហូបអាហារកម្ពុជា-ចិន (Cambodia-China Gastronomy Week) នៅខេត្តសៀមរាប
- បាននាំយកក្បាច់គុនល្បុក្កតោទៅសំដែងរួមគ្នាជាមួយក្បាច់គុនកុងហ្វូសៅលីញ (Henan Meets Cambodia at Shaolin) នៅទីក្រុងចឹងចូវ ខេត្តហឺណាន ដែលជាព្រឹត្តិការណ៍បដិការបន្ទាប់ពីក្បាច់គុនសៅលីញបានទៅសំដែងនៅមុខ ប្រាសាទអង្គរ ហើយក៏ជាលើកដំបូងដែលក្បាច់គុនអន្តរជាតិបានមកសំដែងនៅពីមុខខ្លោងទ្វារ វត្តសៅលីញដោយផ្ទាល់
- បានរៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយគោលដៅទេសចរណ៍ចិន (China Tourism Roadshow to Siem Reap) នៅខេត្តសៀមរាប
- បានរៀបចំពិព័រណ៍ទេសចរណ៍កម្ពុជា-ចិន (Cambodia-China Travel Fair) នៅខេត្តសៀមរាប ដោយមានការចូលរួមពីក្រុមហ៊ុនទេសចរណ៍ ក្នុងស្រុកប្រមាណ ១០០ ក្រុមហ៊ុន និងអ្នកទិញកញ្ចប់ទស្សនកិច្ច (Buyers) ពីប្រទេសចិន ប្រមាណ ១០០ នាក់ ឬស្មើ១០០ ក្រុមហ៊ុនផងដែរ
- បានសហការជាមួយអគ្គនាយកដ្ឋានកិច្ចការបោះពុម្ពផ្សាយភាសាបរទេស នៃសាធារណរដ្ឋប្រជាមានិតចិន និងស្ថានទូត នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា រៀបចំពិព័រណ៍រូបថត សម្រស់ប្រទេសកម្ពុជា សម្រស់ប្រទេសចិន "កម្ពុជា-ចិនក្នុងស៊ុមរូបតែមួយ" នៅខេត្តសៀមរាប

➢ **យុទ្ធនាការ "ឆ្នាំទេសចរណ៍កម្ពុជា-ឥណ្ឌា លើកទី១ ២០២៤"**

- បានសហការជាមួយក្រសួងទេសចរណ៍ នៃសាធារណរដ្ឋឥណ្ឌា រៀបចំពិធីបើកជាផ្លូវការ "ឆ្នាំទេសចរណ៍កម្ពុជា-ឥណ្ឌា លើកទី១" នៅទីក្រុងញ៉ូដេលី ស្របជាមួយការបើកជើង

ហោះហើរត្រង់ ភ្នំពេញ-ញ៉ូដេលី របស់ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា (Air Cambodia)

- បានសហការជាមួយស្ថានទូតឥណ្ឌាប្រចាំកម្ពុជា រៀបចំព្រឹត្តិការណ៍ "ទិវាយោគៈអន្តរជាតិ លើកទី ១០ (International Yoga Day)" ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប
- បានរៀបចំវេទិកាទេសចរណ៍កម្ពុជា-ឥណ្ឌា (Cambodia-India Tourism Forum) នៅខេត្តសៀមរាប
- បានរៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយទេសចរណ៍កម្ពុជាសម្រាប់ផ្នែកឯកជនឥណ្ឌា(India Tourism Roadshow to Siem Reap) នៅខេត្តសៀមរាប។

➢ **ព្រឹត្តិការណ៍ជាតិ និងអន្តរជាតិក្នុងប្រទេសផ្សេងៗ**

- បានសហការជាមួយក្រុមហ៊ុនជីប ម៉ុង ដើម្បីរៀបចំព្រឹត្តិការណ៍ Gumball 3000 Rally in Cambodia នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ព្រមទាំងបានទទួលវិញ្ញាបនបត្រការបំបែកកំណត់ត្រាពិភពលោក (Guinness World Records) របស់កម្ពុជា "ការតាំងបង្ហាញរថយន្តទំនើប រថយន្ត Sport ដ៏ធំបំផុត" នៅខេត្តសៀមរាប
- បានរៀបចំជំនួបផ្លាស់ប្តូរពាណិជ្ជកម្មទេសចរណ៍អន្តរជាតិ (Cambodia Travel Match 2024) នៅខេត្តកំពត ដោយមានការអញ្ជើញចូលរួមពីប្រតិភូអ្នកទិញចំនួន ៧៥ ក្រុមហ៊ុន ដែលអញ្ជើញមកពី ៨ ប្រទេស និងប្រតិបត្តិករទេសចរណ៍ ក្នុងស្រុកចំនួន ៦៨ ក្រុមហ៊ុន
- បានសហការគាំទ្ររៀបចំព្រឹត្តិការណ៍ Raid Amazons 2024 របស់ក្រុមហ៊ុន ZBO France នៅខេត្តសៀមរាប
- បានសហការជាមួយរដ្ឋបាលខេត្តព្រះសីហនុ រៀបចំព្រឹត្តិការណ៍ "ពិព័រណ៍ទេសចរណ៍ វប្បធម៌ និងពាណិជ្ជកម្ម" នៅខេត្តព្រះសីហនុ
- បានសហការរៀបចំព្រឹត្តិការណ៍ជំនួបក្រុមម៉ូតូទេសចរណ៍ Siem Reap Bike Week (Car & Bike Festival) នៅអាកាសយានដ្ឋានសៀមរាបចាស់
- បានសហការរៀបចំព្រឹត្តិការណ៍ Big Bike Meeting Elite Night នៅបរិវេណផាប់ស្ទ្រីត ខេត្តសៀមរាប
- បានសហការរៀបចំពន្លាទេសចរណ៍ក្នុងព្រឹត្តិការណ៍ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុក នៅរាជធានីភ្នំពេញ ដែលមានទេសចរអន្តរជាតិចូលទស្សនាទាំង ៣ថ្ងៃ ចំនួន ៥ ៦០០ នាក់
- បានរៀបចំដាក់បញ្ចូរព័ត៌មានទេសចរណ៍នៅក្នុងផ្សារទំនើបអ៊ីអនសែនសុខ សម្រាប់ផ្តល់ព័ត៌មានពីគោលដៅទេសចរណ៍កម្ពុជា។

❖ **ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធឌីជីថល (Digital marketing)**

- ក្រសួងទេសចរណ៍បន្តជំរុញការផ្សព្វផ្សាយវិស័យទេសចរណ៍ តាមរយៈគ្រប់បណ្តាញព័ត៌មានសង្គម រួមមាន Facebook, Instagram, YouTube, Mobile App, Website, TikTok, WeChat ជាដើម។

## ២.ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងការពង្រឹងគុណភាពអាជីវកម្ម សេវាកម្មទេសចរណ៍

### ២.១. ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

- បានប្រមូលចំណូលពីអាជ្ញាបណ្ណទេសចរណ៍ ចំណាត់ថ្នាក់ សេវាកម្មទេសចរណ៍ និងការពិន័យអន្តរការណ៍ ដោយសម្រេចបាន **៣ ០៩៥ ៦៦០ ៥០០ រៀល** លើសច្បាប់ថវិកា ឆ្នាំ២០២៤ ចំនួន ២ ៧៦៣ ៦៦០ ៥០០ រៀល ស្មើនឹង ៤៩,២% ក្នុងនោះ ចំណូលបានពីអាជ្ញាបណ្ណទេសចរណ៍មានចំនួន ២ ៧៦៣ ៦៦០ ៥០០ រៀល ចំណូលពីចំណាត់ថ្នាក់សេវាកម្មទេសចរណ៍មានចំនួន ២១៣ ១០០ ០០០ រៀល និងចំណូលពីការពិន័យអន្តរការណ៍មានចំនួន ១១៨ ៩០០ ០០០ រៀល
- អាជីវកម្មទេសចរណ៍បានស្នើសុំអាជ្ញាបណ្ណពីក្រសួងទេសចរណ៍មានចំនួន ៣ ៧៨៥ អាជ្ញាបណ្ណ ក្នុងនោះ៖ (១) សណ្ឋាគារមានចំនួន ៥២១ (២) ភោជនីយដ្ឋានមាន ចំនួន ២៧៧ (៣) ផ្ទះស្នាក់មានចំនួន ២៤៨ (៤) ម៉ាស្សាមានចំនួន ៣០ (៥) ទីភ្នាក់ងារទេសចរណ៍មានចំនួន ៤៨២ (៦) រមណីយដ្ឋានទេសចរណ៍មានចំនួន ៥៧ (៧) កីឡាទេសចរណ៍មានចំនួន ៤៥ (៨) មគ្គុទ្ទេសក៍ទេសចរណ៍មានចំនួន ១ ៩៦៦ (៩) អ្នកបកប្រែបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍មានចំនួន ១៦៤
- បានផ្តល់ចំណាត់ថ្នាក់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ចំនួន ៧២ ចំណាត់ថ្នាក់រមណីយដ្ឋានទេសចរណ៍ ១ ចំណាត់ថ្នាក់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យចំនួន ១ និងវិញ្ញាបនបត្រទទួលស្គាល់គុណភាពទទួលទេសចរចិនចំនួន ៣៥ និងបានពិន័យអន្តរការណ៍ចំនួន ២០៨ ករណី។ (តារាងប្រៀបធៀបលម្អិតជាឧបសម្ព័ន្ធ)

### ២.២. ការពង្រឹងគុណភាពអាជីវកម្មសេវាកម្មទេសចរណ៍

- បានចុះពង្រឹងគុណភាពសេវាកម្មទេសចរណ៍ និងត្រួតពិនិត្យភាពជាក់ស្តែងនៃអាជីវកម្ម ចំនួន ១៤ លើក ក្នុងខេត្តគោលដៅចំនួន ៦ ខេត្ត
- បានរៀបចំសិក្ខាសាលាស្តីពីការពង្រឹងគុណភាពសេវាកម្មទេសចរណ៍បានចំនួន ៣ លើក នៅខេត្តសៀមរាប ខេត្តកំពត និងខេត្តព្រះសីហនុ
- បានផ្តល់វិញ្ញាបនបត្រទទួលស្គាល់សមាគមឧស្សាហកម្មទេសចរណ៍បានចំនួន ៤
- បានចុះវាយតម្លៃ និងផ្តល់វិញ្ញាបនបត្រទទួលស្គាល់កាណូតទេសចរណ៍កម្ពុជាចំនួន ៤៣ ម្ចាស់ ស្មើនឹង ៥២ គ្រឿង
- បានផ្តល់គោលការណ៍អនុញ្ញាតឱ្យមានការបណ្តុះបណ្តាលអ្នកបកប្រែភាសាកូរ៉េបន្ថែមចំនួន ៥៨ នាក់ ដើម្បីនាំភ្ញៀវកូរ៉េមកទស្សនាកម្ពុជាឱ្យបានច្រើន
- បានដាក់ចេញសារាចរណែនាំលេខ ០០២ សសរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងប្រព័ន្ធអគ្គិភ័យនៅតាមមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (ក្លឹបកម្សាន្ត ខារ៉ាអូខេ វង្គសាល-ឌីស្កូតែក និងបៀរហ្គាឌិន)
- បានចេញសេចក្តីណែនាំស្តីពីការគ្រប់គ្រង និងពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍ទេសចរណ៍ផ្សេងៗ

- បានដាក់ចេញសេចក្តីជូនដំណឹងលេខ ០៦៣ សជណ.អគ២ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការពង្រឹងការគ្រប់គ្រងអាជីវកម្ម និងបុគ្គលិកបម្រើការសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតាមអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (ក្លឹបកម្សាន្ត ខារ៉ាអូខេ វង្គសាល-ឌីស្កូតែក និងបៀរហ្គាឌិន)។

## ២.៣. ការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍

- បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលជាតិដោយផ្ទាល់ចំនួន ៤វគ្គ៖ លើជំនាញ (១) ការិយាល័យជួរមុខ (២) បដិសណ្ឋារកិច្ច និងការគួរសមភ្ញៀវ (៣) គេហកិច្ចនិងផ្នែកសេវាកម្មម្ហូបអាហារ និង(៤) ភេសជ្ជៈ មានសិក្ខាកាមសរុបចំនួន **២៧០ នាក់**
- បានធ្វើការបណ្តុះបណ្តាលយុវជនកម្ពុជាបានចំនួនសរុប ៤ ៥៥៦ នាក់ លើជំនាញ (១) គេហកិច្ច (២) ការិយាល័យជួរមុខ (៣) សេវាកម្មម្ហូបអាហារ (៤) ភេសជ្ជៈ (៥) ធុងកាហ្វេ (៦) ចុងភៅ (៧) មគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍ (៨) គ្រូបង្គោល (៩) អ្នកវាយតម្លៃបង្គោលហូកា នៅខេត្តចំនួន ១០ រួមមាន៖ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ
- បានបើកវគ្គបណ្តុះបណ្តាលអ្នកជំនាញប្រព័ន្ធកក់សំបុត្រយន្តហោះក្នុង និងក្រៅប្រទេសសម្រាប់អ្នកបម្រើការក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ បានចំនួន ១២ វគ្គ ដែលមានសិក្ខាកាមសរុប ១៧៦ នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលលើជំនាញ "មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍" ជូនសមាជិកសហគមន៍ទេសចរណ៍កែច្នៃវត្ថុអនុស្សាវរីយ៍កំពង់រលឹងចំនួន ៦២ នាក់
- គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍បានទទួលស្គាល់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងសាកលវិទ្យាល័យដៃគូ ដែលបានអនុវត្ត និងគាំទ្រកម្មវិធីសិក្សាអាស៊ាន (ASEAN MRA-TP) **ចំនួន ១៨** នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តក្រចេះ និងខេត្តព្រះសីហនុ មានសិស្សបានបញ្ចប់ការបណ្តុះបណ្តាល ចំនួនសរុប **៨ ៩៨៩ នាក់** លើជំនាញសេវាកម្មសណ្ឋាគារ និងសេវាកម្មធ្វើដំណើរ
- បានដាក់កម្មវិធីបណ្តុះបណ្តាលបដិសណ្ឋារកិច្ច ហូកា ទៅក្នុងសាលាបណ្តុះបណ្តាល និងកម្មវិធីបណ្តុះបណ្តាលរួមមាន៖ (១) សាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ស្ពួន (២) មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសមិត្តភាពកម្ពុជា-ជប៉ុន (៣) វិទ្យាស្ថានពហុបច្ចេកទេសតេជោសែន (៤) ក្លឹបទេសចរណ៍ (៥) មជ្ឈមណ្ឌលធនធានវិស័យទេសចរណ៍ នៅខេត្តសៀមរាប និងខេត្តព្រៃវែង
- បានរៀបចំសិក្ខាសាលាដាក់ឱ្យប្រើប្រាស់ និងអនុវត្តក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ចំនួន ៣ លើក នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ ដែលមានអ្នកចូលរួមសរុប ៦៧៦ នាក់

- បានរៀបចំសិក្ខាសាលាជំនាញវិជ្ជាជីវៈ និងវិថីអាជីពការងារក្នុងវិស័យទេសចរណ៍ ដែលមានអ្នកចូលរួមចំនួន ២៥០ នាក់
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងបើកវគ្គស្តីពីកម្មវិធីបណ្តុះបណ្តាលបដិសណ្ឋារកិច្ច ហូកា សម្រាប់ខេត្តសៀមរាប ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ
- បានរៀបចំទិវាជំនាញ ហូកា ឆ្នាំ២០២៤ ក្រោមប្រធានបទ៖ វិនិយោគទេសចរណ៍ វិនិយោគលើធនធានមនុស្ស
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) ដើម្បីជំរុញការបណ្តុះបណ្តាលបដិសណ្ឋារកិច្ច ហូកា
- សហការជាមួយអង្គការ Swisscontact បានរៀបចំ "ផែនទីបង្ហាញផ្លូវជំនាញ ហូកា ឆ្នាំ២០២៤-២០២៨" ដើម្បីជាចលករចូលរួមសំខាន់ក្នុងការលើកកម្ពស់ជំនាញវិជ្ជាជីវៈ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី កម្មវិធីបណ្តុះបណ្តាលបដិសណ្ឋារកិច្ចហូកា សម្រាប់ខេត្តសៀមរាប ក្រោមការគាំទ្ររបស់មូលនិធិអភិវឌ្ឍន៍ជំនាញ
- កម្មវិធីបណ្តុះបណ្តាលបដិសណ្ឋារកិច្ចកម្ពុជាហូកា ដំណាក់កាលទី៣ ឆ្នាំ២០២៤-២០២៨
- កិច្ចសហកាជាមួយអង្គការ និងដៃគូអភិវឌ្ឍន៍នានា ដូចជាអង្គការអន្តរជាតិខាងការងារប្រចាំកម្ពុជា (ILO) អង្គការកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ប្រចាំកម្ពុជា (GIZ) អង្គការស្វីសខន់ថាក់ (SWISSCONTACT) កម្មវិធីអភិវឌ្ឍជំនាញ (SDP) អង្គការ ASSIST ក្រុមហ៊ុនបដិសណ្ឋារកិច្ចថាលាស (THALIAS Hospitality Group) និងអង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំកម្ពុជា (IOM) បានធ្វើការវាយតម្លៃលើការសិក្សាពីមុន (RPL: Recognition of Prior Learning) ដល់អ្នកកំពុងបម្រើការងារនៅក្នុងវិស័យទេសចរណ៍ មានចំនួន ២ ២០០ នាក់ (២០១៧-២០២៣) ដោយទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈអាស៊ាន (ASEAN Level 1 Certificate II) និងវិញ្ញាបនបត្របញ្ជាក់សមត្ថភាព (Certificate of Competency) លើជំនាញ (១) ការិយាល័យជួរមុខ (២) សេវាកម្មម្ហូបអាហារ (៣) គេសជ្ជៈជំនាញគេហកិច្ច (៤) ជំនាញផលិតកម្មម្ហូបអាហារ
- បានធ្វើការវាយតម្លៃលើការសិក្សាពីមុនតាមប្រព័ន្ធឌីជីថល (Digital RPL) ចំនួន ១៣០ នាក់ ក្រោមកិច្ចសហការជាមួយអង្គការអន្តរជាតិខាងការងារប្រចាំកម្ពុជា (ILO)
- បានទទួលស្គាល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពអ្នកជំនាញទេសចរណ៍ (Assessment Center) ចំនួន ៤ ទីតាំង នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប
- បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញបន្ថែម (Up Skilling) ចំនួន ២ ៩៤២ នាក់ រួមមាន៖
    - ការបណ្តុះបណ្តាលខាងក្នុង (In-House Training) ដល់បុគ្គលិកសណ្ឋាគារ ២ ០០០ នាក់
    - វគ្គបណ្តុះបណ្តាលជំនាញបៃតង (Green Skill) ៦០ នាក់
    - កម្មវិធីសមាហរណកម្មជំនាញទេសចរណ៍ (Tourism Skill Integration Program) ១៣០ នាក់
    - កម្មវិធីសិក្សាកម្រិតសញ្ញាបត្រជាន់ខ្ពស់វិជ្ជាជីវៈ ផ្នែកគ្រប់គ្រងបដិសណ្ឋារកិច្ច (Advance Diploma in Hospitality Management) សមមូលនឹងសញ្ញាបត្រវិជ្ជាជីវៈកម្រិត៥

ស្របតាមក្របខណ្ឌគុណវុឌ្ឍិអាស៊ាន ចំនួន ១២ នាក់ សហការជាមួយសាលាសណ្ឋាគារប៉ូលឌុយប្រ៊ូល

- កម្មវិធីសិក្សាជំនាញគ្រប់គ្រងបដិសណ្ឋារកិច្ច (Diploma of Hospitality Management) សមមូលនឹងសញ្ញាបត្រវិជ្ជាជីវៈកម្រិត៤ ស្របតាមក្របខណ្ឌគុណវុឌ្ឍិអាស៊ាន ចំនួន ៨៦ នាក់ សហការជាមួយ សាលាសណ្ឋាគារប៉ូលឌុយប្រ៊ូល
- វគ្គវិក្រឹត្យការលើជំនាញស្ប៉ា និងសុខុមាលភាព ចំនួន ៣០៣ នាក់ ក្នុងនោះជនពិការភ្នែក ចំនួន ៤១ នាក់
- សហការជាមួយមជ្ឈមណ្ឌលអាស៊ានជប៉ុន (ASEAN JAPAN Center) រៀបចំវគ្គបណ្តុះបណ្តាលវិក្រឹត្យការលើជំនាញស្ប៉ា និងសុខុមាលភាព ចំនួន ១៣៣ នាក់ ក្នុងនោះជនពិការ ១០ នាក់
- សហការជាមួយក្រុមហ៊ុន (ACA Travel and Tour) រៀបចំវគ្គបណ្តុះបណ្តាលជំនាញកក់សំបុត្រយន្តហោះ (Ticketing and Reservation) តាមប្រព័ន្ធ AMADEUS ចំនួន ២០០ នាក់។
- សហការជាមួយទីភ្នាក់ងារធ្វើដំណើរអាស៊ីប៉ាស៊ីហ្វិក (PATA) រៀបចំវគ្គបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុ (Financial) និងជំនាញឌីជីថល (Digital) ចំនួន ៥២ នាក់

- បានទទួលស្គាល់ការចុះបញ្ជីការ និងទទួលស្គាល់កម្មវិធីសិក្សាសាលាទេសចរណ៍ចំនួន ១៩ ទីតាំង និងទទួលស្គាល់សាលាទេសចរណ៍ចំនួន ៧ ទីតាំង
- សហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ដើម្បីរៀបចំផែនការសកម្មភាពអនុវត្តគម្រោង
- បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំគុណវុឌ្ឍិជាតិវិជ្ជាជីវៈទេសចរណ៍ និងបានកំពុងរៀបចំសាកល្បងគុណវុឌ្ឍិសញ្ញាបត្រវិជ្ជាជីវៈ១ ក្របខណ្ឌគុណវុឌ្ឍិជាតិលើជំនាញការិយាល័យជួរមុខ និងសេវាកម្មម្ហូបអាហារនិងភេសជ្ជៈ
- សហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ដើម្បីរៀបចំផែនការសកម្មភាពអនុវត្តគម្រោង
- សហការជាមួយលេខាធិការដ្ឋានអាស៊ាន ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលអាស៊ាន **១៥ នាក់** អ្នកវាយតម្លៃបង្គោលអាស៊ាន ១៥ នាក់ សម្រាប់កម្ពុជាលើ សេវាកម្មសណ្ឋាគារ និងសេវាកម្មធ្វើដំណើរ សម្រាប់គ្រូបង្គោលអាស៊ាន និងអ្នកវាយតម្លៃបង្គោលអាស៊ាន បានធ្វើការបណ្តុះបណ្តាលបន្តដល់គ្រូបង្គោលជាតិ និងអ្នកវាយតម្លៃបង្គោលជាតិ ចំនួន ៧៧៣ នាក់
- សហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) រៀបចំសេចក្តីព្រាងគោលការណ៍ ណែនាំកម្មវិធីហ្វឹកហាត់ការងារក្នុងវិស័យទេសចរណ៍ (Apprenticeship Guideline) ជាការអនុវត្តជំហានដំបូង សិស្សសាលាបដិសណ្ឋារកិច្ច និងទេសចរណ៍ ប៉េអេសអឺ បានចូលរួមអនុវត្តចាប់តាំងពីឆ្នាំ២០២០-២០២៤ សរុប **៣៦៣ នាក់** នៃសេវាកម្មសណ្ឋាគារ
- សហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) បានរៀបចំពង្រាងគោលការណ៍ណែនាំស្តីពីជំនាញបៃតង និងជំនាញឌីជីថល ក្នុងវិស័យទេសចរណ៍

- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា រៀបចំកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន ឆ្នាំទី១ ទី២ ទី៣ សម្រាប់ដាក់ចុះអនុវត្តនៅតាមវិទ្យាល័យបច្ចេកទេស និងចំណេះទូទៅ ដែលកម្មវិធីសិក្សាជំនាញនេះ សិស្សនឹងទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិវិជ្ជាជីវៈទេសចរណ៍ មានតម្លៃសមមូលនឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដោយកម្មវិធីសិក្សាគោលនៃជំនាញចំនួន ៥ រួមមាន៖ (១) ការិយាល័យជួរមុខ (២) គេហកិច្ច (៣) សេវាកម្មម្ហូបអាហារនិងភេសជ្ជៈ (៤) ផលិតកម្មម្ហូបអាហារ និង(៥) ជំនាញការីទេសចរណ៍
- បានបញ្ជូនសិស្សជំនាញវិជ្ជាជីវៈទេសចរណ៍ នៃសាលាបដិសណ្ឋារកិច្ច និងទេសចរណ៍ ប៉េ អេស អឺ និងសាលាសណ្ឋាគារ និងទេសចរណ៍ប៉ូលឌុយប្រ៊ូល ចូលរួមកម្មវិធីប្រកួតជំនាញអាស៊ាន (ASEAN SKILL COMPETETION) រយៈពេល ២ឆ្នាំម្តង ឆ្លាស់គ្នានៅក្នុងប្រទេសជាសមាជិកអាស៊ាន លើជំនាញចុងភៅ និងជំនាញសេវាកម្មភោជនីយដ្ឋាន និងទទួលបានមេដាយឆ្នើម ៦ មេដាយឆ្នើមជាតិ ១
- បច្ចុប្បន្ន កម្ពុជា បានទទួលបន្ទុកដឹកនាំការងារផ្សេងៗទៀត ក្នុងផ្នែក MRA-TP សម្រាប់អាស៊ាន៖
    - ទទួលបន្ទុកដឹកនាំរៀបចំបញ្ចប់សេចក្តីព្រាង នៃស្តង់ដាសមត្ថភាពអ្នកជំនាញស្ប៉ា និងសុខុមាលភាពអាស៊ាន ដែលបានអនុម័តនៅថ្នាក់ជំនាញអាស៊ានរួចហើយ ដោយបច្ចុប្បន្នកំពុងចងក្រងកម្មវិធីសិក្សា នឹងត្រៀមប្រកាសផ្សព្វផ្សាយ និងបណ្តុះបណ្តាលគ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលអាស៊ាន នាពេលខាងមុខ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ
    - ទទួលបន្ទុកដឹកនាំរៀបចំយន្តការអាស៊ានស្តីពី "ការវាយតម្លៃការសិក្សាពីមុន លើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN RPL Mechanism for Tourism Professionals)" ដោយសហការជាមួយលេខាធិការដ្ឋានអាស៊ាន ដើម្បីពិភាក្សាលើការរៀបចំយន្តការឱ្យបានកាន់តែស៊ីជម្រៅស្របតាមស្តង់ដារជាតិ និងអាស៊ាន ក្នុងការគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀង MRA-TP ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងកម្រិតតំបន់នាពេលខាងមុខ
- បានរៀបចំបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំផ្សេងៗ ចំនួន ១០ សម្រាប់ទ្រទ្រង់ដល់ដំណើរការនៃការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ទ-MRA។

## ៣. ការពង្រឹងយន្តការអភិបាលកិច្ចទេសចរណ៍

### ៣.១. ការពង្រឹងការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងទេសចរណ៍

#### ក. ការងាររដ្ឋបាល និងកិច្ចការទូទៅ

ដើម្បីសម្របសម្រួលដល់ការងារគ្រប់គ្រងផ្ទៃក្នុង ក្រសួងទេសចរណ៍បានបន្តរៀបចំកែទម្រង់បែបបទរដ្ឋបាលឆ្ពោះទៅទំនើបកម្មការងារ រួមមាន៖

- បានពង្រឹងការគ្រប់គ្រង និងរបៀបរបបការងារគោរពរលិខិតតាមបែបបទនីតិវិធីរដ្ឋបាល ការងារពិធីការ ការធ្វើរបាយការណ៍បូកសរុប និងកំណត់ហេតុអង្គប្រជុំនានា ដោយបញ្ចូលការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កភាពងាយស្រួល និងឆាប់រហ័ស
- បានពង្រឹងឡើងវិញការងារគ្រប់គ្រងសន្តិសុខ សុវត្ថិភាព អនាម័យ និងសោភណភាពនៅជុំវិញបរិវេណទីស្តីការក្រសួងទេសចរណ៍

- បានសម្របសម្រួលការងារបដិសណ្ឋារកិច្ច និងពិធីការ ក្នុងការរៀបចំព្រឹត្តិការណ៍ ពិធីបើកឆ្នាំនៃការផ្លាស់ប្ដូរប្រជាជន និងប្រជាជន កម្ពុជា-ចិន ពិធីបុណ្យទន្លេ លើកទី៨ ពិធីបើកពិធីសម្ដែងរួមគ្នារវាងក្បាច់គុនល្បុក្កតោជាមួយនឹងក្បាច់គុនកុងហ្វូសៅលីង (When Shaolin Meets Bokator at Angkor) ព្រឹត្តិការណ៍ Gumball 3000 Rally in Cambodia វេទិកាទេសចរណ៍កម្ពុជា-ចិន ពិព័រណ៍ម្ហូបអាហារកម្ពុជា-ចិន Cambodia-China Gastronomy Week វេទិកាទេសចរណ៍កម្ពុជា-ឥណ្ឌា និងពិធីបើកបុណ្យសមុទ្រលើកទី១១។

**ខ. ការងារគ្រប់គ្រងធនធានមនុស្ស**

- បច្ចុប្បន្នមន្ត្រីរាជការសរុបមានចំនួន **១ ១៧៦ នាក់ ស្រី ៤១៤ នាក់** ក្នុងនោះ៖
  - ទីស្ដីការក្រសួងសរុបចំនួន **៦៦៧ នាក់ ស្រី ២២២ នាក់**
  - មន្ទីរទេសចរណ៍រាជធានី ខេត្តសរុបចំនួន **៥០៩ នាក់ ស្រី ១៩២ នាក់**
- មន្ត្រីជាប់កិច្ចសន្យាសរុបមានចំនួន **៥៤៥ នាក់ ស្រី ៣៧៧ នាក់** ក្នុងនោះ៖
  - ទីស្ដីការក្រសួងសរុបចំនួន **២៤៥ នាក់ ស្រី ២២១ នាក់**
  - មន្ទីរទេសចរណ៍រាជធានី ខេត្តសរុបចំនួន **៣០០ នាក់ ស្រី ១៥៦ នាក់**
- នាយកដ្ឋានធនធានមនុស្សបានពង្រឹងការងារគ្រប់គ្រងមន្ត្រីរាជការប្រកបដោយប្រសិទ្ធភាព និងទំនើបកម្ម ដោយសម្រេចបានលទ្ធផលការងារ ដូចខាងក្រោម៖
  - បានអនុវត្តការបើកប្រាក់ខែជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធធនាគារ សម្រេចបាន ១០០% និងបើកមួយខែពីរដងនៅរៀងរាល់សប្ដាហ៍ទី២ (៥០%) និងសប្ដាហ៍ទី៤ (៥០%) នៃខែនីមួយៗ
  - បានដាក់ឱ្យអនុវត្តការគ្រប់គ្រងវត្តមានតាមរយៈប្រព័ន្ធស្កេនមុខសម្រាប់គ្រប់អង្គភាពនៅទីស្ដីការក្រសួងទេសចរណ៍
  - បានចូលរួមអនុវត្តការងារកំណែទម្រង់រដ្ឋបាលសាធារណៈ និងធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការតាមប្រព័ន្ធ HRMIS របស់ក្រសួងមុខងារសាធារណៈ
  - បានចាត់បញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្ដុះបណ្ដាលក្នុងប្រទេសចំនួន **១៣០ នាក់ ស្រី ៤៦ នាក់** និងក្រៅប្រទេសចំនួន **៤៩ នាក់ ស្រី ២៨ នាក់** និងបានចាត់បញ្ជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាចូលរួមសិក្ខាសាលាក្នុងប្រទេសចំនួន **១៨៥ នាក់ ស្រី ៧៨ នាក់**
  - បានសហការជាមួយបេឡាជាតិសន្តិសុខសង្គម ធ្វើបណ្ណសមាជិក ប.ស.ស. ជូនសហព័ទ្ធ និងកូនក្នុងបន្ទុករបស់មន្ត្រីរាជការចំនួន **១១៨ នាក់ ស្រី ៧៥ នាក់** និងស្នើសុំបណ្ណសមាជិក ប.ស.ស. ជូនជំនួយការ និងមន្ត្រីជាប់កិច្ចសន្យាចំនួន **២៧៨ នាក់ ស្រី ១៣៥ នាក់**
  - បានស្នើសុំដំឡើងឋានន្តរស័ក្តិ ថ្នាក់ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការចំនួន **២៧៨ នាក់ ស្រី ១០៣ នាក់** និងតាមកម្រិតសញ្ញាបត្រចំនួន **៣៨ នាក់ ស្រី ១០ នាក់**

- បានធ្វើប្រកាសអនុញ្ញាតឱ្យមន្ត្រីរាជការចំនួន **៣ នាក់** ស្ថិតនៅក្នុងភាពទំនេរពីមុខងារ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលបន្ត នៅសាលាភូមិន្ទរដ្ឋបាល
- បានទទួលក្របខ័ណ្ឌមន្ត្រីរាជការពីក្រសួង ស្ថាប័នផ្សេងចំនួន **១ នាក់**
- បានផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការពីក្រសួងទេសចរណ៍ទៅស្ថាប័នផ្សេងៗចំនួន **៣ នាក់** បានផ្លាស់ប្តូរទីកន្លែងមន្ត្រីរាជការចំនួន **២ នាក់** ស្រី **១ នាក់**
- បានលុបក្របខ័ណ្ឌមន្ត្រីរាជការដោយស្ម័គ្រចិត្ត និងដោយមរណភាពចំនួន **៧ នាក់** និងផ្អាកការដំឡើងថ្នាក់ ដល់មន្ត្រីរាជការសរុប **៦៣ នាក់** ស្រី **២៥ នាក់**
- បានតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការដើម្បីបំពេញរចនាសម្ព័ន្ធគ្រប់គ្រងចំនួន **២៧ នាក់** ស្រី **១ នាក់**។

### គ. ការងារសន្តិសុខ និងសុវត្ថិភាពទេសចរ

- លើកកម្ពស់ការពង្រឹងសន្តិសុខ និងសុវត្ថិភាពទេសចរនៅក្នុងចំណោមភាគីពាក់ព័ន្ធ និងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប ខេត្តកំពត និងខេត្តកំពង់ស្ពឺ ក្នុងគោលបំណងជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ លុបបំបាត់បាតុភាពអសន្តិសុខ និងភាពអសកម្មដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិនាមគោលដៅទេសចរណ៍កម្ពុជា
- បានដាក់ចេញយុទ្ធនាការចូលរួមលុបបំបាត់ជំងឺគ្រុនចាញ់ក្នុងវិស័យទេសចរណ៍ នៅខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង ដើម្បីរួមគ្នាសម្រេចគោលដៅយុទ្ធសាស្ត្រជាតិរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ក្នុងការប្រែក្លាយកម្ពុជា ជាប្រទេសគ្មានជំងឺគ្រុនចាញ់នៅឆ្នាំ២០២៥។ យុទ្ធនាការនេះជួយបង្កើតទំនុកចិត្ត និងភាពជឿជាក់របស់ភ្ញៀវទេសចរក្នុងពេលមកកម្សាន្តនៅព្រះរាជាណាចក្រកម្ពុជា។

### ឃ. ការងារគណនេយ្យ និងហិរញ្ញវត្ថុ

- ជារួមនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុបាននិងកំពុងអនុវត្តការងារសម្របសម្រួល និងជំរុញដល់គ្រប់សកម្មភាពក្នុងក្រសួង និងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធសំដៅលើការបង្កើនប្រសិទ្ធភាព និងសុខដុមនីយកម្ម
- សម្រេចបាននូវលទ្ធផលធំៗ សម្រាប់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុដូចជា៖
  - សកម្មភាពការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈអនុវត្តបាននូវមុខងារក្នុងប្រព័ន្ធការគ្រប់គ្រងព័ត៌មានវិទ្យា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System "FMIS") ប្រព័ន្ធបច្ចេកវិទ្យាពត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Nontax Revenues Management Information System "NRMIS") ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State Asset Register Management Information System "SARMIS")
  - បញ្ចូលសកម្មភាពរបស់អង្គភាពនីមួយៗទៅក្នុងប្រព័ន្ធ FMIS
  - គ្រប់គ្រងបាននូវទិន្នន័យថវិការបស់ក្រសួងក្នុងប្រព័ន្ធព័ត៌មានវិទ្យា។

ង. ការងារលទ្ធកម្ម

❖ ប្រភេទលទ្ធកម្ម

- លទ្ធកម្មទំនិញ អនុវត្តបានចំនួន ៧កិច្ចសន្យា គិតជាទឹកប្រាក់ចំនួន ១ ១០១,៧៧ លានរៀល ស្មើនឹង ១០០% នៃតម្លៃកិច្ចសន្យាសរុបដែលបានអនុវត្តរួច
- លទ្ធកម្មសំណង់ អនុវត្តបានចំនួន ១ កិច្ចសន្យា គិតជាទឹកប្រាក់ចំនួន ១១៥,៣២ លានរៀល ស្មើនឹង ១០០% នៃតម្លៃកិច្ចសន្យាសរុបដែលបានអនុវត្តរួច
- លទ្ធកម្មសេវាកម្ម អនុវត្តបានចំនួន ១ កិច្ចសន្យា គិតជាទឹកប្រាក់ចំនួន ១៣៨,៧២ លានរៀល ស្មើនឹង ១០០% នៃតម្លៃកិច្ចសន្យាសរុបដែលបានអនុវត្តរួច។

❖ វិធីសាស្ត្រលទ្ធកម្ម

- ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក អនុវត្តបានចំនួន ១ កិច្ចសន្យា គិតជាទឹកប្រាក់ចំនួន ៤២១,៩៥ លានរៀល ស្មើនឹង ១០០% នៃតម្លៃកិច្ចសន្យាសរុប ដែលបានអនុវត្តរួច
- ការពិគ្រោះថ្លៃ អនុវត្តបានចំនួន ៨ កិច្ចសន្យា គិតជាទឹកប្រាក់ចំនួន៩៣៣,៨៦ លានរៀល ស្មើនឹង ១០០% នៃតម្លៃកិច្ចសន្យាសរុប ដែលបានអនុវត្តរួច។

❖ ការសន្សំសំចៃ

- សន្សំសំចៃតម្លៃកិច្ចសន្យាធៀបនឹងជានាចំណាយបានចំនួន ៥,១១ លានរៀល ស្មើនឹង ០,៣៦%
- សន្សំសំចៃតម្លៃកិច្ចសន្យាធៀបនឹងផែនការបានចំនួន ៤៤៨,០៥ លានរៀល ស្មើនឹង ២៤,៨៦%។

### ៣.២. ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងទេសចរណ៍

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងទេសចរណ៍ បានអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ សម្រេចបាន ៣៣ សកម្មភាព ស្មើនឹង ៩២% ធៀបនឹងផែនការសរុបប្រចាំឆ្នាំ ក្នុងនោះសកម្មភាពសំខាន់ៗ រួមមាន៖

- ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការបង់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួងទេសចរណ៍ និងការគ្រប់គ្រងចំណូលទាំងស្រុងតាមប្រព័ន្ធបច្ចេកវិទ្យា NRMIS, E-payment និង CAMDx
- ការពង្រឹងសុក្រឹត្យភាពនៃការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធរបស់ក្រសួងទេសចរណ៍
- ការសម្រួលអនុលោមភាពបទដ្ឋានគតិយុត្តទាក់ទងនឹងការស្នើសុំអាជ្ញាបណ្ណទេសចរណ៍
- ការពង្រឹងសុក្រឹត្យភាពនៃការរៀបចំផែនការចំណាយតាមកម្មវិធីប្រចាំឆ្នាំ
- ការអនុវត្តការបើកប្រាក់បេសកកម្មក្នុង និងក្រៅប្រទេសរបស់មន្ត្រីរាជការតាមប្រព័ន្ធធនាគារ
- ការជំរុញការទូទាត់ថវិកាបុរេប្រទាន និងរដ្ឋទេយ្យបុរេប្រទានឱ្យមានប្រសិទ្ធភាព
- ការរៀបចំប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្មរបស់ក្រសួងទេសចរណ៍
- ការរៀបចំ និងអនុម័តផែនការលទ្ធកម្មឱ្យបានមុនឆ្នាំអនុវត្តថវិកា

- ការរៀបចំរបាយការណ៍នៃការអនុវត្តលទ្ធកម្មជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានទាន់ពេល
- ការបន្តប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ការរៀបចំប្រតិបត្តិថវិកាឱ្យបានទាន់ពេល
- ការរៀបចំរបាយការណ៍អនុវត្តថវិកាប្រចាំត្រីមាស ឆមាស និងឆ្នាំតាមប្រព័ន្ធបច្ចេកវិទ្យា FMIS
- ការបន្តពង្រឹងការស្នើសុំការចុះបញ្ជីបណ្ណសម្គាល់អចលនវត្ថុរបស់ក្រសួងទេសចរណ៍
- ការជំរុញការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានអង្គរ
- ការពង្រឹងការរៀបចំថវិកាដោយការញែកបន្ទុកបុគ្គលិកទៅតាមកម្មវិធីនីមួយៗ
- ការពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- ការបន្តជំរុញប្រសិទ្ធភាពនៃការអនុវត្តមុខងារអធិការកិច្ច និងការរៀបចំរបាយការណ៍
- ការរៀបចំរបាយការណ៍សវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន
- ការរៀបចំ និងកែលម្អផែនការសកម្មភាពសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ។

### ៣.៣. ការងារកំណែទម្រង់រដ្ឋបាលសាធារណៈ

- **ការងារវិភាគមុខងារនិងរចនាសម្ព័ន្ធ និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីរាជការស៊ីវិលរបស់ក្រសួង**

- បានបណ្តុះបណ្តាលមន្ត្រីជំនាញនៃមន្ទីរទេសចរណ៍រាជធានី ខេត្តនិងក្រសួងចំនួន ១៥០ នាក់ ស្តីពី "នីតិវិធីនៃការវិភាគមុខងារ និងរចនាសម្ព័ន្ធនិងធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការក្រសួងស្ថាប័ន" កាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤
- បានធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃដំណើរការពិនិត្យឡើងវិញ ការវិភាគមុខងារ និងរចនាសម្ព័ន្ធ និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីរាជការស៊ីវិល ប្រចាំខែ និងឆមាសទី១ ជូនក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈដើម្បីគាំទ្រវិស័យសេដ្ឋកិច្ចជាប្រចាំ
- ក្នុងនាមប្រធានលេខាធិការដ្ឋាន នៃក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងទេសចរណ៍ បានសហការសម្របសម្រួលជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងអង្គភាពទាំងអស់ក្រោមឱវាទក្រសួងទេសចរណ៍ ធ្វើការពិនិត្យឡើងវិញ និងវិភាគមុខងារនិងរចនាសម្ព័ន្ធ និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីរាជការស៊ីវិលរបស់ក្រសួង អគ្គនាយកដ្ឋាន ថ្នាក់ប្រហាក់ប្រហែល និងនាយកដ្ឋានរួចរាល់ និងបានរៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធ និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការឆមាសទី១ ឆ្នាំ២០២៤ របស់ក្រសួងទេសចរណ៍ តាមសេចក្តីណែនាំលេខ០១ សណន របស់រាជរដ្ឋាភិបាល។ ជាលទ្ធផលបឋម ផ្អែកតាមលទ្ធផលនៃការវិភាគ៖

**ក. មុខងារ**

| អង្គភាពអនុវត្តមុខងារ | មុខងារ | មុខងារបច្ចុប្បន្ន | មុខងារក្រោយវិភាគ |
|---|---|---|---|
| ក្រសួងទេសចរណ៍ | មុខងារគោល | ១៤ | ៣ |

| | | | | |
|---|---|---|---|---|
| អគ្គនាយដ្ឋាននិងថ្នាក់ប្រហាក់ប្រហែល | មុខងារ | គាំទ្រ | ២៨ | ១៨ |
| នាយកដ្ឋាននិងថ្នាក់ប្រហាក់ប្រហែល | | ជំនាញ | ១០៤ | ៣២ |

### ៣.៤. ការពង្រឹងយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

#### ក. ការងារនីតិកម្ម

❖ **ការងារកសាងលិខិតបទដ្ឋានគតិយុត្ត**

- បានសហការជាមួយអង្គភាពជំនាញកែសម្រួលអនុក្រឹត្យចំនួន ៣ រួមមាន៖
  - អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ក្នុងគោលដៅសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ពង្រឹង និងពង្រីកបទពិសោធនៃការអភិវឌ្ឍនិងភាពទាក់ទាញទេសចរណ៍ តាមរយៈការពង្រឹង និងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជាជំរុញកិច្ចសហការភាពជាដៃគូ និងការចូលរួមរវាងផ្នែកសាធារណៈនិងផ្នែកឯកជនក្នុងការធានាគុណភាពសេវាកម្ម និងផលិតផលទេសចរណ៍ក្នុងការផ្សព្វផ្សាយទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារទេសចរណ៍អន្តរជាតិ (ដាក់ឱ្យអនុវត្តដោយអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤)
  - អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ **ក្នុងគោលដៅជំរុញការអភិវឌ្ឍវិស័យទេសចរណ៍** (ដាក់ឱ្យអនុវត្តដោយអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤)
  - អនុក្រឹត្យស្តីពីការបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល (ខ្លឹមសារដើមគឺ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាវិជ្ជាជីវៈទេសចរណ៍ ដែលបានដាក់ឱ្យអនុវត្តកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ដោយអនុក្រឹត្យលេខ ១៤៨ អនក្រ.បក) រង់ចាំការពិនិត្យសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាក្រសួងអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ។
- បានបញ្ចប់សេចក្តីព្រាងប្រកាសចំនួន ៣ រួមមាន៖
  - ប្រកាសស្តីពីនីតិវិធីនិងលក្ខខណ្ឌក្នុងការពិន័យអន្តរការណ៍ ចំពោះបុគ្គលដែលល្មើសនឹងច្បាប់ស្តីពីទេសចរណ៍ ដោយសហការជាមួយអង្គភាពជំនាញរបស់ក្រសួងទេសចរណ៍ អនុលោមតាមមាត្រា ៦៣ នៃច្បាប់ស្តីពីទេសចរណ៍
  - ប្រកាសស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរទេសចរណ៍រាជធានី ខេត្ត ក្នុងការពិនិត្យ សម្រេចលើកិច្ចការនានាពាក់ព័ន្ធនឹងគម្រោងវិនិយោគ ក្នុងដែនសមត្ថកិច្ចរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត អនុលោមតាមអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

- ប្រកាសស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទទេសចរណ៍ អនុលោមតាមមាត្រា ៤៥ នៃច្បាប់ស្ដីពីទេសចរណ៍។

- បានសហការជាមួយអង្គភាពជំនាញរបស់ក្រសួងទេសចរណ៍ រៀបចំសេចក្ដីសម្រេចស្ដីពីការបង្កើតក្រុមការងារនានាចំនួន ១៧ និងបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់
- បាននិងកំពុងសិក្សាស្រាវជ្រាវផលប៉ះពាល់លើច្បាប់ស្ដីពីទេសចរណ៍ចំពោះសង្គម សេដ្ឋកិច្ច និងវប្បធម៌ ស្របតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១៣២ សសរ ចុះ២៦ ខែធ្នូ ឆ្នាំ២០១៦
- បានចូលរួមពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ និងអនុក្រឹត្យមួយចំនួនរបស់រាជរដ្ឋាភិបាលតាមការស្នើសុំរបស់ថ្នាក់ដឹកនាំ និងអង្គភាពជំនាញ
- បានបណ្ដុះបណ្ដាលមន្ត្រីជំនាញចំនួន ៩៥ នាក់ មកពីអង្គភាពទាំង ២១ ក្រោមចំណុះក្រសួង និងមន្ទីរទេសចរណ៍រាជធានី ខេត្តទាំង២៥ អំពីនីតិវិធីនៃការវាយតម្លៃផលប៉ះពាល់គតិយុត្ត។

❖ **ការងារផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

- បានផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទេសចរណ៍ថ្មីៗ ដែលរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តដល់មន្ត្រីជំនាញ និងប្រតិបត្តិករទេសចរណ៍ចំនួន ២៥០នាក់ នៅខេត្តសៀមរាប ក្នុងគោលដៅពង្រឹងការអនុវត្តច្បាប់និងពង្រឹងគុណភាពសេវាកម្មទេសចរណ៍ដើម្បីចូលរួមគាំទ្រយុទ្ធនាការទស្សនាសៀមរាបឆ្នាំ២០២៤
- បានផ្សព្វផ្សាយ និងចែកចាយកម្រងសម្រង់លិខិតបទដ្ឋានគតិយុត្តទេសចរណ៍ចំនួន ៤ កម្រង រួមមានៈ (១) កម្រងសម្រង់លិខិតបទដ្ឋានគតិយុត្តទេសចរណ៍ជាភាសាខ្មែរ ចិន អង់គ្លេស បារាំង ជប៉ុន កូរ៉េ និងភាសារុស្ស៊ី ឆ្នាំ២០២០ (២) កម្រងសម្រង់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងឧស្សាហកម្មទេសចរណ៍ ឆ្នាំ២០២១ (៣) កម្រងសម្រង់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានសុវត្ថិភាពទេសចរណ៍ ឆ្នាំ២០២១ និង(៤) កម្រងសម្រង់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងយន្តការស្ថាប័នទេសចរណ៍ ឆ្នាំ២០២២ កម្រងសម្រង់បទប្បញ្ញត្តិពាក់ព័ន្ធនឹងស្តង់ដាចំណាត់ថ្នាក់សេវាកម្មទេសចរណ៍ ភាគ១ ឆ្នាំ២០២៤ និងសន្ទានុក្រមទេសចរណ៍ ដល់ស្ថាប័ននីតិបញ្ញត្តិ (រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ) ក្រសួង ស្ថាប័ន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋបាលរាជធានី ខេត្ត មន្ទីរទេសចរណ៍រាជធានី ខេត្ត បណ្ណាល័យជាតិ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការជាតិ សមាគមទេសចរណ៍ សហព័ន្ធទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍ ចំនួន ៣ ០០០ ក្បាល
- បានចុះពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តទេសចរណ៍ នៅគោលដៅចំនួន ១៦ខេត្ត ដូចជាៈ ខេត្តមណ្ឌលគិរី ខេត្តរតនៈគិរី ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកោះកុង

- បានសហការជាមួយក្រុមការងារគ្រប់គ្រងគេហទំព័រផ្លូវការក្រសួងទេសចរណ៍ ដាក់បញ្ចូលអត្ថបទច្បាប់ចំនួន ២ ព្រះរាជក្រឹត្យចំនួន ១ អនុក្រឹត្យ១៧ ប្រកាសចំនួន៧០ សេចក្តីសម្រេចពាក់ព័ន្ធនឹងទេសចរណ៍ ក្នុងគេហទំព័រផ្លូវការក្រសួងទេសចរណ៍។

## ខ. អធិការកិច្ច

### ❖ ការងារអធិការកិច្ច

- បានចុះអធិការកិច្ចចំនួន ១៦ ខេត្ត រួមមាន៖ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តពោធិ៍សាត់ ខេត្តតាកែវ ខេត្តស្វាយរៀង ខេត្តកែប និង ខេត្តព្រៃវែង
- បានចុះអធិការកិច្ច ពិនិត្យលើមូលដ្ឋានអាជីវកម្មទេសចរណ៍ចំនួន ៤៣ ទីតាំង នៅរាជធានីភ្នំពេញ។

### ❖ ការងារទទួល និងដោះស្រាយបណ្តឹងទេសចរណ៍

- បានបញ្ចប់ដោយជោគជ័យករណីបណ្តឹងរបស់ក្រុមហ៊ុនជីហ្វ្រេងជីភែនីវីឡា ប្តឹងក្រុមហ៊ុនទេសចរណ៍ Focus Asia International
- បានសហការជាមួយមន្ទីរទេសចរណ៍ខេត្តសៀមរាប និងអង្គភាពពាក់ព័ន្ធ ដើម្បីសម្របសម្រួលវិវាទរវាងម្ចាស់សណ្ឋាគារ និងទីភ្នាក់ងារទេសចរណ៍ដែលជំពាក់បំណុលមុនកូវីដ-១៩
- បានចុះពិនិត្យលើការបញ្ចេញមតិរបស់ប្រជាពលរដ្ឋតាមបណ្តាញសង្គម អំពីការបំពាក់ហង្សស័ក លើទេវរូប ២អង្គ នៅប្រាសាទអង្គរវត្ត
- បានធ្វើការសម្របសម្រួល និងរកដំណោះស្រាយ ករណីវិវាទ រវាងទីភ្នាក់ងារទេសចរណ៍សកុណា ត្រាវែល (ខេមបូឌា) ឯ.ក ជាមួយប្រជាពលរដ្ឋរងគ្រោះ ដែលជាលទ្ធផលភាគីទាំងពីរ បានបន្តដោះស្រាយតាមនីតិវិធីតុលាការ

### ❖ ការងារតាមដានការអនុវត្តច្បាប់

- បានចុះណែនាំ និងប្រគល់លិខិតព្រមាន ចំពោះលោក ហៀក សេងហួត មគ្គុទ្ទេសក៍ទេសចរណ៍ភាសាអង់គ្លេស នៅមន្ទីរទេសចរណ៍ខេត្តសៀមរាប
- បានសហការជាមួយ ក្រសួងអធិការកិច្ច ដើម្បីចុះពិនិត្យ និងអង្កេតស្រាវជ្រាវករណីភាពមិនប្រក្រតីក្នុងការអភិវឌ្ឍទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចរបស់លោកស្រី ស៊ឹង សុខអាង នៅចំណុចជើងភ្នំ១៥០០ ក្នុងភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។

## គ. ការងារសវនកម្មផ្ទៃក្នុង

- បានចុះសវនកម្មលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ប្រសិទ្ធភាពប្រតិបត្តិការ ហិរញ្ញវត្ថុ អនុលោមភាព និងបច្ចេកវិទ្យាព័ត៌មាន និងតាមដានការអនុវត្តអនុសាសន៍សវនកម្មគ្រាមុនបានចំនួន ១៨ មន្ទីរទេសចរណ៍រាជធានី ខេត្ត និងនាយកដ្ឋានចំនួន ២
- បានធ្វើលិខិតជំរុញកែលម្អចំណុចខ្វះខាត របាយការណ៍បញ្ចប់សវនកម្ម និងបោះពុម្ព

ជាសៀវភៅរបាយការណ៍ផ្ញើជូនមន្ទីរទេសចរណ៍ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តកំពត ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តកែប ខេត្តប៉ៃលិន ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តតាកែវ នាយកដ្ឋានវិនិយោគទេសចរណ៍ និងនាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍

- បានរៀបចំតារាងព័ត៌មានសវនកម្មផ្ទៃក្នុង នៃក្រសួងទេសចរណ៍ សម្រាប់ឆ្នាំ២០២៤ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរៀបចំចងក្រងបោះពុម្ពសៀវភៅ ស្តីពីដំណើរការ និងនីតិវិធីសវនកម្មផ្ទៃក្នុង
- បានរៀបចំរបាយការណ៍សង្ខេបលទ្ធផលការងារចុះធ្វើសវនកម្មប្រចាំឆ្នាំ២០២៣ លើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង រួមមាន៖ គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងធនធានមនុស្ស គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ គ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ និងបច្ចេកវិទ្យាព័ត៌មាន និងតាមដានការអនុវត្តតាមអនុសាសន៍សវនកម្មគ្រាមុន
- សម្របសម្រួលរៀបចំធ្វើកិច្ចប្រជុំពិភាក្សាជាមួយអាជ្ញាធរសវនកម្មជាតិ ស្តីពីលទ្ធផលលើសេចក្តីព្រាងរបាយការណ៍សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៣
- បានរៀបចំរបាយការណ៍លទ្ធផលការងារលើការចុះធ្វើសវនកម្ម ឆ្នាំ២០២៤ លើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងតាមដានអនុសាសន៍សវនកម្មផ្ទៃក្នុងគ្រាមុន
- បានរៀបចំសរសេរផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងបីឆ្នាំ ២០២៥-២០២៧ និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២៥
- បានរៀបចំរបាយការណ៍វឌ្ឍនភាពសមិទ្ធកម្មប្រចាំឆ្នាំ២០២៤របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ គណនេយ្យភាពសមិទ្ធកម្ម។

## ៤. យន្តការគាំទ្រវិស័យទេសចរណ៍

### ៤.១.គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

- បានរៀបចំកែសម្រួលសមាសភាពថ្នាក់ដឹកនាំរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ សម្រាប់អាណត្តិទី៧ និងបានរៀបចំសេចក្តីសម្រេច (គ.ជ.អ.ទ.) ថ្នាក់រាជធានី-ខេត្តចំនួន ១៧ និងបានរៀបចំកិច្ចប្រជុំលើកទី១ គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ សម្រាប់រាជរដ្ឋាភិបាល នីតិកាល ទី៧ នៃរដ្ឋសភា។

### ៤.២. គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

- បានរៀបចំសេចក្តីសម្រេចក្រុមការងារស្តីពីការកែសម្រួលសមាសភាព និងភារកិច្ចរបស់ក្រុមការងារវាយតម្លៃទីក្រុងស្អាតចំនួន១៧ រាជធានី-ខេត្ត រួមមាន៖ ខេត្តកែប ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តប៉ៃលិន ខេត្តសៀមរាប ខេត្តកោះកុង ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង ខេត្តក្រចេះ ខេត្តកំពង់ស្ពឺ ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង

ខេត្តកណ្តាល ខេត្តព្រះវិហារ និងខេត្តកំពង់ឆ្នាំង

- បានស្នើសុំការអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់បំផុតពីរាជរដ្ឋាភិបាល ដើម្បីជ្រើសរើសទីក្រុង ចំនួន ៣ ជាជ័យលាភីទីក្រុងទេសចរណ៍ស្អាតអាស៊ាន លើកទី៤ ឆ្នាំ២០២២-២០២៤ រួមមាន៖ (១) ខណ្ឌដូនពេញ (២) ទីក្រុងកែប និង(៣) ទីក្រុងកំពត ជាជ័យលាភីទីក្រុងទេសចរណ៍ស្អាតអាស៊ាន លើកទី៤
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ អមដោយវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាទីក្រុងស្អាត" ចំនួន ៣ លើក នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ ដែលមានសិក្ខាកាមសរុប ៣៦៣ នាក់
- បានចុះវាយតម្លៃភូមិទេសចរណ៍ឆ្នើមចំនួន ៩ភូមិ ដើម្បីចូលរួមប្រឡងប្រណាំងភូមិទេសចរណ៍ឆ្នើមអាស៊ានឆ្នាំ២០២៤
- បានរៀបចំសិក្ខាសាលាស្តីពី ចលនាប្រឡងប្រណាំងបង្គន់សាធារណៈអាស៊ាន លើកទី៣ នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមសរុប ១៥០ នាក់
- បានចុះពិនិត្យ និងវាយតម្លៃបេក្ខភាព ដាក់ពាក្យចូលរួមប្រឡងប្រណាំងបង្គន់សាធារណៈអាស៊ាន លើកទី៣ ចំនួន ៧ ទីតាំង
- បានរៀបចំប្រឡងប្រណាំង "ទីក្រុងដែលមានពិធីបុណ្យចូលឆ្នាំសកលល្អជាងគេប្រចាំឆ្នាំ" (Best Countdown City of the year 2023) ក្នុងនោះមានជ័យលាភី ចំនួន ០៣ រួមមាន៖ (១) ខេត្តព្រះសីហនុ (២) ខេត្តបាត់ដំបង និង(៣) ខេត្តសៀមរាប
- បានរៀបចំចុះផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីអនាម័យ បរិស្ថាន និងការទុកដាក់សំណល់រឹងនៅឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានចំនួន ០៤ ទីតាំងមាន៖ (១) វិទ្យាល័យ ហ៊ុនសែនក្រវ៉ា (២) វត្តខេមរាម (វត្តក្រវ៉ា) (៣) ផ្សារក្រវ៉ា និង(៤) សាលាឃុំក្រវ៉ា ដែលមានសមាសភាពចូលរួមសរុបចំនួន ៤៣៦នាក់
- បានប្រគល់វិញ្ញាបនបត្រពានរង្វាន់ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន លើកទី៤ ដែលមានសុពលភាព ឆ្នាំ២០២២-២០២៤ ដល់ជ័យលាភីទីក្រុងទេសចរណ៍ស្អាតអាស៊ាន រួមមាន៖ (១) ខណ្ឌដូនពេញ (២) ទីក្រុងកែប និង(៣) ទីក្រុងកំពត
- បានរៀបចំយុទ្ធនាការ "យុវជន និងទីក្រុងស្អាត" ដើម្បីបញ្ជ្រាបការយល់ដឹងអំពីអនាម័យភាពស្អាតដល់អាជីវករ និងប្រជាពលរដ្ឋ ក្នុងគោលដៅទាក់ទាញទេសចរណ៍ក្នុងខេត្ត ចំនួន ៤ រួមមាន៖ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពត និងខេត្តកោះកុង ដែលមានអ្នកចូលរួមសរុប ១៤៦ នាក់
- បានរៀបចំយុទ្ធនាការ " **កម្ពុជាស្អាត កម្ពុជាបៃតង** " ដើម្បីអបអរសាទរពិធីបុណ្យទន្លេ លើកទី៨ ក្រោមប្រធានបទ "ទន្លេដើម្បីសន្តិភាព និងការអភិវឌ្ឍ" នៅខេត្តសៀមរាប និងដើម្បីបង្កើនភាពទាក់ទាញគោលដៅទេសចរណ៍នៅតំបន់ទេសចរណ៍កោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង

- បានរៀបចំសកម្មភាពលើកកម្ពស់ភាពស្អាត អនាម័យ និងបៃតងដើម្បីអបអរសាទរពិធីបុណ្យសមុទ្រលើកទី១១ ក្រោមប្រធានបទ៖ **"អបអរបេតិកភណ្ឌ និងចីរភាពនៃតំបន់ឆ្នេរ"** នៅខេត្តកំពត
- បានសហការរៀបចំទិវាសម្អាតពិភពលោកលើកទី៧ ឆ្នាំ ២០២៤ ជាមួយអង្គការ River Ocean Cleanup នៅតាមបណ្តារាជធានី ខេត្តនីមួយៗ។

## ៤.៣. ការសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរតាមច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិ

- លើកកម្ពស់គុណភាពការធ្វើដំណើររបស់ភ្ញៀវទេសចរ តាមរយៈកិច្ចប្រជុំពេញអង្គរបស់គណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស ដើម្បីពិនិត្យរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធលើស្ថានភាពនៃការសម្រួលការធ្វើដំណើរ ព្រមទាំងលើកឡើងពីបញ្ហាអសកម្មនានា ក្នុងគោលបំណងផ្តល់ជាគំនិត និងដំណោះស្រាយដើម្បីជានាបានបទពិសោធល្អដល់ភ្ញៀវទេសចរក្នុងពេលធ្វើដំណើរឆ្លងកាត់ព្រំដែនក៏ដូចជាចូលមកទស្សនានៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយភាពងាយស្រួល សុវត្ថិភាព មានភាពកក់ក្តៅ និងជឿទុកចិត្ត
- បានពង្រឹងសមត្ថភាពការធ្វើបដិសណ្ឋារកិច្ចទទួលស្វាគមន៍ទេសចរនៅតាមច្រកទ្វារមួយចំនួន ដូចជា៖ អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ខេត្តសៀមរាប និងច្រកទ្វារព្រំដែនអន្តរជាតិ "ដូង" និង "ដី" ខេត្តបាត់ដំបង ដើម្បីជំរុញឱ្យមានការចូលរួមទាំងអស់គ្នាក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរ និងចាត់ទុកភ្ញៀវទេសចរជាភ្ញៀវរបស់យើងទាំងអស់គ្នា
- សម្របសម្រួលជាមួយភាគីពាក់ព័ន្ធលើការចូលចតនាវាទេសចរណ៍ខ្នាតធំក្នុងគោលបំណងប្រែក្លាយកម្ពុជាជាគោលដៅសំចតនាវាទេសចរណ៍ខ្នាតធំដ៏ពេញនិយមមួយនៅក្នុងតំបន់។

## ៤.៤. គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ តាមរយៈអនុក្រឹត្យលេខ ១២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ដោយមានរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ជាប្រធាន រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាអនុប្រធានអចិន្ត្រៃយ៍ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអនុប្រធាន និងបានអនុម័តដាក់ឱ្យប្រើប្រាស់គោលនយោបាយជាតិអេកូទេសចរណ៍ (ឆ្នាំ២០១៩-២០៣០) កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។

ជាលទ្ធផលនៃវេទិកាជាតិ លើកទី៣ កន្លងមក រាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍កំណត់ជាតំបន់អេកូទេសចរណ៍អាទិភាពថ្នាក់ជាតិ ចំនួន ៦ រួមមាន៖ (១) តំបន់អេកូទេសចរណ៍នៅឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម "ភ្នំគូលែន" (២) តំបន់អេកូទេសចរណ៍ទេសភាពជួរភ្នំក្រវ៉ាញ (៣) តំបន់អេកូទេសចរណ៍ឆ្នេរ (៤) តំបន់អេកូទេសចរណ៍ឋាបនីយជីវៈមណ្ឌលបឹងទន្លេសាប (៥) តំបន់អេកូទេសចរណ៍ព្រៃឡង់ និង(៦) តំបន់អេកូទេសចរណ៍ភូមិភាគឦសាន។

គណៈកម្មាធិការជាតិ គ.ជ.អ.អ បានបណ្តុះបណ្តាលដល់សមាជិកសហគមន៍ជាង ៥ ០០០ នាក់ មកពីសហគមន៍ជាង ៩០ នៅទូទាំងប្រទេស លើជំនាញចាំបាច់នានាដូចជាជំនាញទេសចរណ៍ បដិសណ្ឋារកិច្ច ជំនាញចុងភៅ និងការគ្រប់គ្រងសហគមន៍ ជាដើម។

គណៈកម្មាធិការជាតិ គ.ជ.អ.អ បានរៀបចំកម្មវិធីសំខាន់ៗ រួមមានៈ

- រៀបចំកម្មវិធីសំណេះសំណាលសួរសុខទុក្ខ ជាមួយសមាជិក សមាជិកាសហគមន៍ទេសចរណ៍ធម្មជាតិកំពង់ភ្លុក និងសមាគមកាណូតដឹកភ្ញៀវទេសចរចុងឃ្នៀស មានប្រជាសហគមន៍សរុប ៣០០ នាក់ ខេត្តសៀមរាប ក្រោមអធិបតីភាពរបស់ **ឯកឧត្តមរដ្ឋមន្ត្រី និងជាប្រធាន គ.ជ.អ.អ**
- រៀបចំដំណើរទស្សនកិច្ចជូន **ឯកឧត្តមរដ្ឋមន្ត្រី និងជាប្រធានគ.ជ.អ.អ** រួមជាមួយថ្នាក់ដឹកនាំក្រសួងទេសចរណ៍ ទៅកាន់តំបន់សក្តានុពលទេសចរណ៍វប្បធម៌ ធម្មជាតិ និងអេកូទេសចរណ៍ នៅក្នុងខេត្តសៀមរាប ចំនួន ៣ ទីតាំង រួមមានៈ
    - មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ស្ថិតនៅឃុំត្បែង និងឃុំឃុនរាម ស្រុកបន្ទាយស្រី
    - ឧទ្យានជាតិព្រះជ័យវរ្ម័នរោត្តម "ភ្នំគូលែន" ស្ថិតនៅស្រុកស្វាយលើ
    - សហគមន៍ទេសចរណ៍បឹងឈូកបន្ទាយស្រី ស្ថិតនៅភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប
- រៀបចំវគ្គបណ្តុះបណ្តាលជូនសហគមន៍ ដែលត្រូវបានទទួលស្គាល់ជាសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ចំនួន ២២ សហគមន៍ ដែលមានប្រមាណសរុបចំនួនជាង ៨០០ នាក់
- រៀបចំវគ្គបណ្តុះបណ្តាលលើជំនាញ "មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍" ជូនសមាជិក សមាជិកា សហគមន៍ទេសចរណ៍កែច្នៃវត្ថុអនុស្សាវរីយ៍កំពង់រលឹងចំនួន ៦២ នាក់ ស្ត្រី ៤៣ នាក់ ស្ថិតនៅភូមិកំពង់រលឹង សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម
- រៀបចំកិច្ចប្រជុំស្តីពី "ការធ្វើបច្ចុប្បន្នភាពសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ទូទាំងប្រទេស"
- រៀបចំកិច្ចប្រជុំស្តីពី "ការសិក្សា និងវាយតម្លៃបឋមលើលទ្ធភាពក្នុងការកំណត់គោលដៅសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ នៅតាមបណ្តាសហគមន៍ដែលមានសក្តានុពលសម្រាប់ការថតខ្សែភាពយន្ត"
- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងស្តីពី "ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ នៅសហគមន៍ទេសចរណ៍ធម្មជាតិកំពង់ភ្លុក" ស្ថិតនៅភូមិគោកក្តុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង នៅខេត្តសៀមរាប
- បានចុះធ្វើការវាយតម្លៃបេក្ខភាពជ័យលាភីស្តង់ដាសហគមន៍ទេសចរណ៍អាស៊ាន (ASEAN Community -Based Tourism Standard) លើកទី៤ ឆ្នាំ២០២៥-២០២៦ និងស្តង់ដាផ្ទះស្នាក់អាស៊ាន (ASEAN Homestay Standard) លើកទី៥ ឆ្នាំ២០២៥-២០២៧ ចំនួន ២០ ទីតាំង ក្នុងនោះរួមមានសហគមន៍ទេសចរណ៍ចំនួន ១៤ ទីតាំង និងផ្ទះស្នាក់

សហគមន៍ចំនួនទីកន្លែងសម្រាប់ប្រទេសសមាជិកអាស៊ាន ដែលនឹងចែកជ័យលាភី នាឱកាសវេទិកាទេសចរណ៍ (ATF) លើកទី៤៣ នាអំឡុងខែមករា ឆ្នាំ២០២៥ នៅទីក្រុង Johor ប្រទេសម៉ាឡេស៊ី។

## ៤.៥. ការងារវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យទេសចរណ៍

- បានរៀបចំសេចក្តីសម្រេចរួម រវាងក្រសួងទេសចរណ៍ និង គ.ជ.អ.ប ស្តីពីផែនការសកម្មភាព និងថវិកា ឆ្នាំ២០២៤ ជូនលេខាធិការដ្ឋានគ.ជ.អ.ប
- បានសេចក្តីព្រាងផែនការសកម្មភាព និងថវិកា ឆ្នាំ២០២៥ របស់គណៈកម្មការដឹកនាំការងារវិមជ្ឈការ និងវិសហមជ្ឈការក្រសួងទេសចរណ៍ ជូនលេខាធិការដ្ឋានគ.ជ.អ.ប
- បានរៀបចំសិក្ខាសាលាស្តីពីការពិនិត្យការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅខេត្តគោលដៅចំនួន ២ លើក គឺ នៅខេត្តកំពង់ចាម មានសិក្ខាកាមសរុបចំនួន ១២៥ នាក់ ស្រី ៣០ នាក់ និងនៅខេត្តកំពត មានសិក្ខាកាមចូលរួមសរុបចំនួន ១៣០ នាក់ ស្រី ៤២ នាក់
- បានចុះទៅពិនិត្យ និងគាំទ្រលក្ខណៈបច្ចេកទេសដល់មន្ត្រីអង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលខេត្ត មន្ត្រីការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ត្រីនៅមន្ទីរទេសចរណ៍ខេត្តមួយចំនួន ដើម្បីពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យទេសចរណ៍ ឱ្យស្របតាមប្រកាស និងសេចក្តីណែនាំរបស់ក្រសួងទេសចរណ៍។

## ៤.៦. ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងវិស័យទេសចរណ៍ និងបរិស្ថានគ្មានផ្សែងបារី

- បានរៀបចំសិក្ខាសាលា និងចុះផ្សព្វផ្សាយពីសភាពការណ៍គ្រឿងញៀន ដល់ប្រតិបត្តិករទេសចរណ៍ មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ ដោយមានអ្នកចូលរួមចំនួន **៤ ១០៨ នាក់ ស្រី ២៣១ នាក់**
- បានចេញសេចក្តីណែនាំ លេខ ១៩២ សជណ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការបន្តពង្រឹងការអនុវត្តសេចក្តីណែនាំ លេខ ០០៩ សណន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ លើការប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងវិស័យទេសចរណ៍ និងសេចក្តីជូនដំណឹងលេខ ២៦៣ សជណ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ "**NoDrug**" ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យាក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍រាជធានីខេត្ត និងសមាគមឧស្សាហកម្មទេសចរណ៍
- បានសហការជាមួយមន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនធ្វើតេស្តរហ័សរកសារធាតុញៀនប្រភេទមេតំហ្វេតាមីនតាមទឹកមូត្រជូនថ្នាក់ដឹកនាំ ទីប្រឹក្សា មន្ត្រីរាជការ ជំនួយការ និងមន្ត្រីជាប់កិច្ចសន្យាក្រសួងទេសចរណ៍ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ សរុបចំនួន ៧៦១ នាក់ ជាលទ្ធផល អវិជ្ជមានទាំងអស់

- បានសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រៀបចំស្តង់ពិព័រណ៍ និងចែកខិត្តបណ្ណផ្សព្វផ្សាយ អប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀនជូនដល់ភ្ញៀវដែលបានអញ្ជើញចូលរួមក្នុងពិធីបុណ្យទន្លេ លើកទី៨ នៅខេត្តសៀមរាប និងពិធីបុណ្យសមុទ្រ លើកទី១១ នៅខេត្តកំពត
- បានសហការជាមួយរដ្ឋបាលខេត្តកំពង់ចាម និងខេត្តបាត់ដំបង ដើម្បីរៀបចំក្រុងកំពង់ចាម និងក្រុងបាត់ដំបង ជាទីក្រុងទេសចរណ៍គ្មានផ្សែងបារី ក្នុងគោលបំណងចូលរួមអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ និងការពារសុវត្ថិភាព និងសុខភាពទេសចរពីផលប៉ះពាល់នៃផ្សែងបារី ព្រមទាំងចូលរួមប្រែក្លាយទីក្រុងទេសចរណ៍ជាគោលដៅទេសចរណ៍កាន់តែមានភាពទាក់ទាញ ស្អាត និងមានសុវត្ថិភាព។ ពិធីប្រកាសជាផ្លូវការ "ទីក្រុងទេសចរណ៍គ្មានផ្សែងបារី" នៅក្រុងកំពង់ចាម និងក្រុងបាត់ដំបង ត្រូវបានប្រារព្ធធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍**
- លើកកម្ពស់ស្មារតីកីឡាគ្មានថ្នាំជក់ តាមរយៈកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំគោលការណ៍ណែនាំស្តីពី "កីឡាគ្មានថ្នាំជក់" ក្នុងគោលបំណងជំរុញភាពទាក់ទាញ និងពង្រឹងទំនាក់ទំនងរវាងវិស័យកីឡា និងវិស័យទេសចរណ៍ ដោយឈរលើទស្សនទាន "កីឡាគាំទ្រទេសចរណ៍ ទេសចរណ៍គាំទ្រកីឡា"
- ការអនុវត្តសកម្មភាពបរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍ស្របតាម WHO FCTC និងមានការកោតសរសើរពីសម្ព័ន្ធត្រួតពិនិត្យថ្នាំជក់អាស៊ីអាគ្នេយ៍ (SEATCA) ដែលមានការិយាល័យនៅប្រទេសថៃដោយបានផ្តល់ពាន "Tobacco Control Champion Award" ជូនក្រសួងទេសចរណ៍ ដែលក្នុងនោះមានប្រទេសចំនួនពីរប៉ុណ្ណោះបានទទួលពាននេះគឺ ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រថៃ។ នេះជាលើកទី២ ដែលក្រសួងទេសចរណ៍បានទទួលពានសរសើរពីអង្គការអន្តរជាតិ ជាក់ស្តែង កាលពីឆ្នាំ២០២២ ក្រសួងទេសចរណ៍ក៏បានទទួលពាន "ទិវាពិភពលោកគ្មានថ្នាំជក់" ពីអង្គការសុខភាពពិភពលោកផងដែរ
- បានចែករំលែកបទពិសោធជោគជ័យ ក្នុងការអនុវត្តបរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍តាមរយៈការចូលរួមធ្វើជាវាគ្មិនពីសំណាក់**ឯកឧត្តម ហោ សារុន រដ្ឋលេខាធិការក្រសួងទេសចរណ៍** នៅក្នុងពិធីអបអរសាទរទិវាពិភពលោកគ្មានថ្នាំជក់លើប្រធានបទស្តីពី "កិច្ចការពារកុមារពីផលិតផលថ្នាំជក់ និងបារីអេឡិចត្រូនិក" និងនៅក្នុងពិធី Webinar អន្តរជាតិ លើប្រធានបទស្តីពី "ការអនុវត្តច្បាប់ និងបរិស្ថានគ្មានផ្សែងបារីដោយជោគជ័យ"
- បានរៀបចំ និងដាក់ឱ្យអនុវត្តសេចក្តីណែនាំលេខ ០១៣ សណន ស្តីពី "ការពង្រឹងការអនុវត្តបរិស្ថានគ្មានផ្សែងផលិតផលថ្នាំជក់ និងវិធានការហាមឃាត់ចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍" របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ដើម្បីបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព និងធានាបានទេសចរណ៍ស្អាត មានសុវត្ថិភាព មិនប៉ះពាល់ដល់សុខភាពដោយសារផលិតផលថ្នាំជក់។

### ៤.៧. ការងារសុវត្ថិភាពកុមារ ជំងឺអេដស៍ និងសកម្មភាពជនមានពិការភាព

- បង្កើនការយល់ដឹងលើក្រមសីលធម៌ការពារសុវត្ថិភាពកុមារ ជៀសវាងពាក់ព័ន្ធការកេងប្រវ័ញ្ច ការជួញដូរកម្លាំងពលកម្ម និងផ្លូវភេទកុមារ និងលើកកម្ពស់សិទ្ធិជនមានពិការភាពដែលត្រូវបានការពារដោយច្បាប់ និងជំរុញឱ្យមានការផ្តល់ឱកាសការងារដល់ជនមានពិការភាព នៅក្នុងចំណោមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍នៅខេត្តកំពត ខេត្តកំពង់ស្ពឺ និងខេត្តឧត្តរមានជ័យ
- បានចូលរួមផ្សព្វផ្សាយ និងអនុវត្តសូចនាករដែលក្រសួងទេសចរណ៍ត្រូវបំពេញស្របតាម "គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨" របស់រាជរដ្ឋាភិបាល
- បានចូលរួមលើកកម្ពស់ការយល់ដឹងពីស្ថានភាពនិងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ក្នុងវិស័យទេសចរណ៍នៅខេត្តបាត់ដំបង ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដើម្បីចូលរួមចំណែកបញ្ចប់អេដស៍នៅកម្ពុជាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសកម្មភាពយុទ្ធសាស្ត្ររបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

### ៤.៨. ការងារនារី និងយេនឌ័រក្នុងវិស័យទេសចរណ៍

❖ **ស្ថានភាពស្ត្រីក្នុងវិស័យទេសចរណ៍**

- បច្ចុប្បន្ន ក្រសួងមានមន្ត្រីរាជការសរុបចំនួន ១ ១៧៦ នាក់ (ស្ត្រី ៤១៤ នាក់ ស្មើនឹង ៣៥,២០%) និងមន្ត្រីជាប់កិច្ចសន្យាចំនួន ៥៤៥ នាក់ (ស្ត្រី ៣៧៧ នាក់ ស្មើនឹង ៦៩,១៧%)
    - នៅទីស្តីការក្រសួង មានមន្ត្រីចំនួន ៦៦៧ នាក់ (ស្ត្រី ២២២ នាក់ ស្មើនឹង ៣៣,២៨%) និងមន្ត្រីជាប់កិច្ចសន្យាចំនួន ២៤៥ នាក់ (ស្ត្រី ២២១ នាក់ ស្មើនឹង ៨៨,៤០%)
    - នៅមន្ទីរទេសចរណ៍រាជធានី-ខេត្ត មានមន្ត្រីរាជការក្នុងក្របខ័ណ្ឌចំនួន ៥០៩ នាក់ (ស្ត្រី ១៩២ នាក់ ស្មើនឹង ៣៧,៧២%) និងមន្ត្រីជាប់កិច្ចសន្យាចំនួន ៣០០ នាក់ (ស្ត្រី ១៥៦ នាក់ ស្មើនឹង ៥២,៨៨%)។ ក្នុងចំណោមមន្ត្រីនារីទាំង ៤១៤ នាក់ មានមុខតំណែងចាប់ពីរដ្ឋលេខាធិការ រហូតដល់អនុប្រធានការិយាល័យ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ មានចំនួន ៣២០ នាក់ ស្មើនឹង ៧៦% នៃចំនួនមន្ត្រីជាស្ត្រីសរុប មន្ត្រីមានពិការភាពមានចំនួន ២៦ នាក់ (ស្ត្រី ១១ នាក់) ស្មើនឹង ១,៥% នៃមន្ត្រីរាជការសរុប
- ដោយឡែក កម្លាំងពលកម្មជាស្ត្រីក្នុងវិស័យទេសចរណ៍ មានប្រមាណជិត៦០% នៃកម្លាំងពលកម្មសរុប ដោយស្ត្រីមានវត្តមាននៅគ្រប់សេវាកម្មទាំងអស់នៃវិស័យទេសចរណ៍។

❖ **ការបើកវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយអប់រំ**

➢ **ការបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

ក្រសួងទេសចរណ៍ បានចូលរួមអនុវត្តដោយការទទួលខុសត្រូវ ស្របតាមផែនការយុទ្ធសាស្ត្រលើកកម្ពស់យេនឌ័រក្នុងវិស័យទេសចរណ៍ ដំណាក់កាលទី៤ ឆ្នាំ២០២០-២០២៤ សំដៅចូលរួមអភិវឌ្ឍន៍ធនធានមនុស្ស ដោយផ្តោតសំខាន់លើការអប់រំបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្ត្រីទាំងក្នុងវិស័យរដ្ឋនិងឯកជនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០២៤ នេះ ក្រុមការងារយេនឌ័រដែលជាសេនាធិការរបស់ក្រសួង

បានអនុវត្តកម្មវិធីពង្រឹងសមត្ថភាពស្ត្រី និងអ្នកពាក់ព័ន្ធ ដោយបានបើកវគ្គបណ្តុះបណ្តាលចំនួន ៤ លើក នៅខេត្តកំពត ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល ដែលមានអ្នកចូលរួមសរុបចំនួន ៣២៧ នាក់ ក្នុងនោះស្ត្រី ២០៥ នាក់ ស្មើនឹង ៦៣% ។

➢ **សិក្ខាសាលាផ្សព្វផ្សាយអប់រំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ**

ក្រសួងទេសចរណ៍ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអប់រំចំនួន ៦ លើក នៅខេត្តតាកែវ ខេត្តក្រចេះ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម និងខេត្តព្រៃវែង ដែលមានអ្នកចូលរួមសរុបចំនួន ៦២៩ នាក់ ក្នុងនោះស្ត្រីចំនួន ៤០៨ នាក់ ស្មើនឹង ៦៤,៨៦% ដោយផ្តោតលើប្រធានបទស្តីពី "ការលើកកម្ពស់សីលធម៌សង្គម និងតម្លៃស្ត្រីក្នុងវិស័យទេសចរណ៍" "ការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យទេសចរណ៍" "ស្ត្រី និងការអភិវឌ្ឍបៃតងក្នុងវិស័យទេសចរណ៍" និង "ការលើកកម្ពស់សិទ្ធិ តួនាទី និងតម្លៃស្ត្រីក្នុងវិស័យទេសចរណ៍"។

➢ **សកម្មភាពស្ត្រី និងទីក្រុងស្អាត**

ក្រុមការងារ បានសហការជាមួយមន្ទីរទេសចរណ៍រាជធានី-ខេត្ត ផ្សព្វផ្សាយពីការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពទីក្រុងស្អាត ការថែរក្សាអនាម័យ សោភណភាព និងពង្រឹងគុណភាពផលិតផល ក៏ដូចជាសេវាកម្មក្នុងវិស័យទេសចរណ៍ឱ្យកាន់តែប្រសើរឡើងទៀត។ នៅក្នុងសកម្មភាពទីក្រុងស្អាត ស្ត្រីមានការពាក់ព័ន្ធជាសារវន្ត ដោយសារស្ត្រីភាគច្រើនជាអ្នកបម្រើការផ្ទាល់នៅនឹងកន្លែងបន្ទប់ទឹក ផ្ទះបាយ ឬកន្លែងចម្អិនម្ហូបអាហារ ស្ត្រីជាអ្នកដើរផ្សារ ជាអ្នកបោសជូតសម្អាត និងជាអ្នកអប់រំកូនចៅនៅក្នុងគ្រួសារ ដែលការងារទាំងនេះជះឥទ្ធិពលទៅនឹងបរិស្ថាន អនាម័យទីក្រុង តាមរយៈការវេចខ្ចប់ទុកដាក់សំរាម ការប្រើប្រាស់ថង់ប្លាស្ទិក និងផលិតផលក្នុងស្រុក។

➢ **ការចងក្រងក្រុមនារីឯកជនក្នុងវិស័យទេសចរណ៍**

ការពង្រីកបណ្តាញស្ត្រីក្នុងវិស័យទេសចរណ៍ តាមរយៈការចងក្រងក្រុមនារីឯកជនត្រូវបានធ្វើឡើងនៅគ្រប់គោលដៅរាជធានី-ខេត្ត ក្នុងគោលបំណងដើម្បីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង ការចែករំលែកបទពិសោធ និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើងចំពោះស្ត្រី។ គិតត្រឹមឆ្នាំ២០២៤នេះ ក្រុមនារីឯកជនក្នុងវិស័យទេសចរណ៍នៅទូទាំងប្រទេសមានចំនួន ៩៨១ ក្រុម ស្មើនឹង ១២ ០៩៣ នាក់។ ជាធម្មតាចំនួនក្រុមនារីឯកជនតែងមានការប្រែប្រួល អាស្រ័យដោយការបើកបិទអាជីវកម្មទេសចរណ៍នៅតាមគោលដៅរាជធានី-ខេត្ត ការបម្លាស់ទីការងារ និងការផ្លាស់ប្តូរការងាររបស់បុគ្គលិកជាស្ត្រី។

➢ **ការចុះជួបក្រុមនារីនៅតាមមូលដ្ឋានអាជីវកម្ម**

ក្រុមការងារទាំងពីរបានសហការជាមួយមន្ទីរទេសចរណ៍រាជធានី-ខេត្ត ចុះជួបសំណេះសំណាលសួរសុខទុក្ខក្រុមនារីតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ នៅខេត្តគោលដៅចំនួន ៤ រួមមាន៖ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងខេត្តព្រៃវែង។ គោលបំណងនៃការចុះជួបនេះគឺដើម្បី៖ (១) បង្កើនទំនាក់ទំនងល្អរវាងស្ត្រីក្នុងវិស័យរដ្ឋ និងឯកជន (២) ពង្រឹងអនាម័យ សេវាកម្ម និងបដិសណ្ឋារកិច្ច (៣) ពង្រឹងសីលធម៌សង្គម និងតម្លៃស្ត្រីក្នុងវិស័យទេសចរណ៍ និង(៤) ដើម្បីដឹងពីស្ថានភាពសុខទុក្ខសំដៅជួយដំណោះស្រាយបញ្ហាប្រឈមនានា។

### ៤.៩. ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងវិស័យទេសចរណ៍

- បានផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល ដល់មន្ទីរទេសចរណ៍រាជធានី ខេត្ត និងផែនការសកម្មភាពគន្លឹះរបស់ក្រសួងទេសចរណ៍ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងវិស័យទេសចរណ៍ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រជាតិ
- បានចេញសេចក្តីណែនាំដល់មន្ទីរទេសចរណ៍រាជធានី ខេត្ត និងម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ស្តីពីការផ្តល់របបថែទាំសុខភាពប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល (ម.ស.ស.) សម្រាប់បុគ្គលិកបម្រើការនៅតាមអាជីវកម្មសេវាកម្សាន្ត (ក្លឹបកម្សាន្ត ខារ៉ាអូខេ រង្គសាល-ឌីស្កូតែក និងបៀរហ្គាឌិន) នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យរៀបចំបញ្ជីឈ្មោះបុគ្គលិកបម្រើការសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតាមអាជីវកម្មរបស់ខ្លួន ដើម្បីស្នើសុំបណ្ណមូលនិធិសមធម៌សុខាភិបាល (ម.ស.ស.)
- បានផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគិតគូរយកចិត្តទុកដាក់ផ្តល់អត្ថប្រយោជន៍សង្គមដល់បុគ្គលិកបម្រើការសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតាមអាជីវកម្មក្លឹបកម្សាន្ត ខារ៉ាអូខេ រង្គសាល-ឌីស្កូតែក បៀរហ្គាឌិន និងម៉ាស្សា-ស្ប៉ា តាមរយៈកិច្ចប្រជុំស្តីពី "ការពង្រឹងសមត្ថភាពក្នុងវិស័យទេសចរណ៍" និងបានចុះសំណេះសំណាលផ្ទាល់ដល់មូលដ្ឋានអាជីវកម្មសេវាកម្សាន្តទេសចរណ៍មនុស្សពេញវ័យជាមួយម្ចាស់អាជីវកម្ម និងបុគ្គលិកបម្រើការនៅតាមរាជធានី ខេត្តគោលដៅមួយចំនួន
- បានសិក្សាស្រាវជ្រាវបន្ថែមនៅតាមមូលដ្ឋានអាជីវកម្ម ដើម្បីប្រមូលទិន្នន័យស្ថិតិអាជីវកម្ម ស្ថិតិបុគ្គលិកបម្រើការសេដ្ឋកិច្ចក្រៅប្រព័ន្ធ បញ្ហាប្រឈម និងសំណូមពរជាមួយមន្ទីរទេសចរណ៍ រាជធានី ខេត្ត និងម្ចាស់អាជីវកម្មក្លឹបកម្សាន្ត ខារ៉ាអូខេ រង្គសាល-ឌីស្កូតែក និងបៀរហ្គាឌិន ដើម្បីទទួលបានធាតុចូលក្នុងការត្រៀមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងវិស័យទេសចរណ៍ប្រកបដោយចីរភាព បរិយាបន្ន ភាពរឹងមាំ និងភាពធន់ទៅនឹងវិបត្តិ
- ក្រោយរាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការចុះឈ្មោះតាមថ្នាលឌីជីថលអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងនោះវិស័យទេសចរណ៍ (សេវាកម្មស្នាក់នៅ និងម្ហូបអាហារ ដែលមានចំនួន ៩៦ ៣១៥ សហគ្រាស) បានចុះឈ្មោះក្នុងថ្នាលចំនួន ១២,២%
- បានរៀបចំផែនការសកម្មភាពការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងវិស័យទេសចរណ៍សម្រាប់ឆ្នាំ២០២៥ ក្នុងក្របខណ្ឌក្រសួងទេសចរណ៍
- បានរៀបចំផែនការសកម្មភាពគន្លឹះជាអាទិភាពការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងវិស័យទេសចរណ៍រយៈពេលវែង (ឆ្នាំ២០២៥-២០២៨) ឆ្លើយតបទៅនឹងវិធានការគន្លឹះនៃយុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨ ជូនទៅលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់រាជរដ្ឋាភិបាល។

## ៤.១០. ការងារគ្រឹះស្ថានអង្គរ

### ក. ប្រតិបត្តិការប្រមូលចំណូលពីការលក់បណ្ណ ឆ្នាំ២០២៤

គ្រឹះស្ថានបានលក់បណ្ណជូនភ្ញៀវអន្តរជាតិ ចូលរមណីយដ្ឋានអង្គរ បានចំនួន ១ ០២៣ ៦៤៨ នាក់ មានកំណើន ២៨,៦% ធៀបនឹងឆ្នាំ២០២៣ ក្នុងនោះ បណ្ណរយៈពេល ១ថ្ងៃ ស្មើនឹង ៦១,៧% រយៈពេល៣ថ្ងៃ ស្មើនឹង ៣៦,៦% និងរយៈពេល៧ថ្ងៃ ស្មើនឹង១,៦% លក់សំបុត្ររយៈពេលវែងបានចំនួន ៤៤២ នាក់ លក់បណ្ណចូលរមណីយដ្ឋានកោះកែរបានចំនួន ២១ ៩៣៥ នាក់ និងសំបុត្រចូលទស្សនាចុងឃ្មៀស ក្នុងតម្លៃសំបុត្រ ៧ ដុល្លារ មានចំនួន ៣ ៦០៩ នាក់ និងទូកដាកញ្ចប់សរុបចំនួន ២៨ ៤៦៨ កញ្ចប់(ទូកតូច=១៩ ៩៣៧ក ទូកកណ្តាល=៧ ៤១៨ក ទូកធំ=១ ១១៣ក ចំនួនភ្ញៀវឆ្លងកាត់ផៃ=៣ ៩៩៣ នាក់)។

ក្នុងឆ្នាំ២០២៤ គ្រឹះស្ថានអនុវត្តចំណូលសរុបចំនួន ៤៩ ៥១៦ ៥២៣,១៧ ដុល្លារ ដែលក្នុងនោះ សមតុល្យឆ្នាំ២០២៣ ចំនួន ៤៨២ ៩៦០,១៧ ដុល្លារ ចំណូលរមណីយដ្ឋានអង្គរ ចំនួន ៤៧ ៨២៦ ៩៨១ ដុល្លារ ចំណូលបណ្ណរយៈពេលវែងចំនួន ៧១ ៣០០ ដុល្លារ ចំណូលរមណីយដ្ឋានកោះកែរចំនួន ៣២៩ ០២៥ ដុល្លារ និងចំណូលពីការលក់សំបុត្រទូកចូលទស្សនាបឹងទន្លេសាបចំនួន ៨០៦ ២៥៧ ដុល្លារ។

ក្នុងចំណូលសរុបចំនួន ៤៩ ៥១៦ ៥២៣,១៧ ដុល្លារ បានបែងចែកដូចខាងក្រោម៖

| | | |
|---|---|---|
| - ឧបត្ថម្ភមូលនិធិគន្ធបុប្ផាចំនួន | ២ ០៤៧ ៣៧៦ | ដុល្លារ |
| - ទូទាត់សេវាតាមប្រព័ន្ធអេឡិចត្រូនិកចំនួន | ១ ៤២៥ ៣២៨,៥៦ | ដុល្លារ |
| - ធ្វើប្រកាសបង់ថវិកាជាតិចំនួន | ៤៥ ០១៣ ៥៦៣,៤៩ | ដុល្លារ |
| - សមតុល្យឆ្នាំ២០២៤ | ១ ០៣០ ២៥៥,១២ | ដុល្លារ |

គ្រឹះស្ថានបានធ្វើសាលាកប័ត្របង់ចំណូលចូលថវិកាជាតិក្នុងឆ្នាំ២០២៤ ជាប្រាក់រៀលមានចំនួន ១៨២ ៩១៤,៣ លានរៀល ស្មើនឹង ៨៦,៤% នៃផែនការ ។

### ខ. ប្រតិបត្តិការចំណាយឆ្នាំ២០២៤

ឆ្នាំ២០២៤ គ្រឹះស្ថានទទួលថវិកាឧបត្ថម្ភកធន ១៩ ៩៥៥ លានរៀល និងថវិកាអតិរេក ចំនួន ១ ៤៦៨ លានរៀល បានអនុវត្តចំណាយប្រតិបត្តិការសរុបចំនួន ២០ ២៣៩ លានរៀល ស្មើនឹង ៩៤,៥% នៃផែនការឆ្នាំ ដែលក្នុងនោះ ចំណាយក្រៅបន្ទុកបុគ្គលិកចំនួន ១០ ០៥០,៧ លានរៀល ស្មើនឹង ៩២,២% នៃផែនការឆ្នាំ និងចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤ និង៦១០៩) ចំនួន ១០ ១៨៨,៩ លានរៀល ស្មើនឹង ៩៦,៨% នៃផែនការឆ្នាំ ។

- ក្នុងឆ្នាំ២០២៤ បានអនុវត្តចំណាយកិច្ចលទ្ធកម្មបានចំនួន ៩ គម្រោង គិតជាទឹកប្រាក់សរុបចំនួន ៥ ០៨៩ លានរៀល
- ក្នុងឆ្នាំ២០២៤ គ្រឹះស្ថានបានខិតខំកាត់បន្ថយការចំណាយមិនចាំបាច់ដែលធ្វើឱ្យមានថវិកាអតិរេក ចំនួន ១ ១៨៤ លានរៀល

### គ. ការកែទម្រង់ប្រព័ន្ធលក់សំបុត្រ

- ការកែទម្រង់ប្រព័ន្ធលក់សំបុត្ររបស់គ្រឹះស្ថានអង្គរ បានអនុញ្ញាតឱ្យគ្រឹះស្ថាន អាចកែសម្រួលនីតិវិធីនៃការត្រួតពិនិត្យសំបុត្រដោយប្រើឧបករណ៍ទំនើបមកជំនួសវិញដែលអាចធ្វើការ

ត្រួតពិនិត្យបានគ្រប់ប្រាសាទទាំងអស់ ទោះបីជាសេវាអ៊ីនធឺណេតនៅមានកម្រិតក៏ដោយ

- បានលុបបំបាត់នូវទីតាំងត្រួតពិនិត្យសំបុត្រដែលជាន់គ្នា ដើម្បីសម្រួល និង កាត់បន្ថយផលរំខានដល់ភ្ញៀវទេសចរអន្តរជាតិ
- ដើម្បីសម្រួលដល់ភ្ញៀវទេសចរអន្តរជាតិ ក្នុងការទិញសំបុត្រចូលទស្សនារមណីយដ្ឋានអង្គរ គ្រឹះស្ថានអង្គរ ក៏បានដកចេញនូវព័ត៌មានមិនចាំបាច់មួយចំនួន ពីប្រព័ន្ធលក់សំបុត្រ
- បានអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការលក់សំបុត្រ ដោយប្រើម៉ាស៊ីនស្វ័យប្រវត្តិ (Self-ServiceMachine) ដែលត្រូវបានដាក់លើទីតាំងចំនួន៣កន្លែងរួមមាន៖ (១) នៅបញ្ជរលក់សំបុត្រគ្រឹះស្ថានអង្គរ ចំនួន ៦ គ្រឿង (២) នៅប៉ារីសអង្គរ ចំនួន ៦ គ្រឿង និង(៣) នៅផ្សារទំនើបដឹហេរីថេករ៉ក ចំនួន ៣ គ្រឿង សរុបទាំងអស់មានចំនួន ១៥ គ្រឿង
- បន្ថែមលើនេះ ដើម្បីសម្រួលដល់ភ្ញៀវទេសចរអន្តរជាតិ ក៏ដូចជាប្រតិបត្តិករទេសចរទាំងអស់បន្ថែមទៀត គ្រឹះស្ថានអង្គរ ក៏បានបន្តធ្វើទំនើបកម្មប្រព័ន្ធលក់សំបុត្រអនឡាញ ដែលអនុញ្ញាតឱ្យភ្ញៀវទេសចរអន្តរជាតិ អាចទិញសំបុត្រចូលទស្សនារមណីយដ្ឋានអង្គរ បានតាមរយៈគេហទំព័រ (www.angkorenterprise.gov.kh) និងបានបង្កើតម៉ូបាលអេប (MobileApp) នៅលើ Google និង Applestore សម្រាប់ភ្ញៀវទេសចរអន្តរជាតិក៏ដូចជា ភ្នាក់ងារទេសចរ ចូលទិញសំបុត្រចូលទស្សនារមណីយដ្ឋានអង្គរ ស្របតាមការវិវត្តន៍នៃបច្ចេកវិទ្យាព័ត៌មាន
- ជាមួយនឹងវឌ្ឍនភាពបច្ចុប្បន្ននៃការងារកែទម្រង់របស់គ្រឹះស្ថានអង្គរ ភ្ញៀវទេសចរអន្តរជាតិក៏ដូចជា ភ្នាក់ងារទេសចរទាំងអស់ អាចទិញសំបុត្រចូលទស្សនារមណីយដ្ឋានអង្គរបានតាមបួនរបៀបរួមមាន៖ (១) តាមអនឡាញ (២) តាមម៉ូបាលអេប (៣) តាមម៉ាស៊ីនស្វ័យប្រវត្តិ និង(៤) តាមបញ្ជរលក់សំបុត្រ
- ការកែទម្រង់នេះបានផ្តល់ភាពកាន់តែងាយស្រួលបន្ថែមទៀតដល់ភ្ញៀវទេសចរអន្តរជាតិ ក៏ដូចជាគ្រប់ប្រតិបត្តិករទេសចរទាំងអស់ផងដែរ។

### ៤.១១. ការងារសាលាវិជ្ជាជីវៈទេសចរណ៍

- គម្រោងបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍គិតត្រឹមបំណាច់ខែធ្នូ ឆ្នាំ២០២៤៖
  - ១) បានបញ្ចប់ការសាងសង់អគារសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងពីរទីតាំង (រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ) សម្រេចបាន១០០%
  - ២) បានចុះកិច្ចសន្យា ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាល ការិយាល័យ និងបានចាប់ផ្តើមប្រគល់ បំពាក់
  - ៣) បានសហការជាមួយកុងសុលតង់ William Angliss Institute អ្នកជំនាញពីប្រទេសអូស្ត្រាលី រៀបចំសេចក្តីព្រាងកម្មវិធីសិក្សា និងការបណ្តុះបណ្តាល ឧបករណ៍បណ្តុះបណ្តាល (Toolboxes) សេចក្តីព្រាងផែនការយុទ្ធសាស្ត្រ សេចក្តីព្រាងម៉ូដែលសេដ្ឋកិច្ច គម្រោងថវិការបស់សាលា សេចក្តីព្រាងផែនការជ្រើសរើសសិស្ស-និស្សិត សេចក្តីព្រាងយុទ្ធសាស្ត្រទីផ្សារ ការផ្សព្វផ្សាយទំនាក់ទំនង និងឯកសាររដ្ឋបាល និងហិរញ្ញវត្ថុផ្សេងទៀតសម្រាប់ដាក់ឱ្យដំណើរការសាលានាពេលខាងមុខ

៤) បានរៀបចំឱ្យមានបណ្តាញសង្គម Facebook, Telegram និងកំពុងសហការជាមួយក្រុមហ៊ុន Sala Tech Solution និងកុងសុលតង់ WAI រៀបចំគូសនិងអភិវឌ្ឍន៍វេបសាយ និងប្រព័ន្ធគ្រប់គ្រងសាលា ដើម្បីធ្វើការផ្សព្វផ្សាយពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

៥) ជំរុញការរៀបចំអនុក្រឹត្យ និងបទដ្ឋានគតិយុត្ត ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ

៦) បានបញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីសាលា និងគម្រោងទៅទស្សនៈកិច្ចសិក្សានៅ Chambre de Métiers et Artisanals នាទីក្រុងប៉ារីស ប្រទេសបារាំង។

## IV. ការវិភាគទេសចរណ៍ និន្នាការ ទស្សនវិស័យ និង គោលនយោបាយទេសចរណ៍

១) បានរៀបចំ ចងក្រងស្ថិតិទេសចរណ៍ និងលទ្ធផលនៃការវិភាគ និន្នាការទេសចរណ៍កម្ពុជា តំបន់ សកល ដោយមានកិច្ចសហការផ្តល់ទិន្នន័យពីអគ្គនាយកដ្ឋាន អន្តោប្រវេសន៍ ធនាគារជាតិនៃកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ និងបណ្តាមន្ទីរទេសចរណ៍រាជធានី ខេត្តទាំង២៥ ព្រមទាំងមានការសិក្សាស្រាវជ្រាវ ស្ទង់មតិដែលជាធាតុចូល និងឈរលើគោលការណ៍ភាពត្រឹមត្រូវ ភាពសត្យានុម័ត សម្រេចបាននូវលទ្ធផលសង្ខេប ដូចមានខាងក្រោម៖

- បានប្រមូល រៀបចំ ចងក្រង វិភាគ បោះពុម្ពសៀវភៅរបាយការណ៍ស្ថិតិទេសចរណ៍ ឆ្នាំ២០២៤ សម្រាប់បម្រើឱ្យតម្រូវការរបស់អ្នកស្រាវជ្រាវអ្នករៀបចំគោលនយោបាយ និងអ្នកប្រើប្រាស់ស្ថិតិទូទៅ ទាំងកម្រិតជាតិនិងអន្តរជាតិ
- បានចងក្រងសូចនាករទេសចរណ៍ និងស្ថិតិទេសចរណ៍ផ្លូវការឆ្នាំ២០២៤ ចំនួន ៨ ប្រភេទ៖ (១) ទេសចរអន្តរជាតិ (២) ទេសចរជាតិ (៣) ទេសចរជាតិចេញក្រៅ (៤) មូលដ្ឋានអាជីវកម្មទេសចរណ៍ (៥) សេវកម្មស្នាក់នៅ (៦) ចំណូលទេសចរណ៍អន្តរជាតិ (៧) មុខរបរ និងការងារទេសចរណ៍ និង(៨) វិស័យទេសចរណ៍បានរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុប
- បានរៀបចំចងក្រងសូចនាករទេសចរណ៍ចំនួន ២ ផ្សេងទៀត សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (បញ្ចកោណទី២ មុំទី១)៖ (១) អត្រាកំណើនទេសចរអន្តរជាតិ និង(២) តម្លៃបន្ថែមវិស័យទេសចរណ៍
- បានរៀបចំសិក្ខាសាលាស្តីពីការពង្រឹងគុណភាព សង្គតិភាពទិន្នន័យទេសចរណ៍ និងការពង្រឹង សមត្ថភាពមន្ត្រីជំនាញស្ថិតិថ្នាក់ក្រោមជាតិ ដែលមានសិក្ខាកាមចូលរួមសរុបប្រមាណ ៦៥០ នាក់។

២) បានពិនិត្យលើស្ថានភាពទេសចរណ៍តាមប៉ូលទេសចរណ៍សំខាន់ៗ ដើម្បីប្រមូលធាតុចូលសម្រាប់ការវាយតម្លៃ វិភាគ និងព្យាករណ៍ពិពិធកម្មផលិតផលដើម្បីធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិលើវិស័យទេសចរណ៍កម្ពុជា និងគោលនយោបាយទេសចរណ៍នាពេលអនាគតព្រមទាំងការចងក្រង សូចនាករវាយតម្លៃ ដូចខាងក្រោម៖

- ការចុះសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យស្តីពី "ផលប៉ះពាល់នៃវិស័យទេសចរណ៍មកលើសង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន" នៅតាមគោលដៅទេសចរណ៍ ខេត្តកោះកុង
- ការចុះអង្កេត តាមដាន និងពិគ្រោះយោបល់ ដើម្បីជាធាតុចូលពីលទ្ធផលនៃការអនុវត្តគោលនយោបាយជាតិ លើវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាពនៅខេត្តពោធិ៍សាត់
- បានរៀបចំវេទិកាស្តីពី "គោលនយោបាយ និងអភិបាលកិច្ចទេសចរណ៍៖ ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ និងការគ្រប់គ្រងគោលដៅ" នៅខេត្តសៀមរាប
- បានរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពី "**ទេសចរណ៍ពិសិដ្ឋ**"
- បានប្រមូលនូវទិន្នន័យ ដែលជាធាតុចូលពីការសិក្សា វិភាគ រាល់បញ្ហាប្រឈមនានា ដែលកម្ពុជាសំដៅបង្កើនប្រសិទ្ធភាពនៃការរៀបចំគោលនយោបាយដើម្បីឆ្លើយតបនឹងនិន្នាការនៃបម្រែបម្រួលក្នុងវិស័យទេសចរណ៍នាពេលបច្ចុប្បន្ន និងនាពេលអនាគត
- បានចុះសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យស្តីពី "ផលប៉ះពាល់នៃវិស័យទេសចរណ៍មកលើសង្គមសេដ្ឋកិច្ចវប្បធម៌ និងបរិស្ថាន" នៅតាមគោលដៅនៅខេត្តកោះកុង
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការអនុវត្តគោលនយោបាយជាតិលើវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងបរិយាប័ន្នក្នុងបរិកាណ៍ឌីជីថល នៅខេត្តពោធិ៍សាត់

៣) បានពង្រឹងកិច្ចសហការអន្តរជាតិ ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រីរាជការ ទាំងលើផ្នែកសិក្សាស្រាវជ្រាវ គោលនយោបាយទេសចរណ៍ និងផលប៉ះពាល់លើវិស័យទេសចរណ៍កម្ពុជា៖

- ការចុះអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយសកលវិទ្យាល័យយូណានមីនជូ នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីកិច្ចសហប្រតិបត្តិការជំរុញ និងគាំទ្រការអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យទេសចរណ៍ ឆ្នាំ២០២៤
- សហការជាមួយប្រតិភូមជ្ឈមណ្ឌលសហប្រតិបត្តិការ និងផ្លាស់ប្តូរអន្តរជាតិ នៃមន្ទីរពាណិជ្ជកម្មខេត្តហៃណាន នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការស្វែងរកជំនួយគាំទ្រពង្រឹងកិច្ចសហប្រតិបត្តិការ លើការបណ្តុះបណ្តាលមន្ត្រីរាជការរបស់ក្រសួងទេសចរណ៍
- សហការជាមួយមជ្ឈមណ្ឌលបណ្ឌិតសភាវប្បធម៌ និងទេសចរណ៍ចិន ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការកម្ពុជា-ចិន ក្នុងគោលបំណងលើកស្ទួយកិច្ចសហប្រតិបត្តិការ "**ឆ្នាំទេសចរណ៍កម្ពុជា-ចិន ២០២៥**"
- សហការជាមួយសកលវិទ្យាល័យសេដ្ឋកិច្ចវៀតណាម ក្រោមកិច្ចសហប្រតិបត្តិការទ្វេភាគីដោយបានរៀបចំវេទិការចែករំលែកលទ្ធផល នៃការសិក្សាស្រាវជ្រាវអំពីការអភិវឌ្ឍសេដ្ឋកិច្ចបៃតង "Green Growth Development"
- សហការជាមួយមជ្ឈមណ្ឌល Responsible Borne នៃមហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច នៃសាកលវិទ្យាល័យ i-CATS រដ្ឋ Sarawak ប្រទេសម៉ាឡេស៊ី សំដៅលើកស្ទួយការសិក្សាស្រាវជ្រាវលើការអភិវឌ្ឍវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច ប្រកបការទទួលខុសត្រូវ និងមាននិរន្តរភាព

- សហការជាមួយគ្រឹះស្ថានសិក្សាទេសចរណ៍ជាតិ និងអន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធ ក្នុងការស្រាវជ្រាវ និងការរៀបចំគោលនយោបាយក្នុងវិស័យទេសចរណ៍។

## V. បញ្ហាប្រឈមគន្លឹះត្រូវសិក្សាដោះស្រាយ

នៅឆ្នាំ២០២៤ ទន្ទឹមនឹងលទ្ធផល និងសមិទ្ធផលនានា ដែលយើងសម្រេចបាន ក៏នៅមានបញ្ហាប្រឈមគន្លឹះមួយចំនួនដែលត្រូវសិក្សា វាយតម្លៃ និងរកជម្រើសនៃដំណោះស្រាយសមស្រប។ បញ្ហាប្រឈមទាំងនេះ គឺបណ្តាលមកពីកត្តាពាក់ព័ន្ធទាំងខាងក្នុង និងខាងក្រៅ ដែលតម្រូវឱ្យយកចិត្តទុកដាក់ជំរុញ កិច្ចសហការដោះស្រាយបញ្ហា ឬប្រែក្លាយបញ្ហាប្រឈមទៅជាឱកាសសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍវិស័យទេសចរណ៍សម្រាប់ឆ្នាំ២០២៥ និងបន្តបន្ទាប់។ កត្តាពាក់ព័ន្ធនឹងបញ្ហាប្រឈមគន្លឹះ រួមមាន៖

១) កត្តាសន្តិសុខ សុវត្ថិភាពទេសចរណ៍ ជាកត្តាចម្បងបំផុតរបស់ទេសចរក្នុងការសម្រេចចិត្តធ្វើដំណើរ និងទស្សនា។ ក្នុងស្ថានភាពកន្លងមក និន្នាការនៃការធ្វើដំណើរ និងទេសចរណ៍បានថមថយ ដោយសារវិបត្តិនៃការរីករាលដាលជំងឺឆ្លង (កូវីដ-១៩) វិបត្តិដ៏ពុំរ៉ៃនៃសង្គ្រាម ក្នុងពិភពលោក រួមទាំងគ្រោះធម្មជាតិនានាដែលបានកើតឡើងជាបន្តបន្ទាប់។ ម្យ៉ាងទៀត ដោយសារហេតុផលនៃសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងកត្តាពាក់ព័ន្ធដទៃទៀត ទេសចរមួយចំនួនបានប្តូរនិន្នាការពីការធ្វើដំណើរផ្លូវឆ្ងាយ មកគោលដៅទេសចរណ៍នៅក្នុងប្រទេស ឬក្នុងតំបន់ជិតៗក្បែរខាង។ មួយវិញទៀត ដោយសារការគិតគូរអំពី សន្តិសុខ សុវត្ថិភាពភ្ញៀវមួយចំនួនក៏បានកាត់បន្ថយការធ្វើដំណើរ និងទេសចរណ៍។ ជាអាទិភាពសម្រាប់ការទាក់ទាញទេសចរត្រូវបានផ្តោតសំខាន់លើកត្តាពាក់ព័ន្ធនឹងការការពារ ថែរក្សា សន្តិសុខ សុវត្ថិភាពភ្ញៀវ និងការបង្កលក្ខណៈងាយស្រួលផ្នែកព័ត៌មានពិត ពង្រឹងការផ្សព្វផ្សាយរូបភាព ខ្លឹមសារវិជ្ជមានប្រឆាំងព័ត៌មានក្លែងក្លាយ ព្រមទាំងសម្រួលការចូល-ចេញ ការធ្វើដំណើរ ស្នាក់នៅ ការទទួលបាននូវសេវាទេសចរណ៍ប្រកបដោយគុណភាព បដិសណ្ឋារកិច្ចល្អ ផាសុកភាព និងប្រកបដោយការធានា សុខ សុវត្ថិភាពសម្រាប់ទេសចរគ្រប់គ្នា។ បន្ថែមលើនេះ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងកិច្ចសហការដោះស្រាយបញ្ហា និងសម្រួលកិច្ចការពាក់ព័ន្ធផ្ទៃក្នុងនានា សណ្តាប់ធ្នាប់ របៀបរៀបរយ សំដៅលើកកម្ពស់ជំនឿទុកចិត្តរបស់ភ្ញៀវស្តីពីសុវត្ថិភាពទេសចរណ៍ ដូចជា៖ ការលុបបំបាត់ការភ័យខ្លាច ការបារម្ភណ៍អំពីបញ្ហាអវិជ្ជមាន ស្តីពីការចាប់ជំរិត ការឆបោកតាមអនឡាញ។ល។

២) កត្តាសេដ្ឋកិច្ច គឺជាផ្នែកដែលមានឥទ្ធិពលផងដែរក្នុងការសម្រេចចិត្តរបស់ទេសចរ។ កន្លងមក ដោយសារវិបត្តិជាសកលនៃជំងឺកូវីដ-១៩ ប្រទេសនានាលើសកលលោករួមទាំងកម្ពុជា បានទទួលរងឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរមិនធ្លាប់មាន ដែលបណ្តាលឱ្យប៉ះពាល់ផ្នែកសេដ្ឋកិច្ចសកល និងខ្សែច្រវាក់ផ្គត់ផ្គង់ និងសេវាកម្មទេសចរណ៍ត្រូវបានកាត់ផ្តាច់។ ស្ថិតក្នុងដំណាក់កាលនៃការស្តារឡើងវិញនៃវិស័យទេសចរណ៍ ការងើបឡើងវិញនេះ មានសភាពមិនទាន់បានទាំងស្រុងនៅឡើយ ដោយក្នុងនោះការប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងការប្រែប្រួលប្រជាសាស្ត្របណ្តាលឱ្យនៅមានការកាត់បន្ថយការធ្វើដំណើរទេសចរណ៍ កាត់បន្ថយរយៈពេលនៃការទស្សនា

និងបន្ថយការចំណាយ។ ក្រៅពីនេះ កត្តាពាក់ព័ន្ធផ្សេងៗទៀត រួមមានៈ សង្គ្រាមពាណិជ្ជកម្ម អស្ថិរភាពគោលនយោបាយនៃបណ្តាប្រទេសមួយចំនួន អតិផរណា គឺនៅតែជាបញ្ហាប្រឈមគន្លឹះដែលជះឥទ្ធិពលអវិជ្ជមានដល់វិស័យទេសចរណ៍។

៣) កត្តាប្រកួតប្រជែង ក៏ត្រូវបានចាត់ទុកជាគន្លឹះសំខាន់ក្នុងការអភិវឌ្ឍ និងការទាក់ទាញទេសចរ។ កត្តាទាំងនេះ មានផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានស្របតាមស្ថានភាព តួអង្គ កាលៈទេសៈ តម្រូវ ព្រមទាំងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍។ ការប្រែប្រួលនយោបាយ ឬគោលនយោបាយនៃប្រទេសជិតខាងក្នុងតំបន់និងអន្តរជាតិ អាចបង្កឬជះឥទ្ធិពលដល់ការអភិវឌ្ឍទេសចរណ៍ និងឧត្តមភាពប្រៀបធៀប ឬកម្លាំងនៃការប្រកួតប្រជែងរបស់កម្ពុជា។ ភាពនៅមានកម្រិត និងការសម្រួលផ្នែកគោលនយោបាយ ក៏ត្រូវបានកត់សម្គាល់ជាបញ្ហាប្រឈមផងដែរសម្រាប់ការប្រកួតប្រជែងនៃវិស័យទេសចរណ៍កម្ពុជា ធៀបនឹងតំបន់និងពិភពលោកផងដែរ។ ដូច្នេះ ការគិតគូរសិក្សាស៊ីជម្រៅអំពីឥទ្ធិពល ការប្រែប្រួលនយោបាយ ឬគោលនយោបាយនៃបណ្តាប្រទេសនានា ការវិវត្តនៃបច្ចេកវិទ្យា ព្រមទាំងការយកចិត្តទុកដាក់សម្រួល និងរៀបចំគោលនយោបាយ និងកត្តាពាក់ព័ន្ធនានារបស់កម្ពុជា គឺជាគន្លឹះចាំបាច់សម្រាប់បង្កើនការប្រកួតប្រជែង និងឧត្តមភាពប្រៀបធៀបរបស់កម្ពុជានៅក្នុងតំបន់ និងអន្តរជាតិ។

## VI. ទិសដៅអនុវត្តបន្តឆ្នាំ២០២៥

### ១. ការអភិវឌ្ឍទេសចរណ៍ ការវិនិយោគ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ និងយុទ្ធនាការទាក់ទាញទេសចរ

- បន្តពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍នៅតាមបណ្តាសហគមន៍ និងរមណីយដ្ឋានទេសចរណ៍
- បន្តចុះបើកវគ្គបណ្តុះបណ្តាលជូនសហគមន៍ ដែលនឹងត្រូវបានទទួលស្គាល់ជាផ្លូវការសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ពីគណៈកម្មាធិការជាតិ គ.ជ.អ.អ
- បន្តសហការជាមួយមន្ទីរទេសចរណ៍រាជធានីខេត្ត ជំរុញឱ្យម្ចាស់រមណីយដ្ឋានទេសចរណ៍ដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ និងចំណាត់ថ្នាក់បន្ថែមទៀត
- បន្តសហការជាមួយរដ្ឋបាលខេត្តសៀមរាប និងមន្ទីរទេសចរណ៍ ដើម្បីចុះសិក្សា និងជួយដោះស្រាយនូវបញ្ហាប្រឈមក្នុងការស្តារប្រឡាយទឹកសម្រាប់ធ្វើដំណើរទៅកាន់សហគមន៍ទេសចរណ៍ធម្មជាតិកំពង់ភ្លុក និងសមាគមកាណូតដឹកភ្ញៀវទេសចរចុងឃ្នៀស
- ជំរុញការរៀបចំផែនការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍
- ជំរុញការដាក់ចេញប្រកាសឱ្យអនុវត្តស្តង់ដារវត្តទេសចរណ៍គំរូ ស្តង់ដាហាងលក់វត្ថុអនុស្សាវរីយ៍ និងស្តង់ដាភូមិទេសចរណ៍គំរូ
- រៀបចំសិក្ខាសាលាប្រកាសផ្សព្វផ្សាយដាក់ឱ្យអនុវត្តស្តីពី ស្តង់ដាអេកូទេសចរណ៍អាស៊ាន ( ASEAN Ecotourism standard )

- ជំរុញកិច្ចសហការជាមួយមហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច និងមហាវិទ្យាល័យវិស្វកម្ម និងស្ថាបត្យកម្ម ដើម្បីចូលរួមជំរុញកំណើននិស្សិតចុះធ្វើកម្មសិក្សារៀបចំផែនការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍។
- ដឹកនាំរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ និងចុះវាយតម្លៃសមិទ្ធកម្មផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២៣-២០២៥ របស់រាជធានីខេត្តចុងអាណត្តិ
- បណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ លើការកសាងផែនការអភិវឌ្ឍទេសចរណ៍ និងការវាយតម្លៃសមិទ្ធកម្មពាក់កណ្ដាលអាណត្តិ
- សហការរៀបចំផែនការអភិវឌ្ឍទេសចរណ៍មហាអនុតំបន់មេគង្គ (GMS) និងចូលរួមកិច្ចប្រជុំក្រុមការងារទេសចរណ៍មហាអនុតំបន់មេគង្គលើកទី៥៥ នៅប្រទេសឡាវ និងលើកទី៥៦ នៅប្រទេសវៀតណាម និងវេទិកាទេសចរណ៍មេគង្គឆ្នាំ២០២៥ នៅប្រទេសឡាវ
- ជំរុញកិច្ចសហការជាមួយអង្គការ International Organization for Francophonie (OIF) ដើម្បីរៀបចំសិក្ខាសាលាថ្នាក់តំបន់ស្ដីពីគោលដៅទេសចរណ៍បៃតង (Green Destination) វគ្គបណ្ដុះបណ្ដាលថ្នាក់តំបន់ស្ដីពីការអភិវឌ្ឍអេកូទេសចរណ៍ និងកម្មវិធីបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍និយាយភាសាបារាំង ក្រោមកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធនៅឆ្នាំ២០២៥ សំដៅត្រៀមខ្លួនកម្ពុជាធ្វើម្ចាស់ផ្ទះកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ឆ្នាំ២០២៦ (Francophonie Summit 2026)
- បន្តកិច្ចសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការអាស៊ាន-ជប៉ុន (AJC) ដើម្បីអនុវត្តគម្រោងបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពឌីជីថលដល់ស្ត្រីក្នុងសហគមន៍អេកូទេសចរណ៍កោះទ្រង់ ខេត្តក្រចេះនៅអំឡុងត្រីមាសទី១ ឆ្នាំ២០២៥
- បន្តធ្វើកិច្ចសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ករណីកែសម្រួលខ្លឹមសារនៃកិច្ចព្រមព្រៀងបង្កើតការិយាល័យទេសចរណ៍មហាអនុតំបន់មេគង្គ (GMSTO) និងបន្តនីតិវិធីពាក់ព័ន្ធ
- ត្រៀមរៀបចំនីតិវិធី និងគោលការណ៍ពាក់ព័ន្ធ ដើម្បីពិនិត្យលទ្ធភាព និងការអនុញ្ញាត កម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ លើកទី៨ នៃកិច្ចសហប្រតិបត្តិការរបៀងទេសចរណ៍ភាគខាងត្បូង (8th STC Meeting) នៅឆ្នាំ២០២៦ តាមវេន ស្របតាមស្មារតីកិច្ចប្រជុំក្រុមការងារកិច្ចសហប្រតិបត្តិការរបៀងទេសចរណ៍ភាគខាងត្បូងកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤
- សហការជាមួយការិយាល័យសម្របសម្រួលទេសចរណ៍មេគង្គ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងប្រទេសជាសមាជិក GMS ដើម្បីផ្ដល់ធាតុចូលចុងក្រោយលើផែនការអភិវឌ្ឍន៍ទេសចរណ៍មហាអនុតំបន់មេគង្គ មុននឹងដាក់ឆ្លងសិក្ខាសាលាថ្នាក់តំបន់នៅឆ្នាំ២០២៥ ខាងមុខ
- រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ របស់លេខាធិការដ្ឋាន នៃគណៈកម្មការគ្រប់គ្រងគម្រោង ហូកា (HoKa) ដើម្បីសុំយោបល់ និងការឯកភាពពី **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍** មុននឹងចាប់អនុវត្តចាប់ពីឆ្នាំ២០២៥ខាងមុខ

- បន្តកិច្ចសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរៀបចំគុណវុឌ្ឍិក្នុងវិស័យទេសចរណ៍ចំនួន ១០គុណវុឌ្ឍិ លើជំនាញការិយាល័យជួរមុខ គេហកិច្ច ចុងភៅ និងសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ ដើម្បីសង្គតិភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍
- សហការជាមួយមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) ដើម្បីជំរុញសំណើគម្រោងបណ្តុះបណ្តាលអ្នកជំនាញទេសចរណ៍កម្ពុជាទាំងការបណ្តុះបណ្តាលអ្នកជំនាញថ្មី និងពង្រឹងសមត្ថភាពគ្រូបង្គោល និងអ្នកជំនាញកំពុងម្រើការងារបច្ចុប្បន្ន
- សហការជាមួយអង្គការ ILO ដើម្បីបន្តអនុវត្តកម្មវិធីរួបរួមគ្នា ស្តីពីមុខរបរ និងការងារសមរម្យសម្រាប់យុវជននៅកម្ពុជា ដំណាក់កាលទី៣(Decent Employment for Youth in Cambodia-DEY III) ដែលដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ត្រៀមរៀបចំកិច្ចប្រជុំឆ្លងកម្រិតថ្នាក់ដឹកនាំលើឯកសារស្តីពី "**ស្តង់ដាទេសចរណ៍មូស្លីម**"
- រៀបចំ និងចងក្រងឯកសារស្តីពី "Cambodia Muslim Friendly Tourism Route" ឱ្យសម្បូរបែបក្នុងការចែករំលែកជូនទៅដល់គ្រប់ភាគីពាក់ព័ន្ធដើម្បីផ្តល់ជាផលប្រយោជន៍រួមក្នុងការអភិវឌ្ឍទេសចរណ៍មូស្លីម
- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាចំណីអាហារ និងបដិសណ្ឋារកិច្ចទេសចរណ៍មូស្លីមដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០២៥
- ត្រៀមចុះជួយរៀបចំសហគមន៍ទេសចរណ៍ឥស្លាមរួមមាន៖ ខេត្តកំពត ត្បូងឃ្មុំ សៀមរាប និងខេត្តបាត់ដំបង ទៅតាមតំបន់គោលដៅដែលមិនទាន់មានជាសហគមន៍ទេសចរណ៍ឥស្លាមនៅឡើយ
- ពង្រឹងសមត្ថភាពមន្ត្រីបង្គោលនៃទេសចរណ៍មូស្លីមតាមបណ្តារាជធានីខេត្តគោលដៅនីមួយៗ និងជំរុញបន្ថែមមជ្ឈមណ្ឌលផ្តល់ព័ត៌មានទេសចរណ៍ ឱ្យមានការផ្តល់ព័ត៌មានអំពីទេសចរណ៍មូស្លីម
- បង្កើតជាពាក្យស្វាគមន៍ថា (Assalamualaikum) នៅតាមអាកាសយានដ្ឋានព្រំប្រទល់អន្តរជាតិ និងរមណីយដ្ឋានទេសចរណ៍ជាដើម
- ជំរុញបង្កើតព្រឹត្តិការណ៍ Muslim Festival ប្រចាំឆ្នាំនៅតាមគោលដៅ ដែលមានសក្តានុពលនៅតាមបណ្តារាជធានីខេត្តមួយចំនួន
- សហការជាមួយក្រុមហ៊ុនទេសចរណ៍ ដែលកំពុងដំណើរការអាជីវកម្មជាមួយទីផ្សារមូស្លីមដើម្បីបង្កើនសកម្មភាពផ្សព្វផ្សាយឱ្យចំគោលដៅនិងរៀបចំឱ្យមានកិច្ចប្រជុំពិភាក្សាជាប្រចាំរវាងរដ្ឋ និងឯកជន ព្រមទាំងធ្វើការសហការជាមួយបណ្តាប្រទេសនានា លើកិច្ចការទេសចរណ៍មូស្លីម ដូចជាអនុស្សារណៈយោគយល់គ្នា និងការងារផ្លាស់ប្តូរបទពិសោធន៍គ្នាលើការងារទេសចរណ៍មូស្លីម
- រៀបចំធ្វើបច្ចុប្បន្នកម្មលើសេចក្តីសម្រេចស្តីពីការកែសម្រួលក្រុមការងារទេសចរណ៍មូស្លីម "Muslim Friendly Tourism"
- បន្តស្វែងរកដៃគូអភិវឌ្ឍនានា ដើម្បីគាំទ្រ និងជួយដល់សហគមន៍ទេសចរណ៍ឥស្លាម ដែលមានស្រាប់នៅខេត្តកំពត ខេត្តត្បូងឃ្មុំ ខេត្តសៀមរាប និងខេត្តបាត់ដំបង។
- រៀបចំធ្វើបច្ចុប្បន្នភាពលើគម្រោងវិនិយោគទេសចរណ៍នៅកម្ពុជា

- ចុះសិក្សា ប្រមូល និងចងក្រងទិន្នន័យវិនិយោគសហគ្រាសទេសចរណ៍ខ្នាតតូច និងមធ្យម (SMEs) គម្រោងវិនិយោគឯកជន គម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគភាពជាដៃគូរដ្ឋ និងឯកជន
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីគោលនយោបាយតំបន់ពិសិដ្ឋ អនុក្រឹត្យស្តីពីតំបន់ទេសចរណ៍ពិសិដ្ឋ និងឱកាស នៃការវិនិយោគទេសចរណ៍នៅតំបន់សៀមរាប និងតំបន់ជុំវិញ
- រៀបចំសមិទ្ធិលទ្ធភាពនៃគម្រោងវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ដើម្បីស្វែងរកទុនវិនិយោគពីដៃគូអភិវឌ្ឍន៍
- បន្តជំរុញកិច្ចសហការជាមួយក្រុមការងារ ជំរុញការអនុវត្តកម្មវិធីពិសេសខេត្តព្រះសីហនុ
- បន្តអនុវត្តអនុស្សារណៈនៃការយោគយល់ (MOU) រវាងក្រសួងទេសចរណ៍ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលជំនាញឌីជីថលជូនថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួងទេសចរណ៍
- បន្តកិច្ចសហប្រតិបត្តការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងភាគីពាក់ព័ន្ធ ដើម្បីធ្វើបច្ចុប្បន្នភាពហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៃក្រសួងទេសចរណ៍
- បន្តកិច្ចសហប្រតិបត្តការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលដើម្បីដាក់ឱ្យដំណើរការថ្នាលនិងកម្មវិធីរដ្ឋាភិបាលឌីជីថល (Digital Government Products - DGPs) ក្នុងក្របខណ្ឌក្រសួងទេសចរណ៍
- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន ប្រាវីនយ៉ា អ៊ីសឺវីស (PRAVINYA ESERVICES CO., LTD.) ដើម្បីអភិវឌ្ឍថ្នាលនិងកម្មវិធីឌីជីថលក្នុងវិស័យទេសចរណ៍
- បន្តកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន ដើម្បីសិក្សា និងគាំទ្រដល់ការអភិវឌ្ឍថ្នាលទេសចរណ៍ឆ្លាត និងប្រព័ន្ធព័ត៌មានចាំបាច់សម្រាប់ក្រសួងទេសចរណ៍ ជាអាទិ៍ ថ្នាលសម្រាប់គាំទ្រដល់ការបង្កើតសេវាទេសចរណ៍ឆ្លាត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននិងគោលការណ៍ណែនាំទេសចរណ៍ ប្រព័ន្ធកក់និងទិញតាមអនឡាញ ប្រព័ន្ធគ្រប់គ្រងអាជ្ញាបណ្ណនិងចំណូល ប្រព័ន្ធគ្រប់គ្រងរចនាសម្ព័ន្ធនិងលំហូរឯកសារ និងប្រព័ន្ធគ្រប់គ្រងបុគ្គលិក
- បន្តតាមដានដំណើរការនៃការរៀបចំអនុម័តផែនការសកម្មភាពសម្រាប់ក្រុមការងារពិសេសក្នុងវិស័យទេសចរណ៍ និងដឹកជញ្ជូនអាស៊ានសម្រាប់ឆ្នាំ២០២៥-២០២៦ (Plan of Actions of Ad-Hoc Task Force on Tourism and Transportation (ATFTT) និងសហការជាមួយផ្នែកដឹកជញ្ជូនអាស៊ាន ក្នុងការអនុវត្តលក្ខខណ្ឌការងារក្រុមការងារពិសេសក្នុង វិស័យទេសចរណ៍ និងដឹកជញ្ជូនអាស៊ាន ATFTT (Term of Reference on ATFTT) ឱ្យមានប្រសិទ្ធភាព
- បន្តតាមដានការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រទេសចរណ៍អាស៊ានក្រោយឆ្នាំ២០២៥ ដែលដឹកនាំសម្របសម្រួលដោយប្រទេសហ្វីលីពីន
- បន្តតាមដានវឌ្ឍនភាពការងារគំនិតផ្តួចផ្តើម "ប្រទេសប្រាំមួយ គោលដៅមួយ - Six Countries, One Destination"

- បន្តសម្របសម្រួលផែនការសកម្មភាព ដែលកម្ពុជាដឹកនាំ ក្នុងផែនការយុទ្ធសាស្ត្រទេសចរណ៍ អាស៊ាន ឆ្នាំ២០១៦-២០២៥
- បន្តតាមដានការអនុវត្តផែនការសកម្មភាពរួមស្តីពី កិច្ចសហប្រតិបត្តិការទេសចរណ៍ ឆ្នាំ២០២៣-២០២៥ ទាំងក្នុងក្របខណ្ឌអនុតំបន់ ACMECS និងក្របខណ្ឌទ្វេភាគីកម្ពុជា-ថៃ ឱ្យបានប្រសិទ្ធភាពខ្ពស់
- បន្តសហការជាមួយស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា ដើម្បីត្រៀមរៀបចំព្រឹត្តិការណ៍ក្នុង "**ឆ្នាំទេសចរណ៍កម្ពុជា-ចិន ២០២៥**"
- ជំរុញកិច្ចសហប្រត្តិបត្តិការក្នុងវិស័យទេសចរណ៍រវាងក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្តសានស៊ី
- បន្តជំរុញកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ជាមួយមជ្ឈមណ្ឌលអាស៊ាន-ចិន មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ និងសហការជាមួយមជ្ឈមណ្ឌលទាំង៣នេះ ក្នុងការរៀបចំសិក្ខាសាលាលើការពង្រឹងសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍ ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍
- ជំរុញផ្សព្វផ្សាយគោលដៅទេសចរណ៍ជាពិសេសទេសចរណ៍វប្បធម៌ និងធម្មជាតិកម្ពុជា-ឥណ្ឌា បង្កើតការយល់ដឹង និងជំរុញផ្សព្វផ្សាយតំបន់គោលដៅទេសចរណ៍ និងខ្សែទស្សនកិច្ចព្រះពុទ្ធសាសនា និងធម្មយាត្រា ប្រវត្តិសាស្ត្រ វប្បធម៌-ធម្មជាតិ និងជំរុញវិនិយោគវិស័យទេសចរណ៍
- ត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមការងាររួម ស្តីពីកិច្ចសហប្រតិបត្តិការកម្ពុជា-ថៃ លើកទី៨ កិច្ចប្រជុំក្រុមការងាររួម ស្តីពីកិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម លើកទី៤ កិច្ចប្រជុំក្រុមការងាររួម ស្តីពីកិច្ចសហប្រតិបត្តិការកម្ពុជា-ឡាវ លើកទី៤ កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ទ្វេភាគីកម្ពុជា-ឡាវ លើកទី២ និងពិធីបុណ្យម្ហូបអាហារកម្ពុជា-ឡាវ-ថៃ-វៀតណាម
- បន្តដាក់ចេញយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍រួមកម្ពុជា-ឥណ្ឌា "ប្រទេសពីរ គោលដៅមួយ"
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ជាមួយអង្គការជាតិ និងអន្តរជាតិ និងពិនិត្យលទ្ធភាពក្នុងការជំរុញលើសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នា
- ចូលរួមពិព័រណ៍ទេសចរណ៍ចំនួន ៩ ដែលមានក្នុងប្រតិទិនព្រឹត្តិការណ៍ និងពិព័រណ៍ទេសចរណ៍អន្តរជាតិរបស់ក្រសួងទេសចរណ៍ រួមមាន៖ ASEAN Tourism Forum (ATF), Outbound Travel Mart (OTM), Astindo Travel Fair, International Tourismus Borse (ITB Berlin), Seoul International Fair (SITF), Guangzhou International Travel Fair (GITF), Thailand Travel Mart Plus (TTM+), ITE HCMC និងរាត្រីកម្ពុជា និង Tourism Expo Japan
- បន្តសិក្សាស្រាវជ្រាវ និងរៀបចំចងក្រងផែនការយុទ្ធសាស្ត្រទីផ្សារទេសចរណ៍លើទីផ្សារសំខាន់ៗ ជំរុញការផ្សព្វផ្សាយអំពីទេសចរណ៍ម្ហូបអាហារកម្ពុជា (Cambodia Gastronomy Tourism) ត្រៀមផ្សព្វផ្សាយនិងអនុវត្តយុទ្ធនាការ Two Kingdoms One Destination, Three Countries One Destination, Six Countries One Destination ជាមួយបណ្តាប្រទេសក្នុងតំបន់

- បន្តសហការផ្សព្វផ្សាយជាមួយដៃគូសារព័ត៌មានអន្តរជាតិ ដូចជា៖ BLOOMBERG, TRAVEL WEEKLY ASIA, ASEAN JAPAN CENTER, ASEAN CHINA CENTER, ASEAN KOREA CENTER, ASEANTA
- "ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ឆ្នាំ២០២៤"
    - កំណត់យកឆ្នាំ២០២៥ ជា "**ឆ្នាំទេសចរណ៍កម្ពុជា-ចិន**"។
- យុទ្ធនាការ "ឆ្នាំទេសចរណ៍កម្ពុជា-ឥណ្ឌា"
    - បន្តកំណត់យកឆ្នាំ២០២៥ ជា "**ឆ្នាំទេសចរណ៍កម្ពុជា-ឥណ្ឌា**"។
- យុទ្ធនាការ "ឆ្នាំទស្សនាសៀមរាប"
    - គ្រោងរៀបចំព្រឹត្តិការណ៍ "ការសម្តែងសិល្បៈអន្តរជាតិ (Mozart Angkor)" ឆ្នាំ២០២៥
    - គ្រោងរៀបចំព្រឹត្តិការណ៍ទេសចរណ៍សាសនា នៅខេត្តសៀមរាប។

## ២. ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងការពង្រឹងគុណភាពអាជីវកម្ម សេវាកម្មទេសចរណ៍

- បន្តជំរុញការកៀងគរចំណូលពីអាជ្ញាបណ្ណទេសចរណ៍ និងចំណាត់ថ្នាក់សេវាកម្មទេសចរណ៍ ឱ្យបានស្របតាមផែនការកៀងគរចំណូលប្រចាំឆ្នាំ២០២៥របស់ក្រសួងទេសចរណ៍
- បន្តពង្រឹងគុណភាពសេវាកម្មទេសចរណ៍ "**សេវាមួយ ស្តង់ដាមួយ**"
- បន្តតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានារបស់ផ្នែកឯកជនក្នុងវិស័យទេសចរណ៍ តាមរយៈយន្តការក្រុមការងាររាជរដ្ឋាភិបាល-ផ្នែកឯកជនក្នុងវិស័យទេសចរណ៍
- បន្តពង្រឹង និងពង្រីកវគ្គបណ្តុះបណ្តាលអ្នកជំនាញវិជ្ជាជីវៈទេសចរណ៍ និងគ្រូបង្គោលជំនាញថ្នាក់ជាតិ និងអាស៊ានស្របតាមផែនការអភិវឌ្ឍន៍ធនធានមនុស្ស
- បន្តបើកវគ្គមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ និងវគ្គពិសេសក្នុងឆ្នាំ២០២៥
- ចុះវាយតម្លៃទីក្រុងស្អាតសម្រាប់ឆ្នាំ២០២៥-២០២៨ នៅតាមក្រុង ស្រុក ខណ្ឌទូទាំងប្រទេស
- បន្តពង្រឹងការអនុវត្តយុទ្ធនាការ "**ទីក្រុងស្អាត រមណីយដ្ឋាន សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**"។

## ៣. ការអភិវឌ្ឍធនធានមនុស្ស ការងារស្ថិតិទេសចរណ៍ និងគោលនយោបាយ

- បន្តប្រមូល រៀបចំ ចងក្រង វិភាគ និងផ្សព្វផ្សាយទិន្នន័យស្ថិតិទេសចរណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ និងបោះពុម្ពសៀវភៅរបាយការណ៍ស្ថិតិទេសចរណ៍ ឆ្នាំ២០២៥ សម្រាប់បម្រើសេចក្តីត្រូវការ ដល់អ្នកស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ និងអ្នកប្រើប្រាស់ ទិន្នន័យស្ថិតិទេសចរណ៍ ទាំងកម្រិតជាតិ និងអន្តរជាតិ
- បន្តផ្ញើរបាយការណ៍ទិន្នន័យស្ថិតិទេសចរណ៍កម្ពុជា ផ្ញើទៅគ្រប់ស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍ
- កសាងប្រមូលទិន្នន័យទេសចរណ៍ឌីជីថល (Digital tourism database: www.tourism.gov.kh) និងរៀបចំកសាងកម្មវិធី Software លើទូរស័ព្ទដៃសម្រាប់ផ្សព្វផ្សាយស្ថិតិទេសចរណ៍
- បន្តរៀបចំ ចងក្រងគណនីរណបទេសចរណ៍ (TSA: Tourism Satellite Account) ជាជំហានដំបូង ដែលមានសកម្មភាពចំនួន ១០

- ត្រៀមរៀបចំសិក្ខាសាលាពិគ្រោះយោបល់ដើម្បីជាតុចូល ស្តីពី "**ការអនុវត្តគោលនយោបាយជាតិលើវិស័យទេសចរណ៍ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន**" ក្នុងបរិការណ៍ឌីជីថល នៅខេត្តប៉ៃលិន
- ត្រៀមរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ពីផលប៉ះពាល់នៃវិស័យទេសចរណ៍មកលើ សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន នៅខេត្តកោះកុង
- រៀបចំសកម្មភាពសម្រាប់ធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិលើវិស័យទេសចរណ៍
- បន្តបង្កើនកិច្ចសហការស្រាវជ្រាវជាមួយគ្រឹះស្ថានសិក្សាទេសចរណ៍ជាតិ និងអន្តរជាតិ ដើម្បីផ្លាស់ប្តូរ បទពិសោធក្នុងការស្រាវជ្រាវ និងការរៀបចំគោលនយោបាយក្នុងវិស័យទេសចរណ៍
- រៀបចំបង្កើតក្រុមការងាររបស់ក្រសួងទេសចរណ៍ ដើម្បីពិភាក្សាជាមួយសកលវិទ្យាល័យយុណាន មីនជូ នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីអនុវត្តអនុស្សរណៈយោគយល់គ្នា (MOU) ក្រោមកិច្ចសហប្រតិបត្តិការលើកកម្ពស់ និងគាំទ្រការអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យទេសចរណ៍
- បន្តកិច្ចសហប្រតិបត្តិការជាមួយប្រតិភូមជ្ឈមណ្ឌល សហប្រតិបត្តិការ និងផ្លាស់ប្តូរអន្តរជាតិ នៃមន្ទីរពាណិជ្ជកម្មខេត្តហៃណាន សាធារណរដ្ឋប្រជាមានិតចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការលើការបណ្តុះបណ្តាល មន្ត្រីរាជការរបស់ក្រសួងទេសចរណ៍
- បន្តសហការជាមួយសកលវិទ្យាល័យសេដ្ឋកិច្ចវៀតណាម ក្រោមកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងការចែករំលែកលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីការអភិវឌ្ឍសេដ្ឋកិច្ចបៃតង "Green Growth Development"
- បន្តសហការជាមួយមជ្ឈមណ្ឌលសង្គមសិក្សាស្រាវជ្រាវសារ៉ាវ៉ាក់នៃប្រទេសម៉ាឡេស៊ី ក្នុងការតាមដាន អង្កេតសកម្មភាពស្រាវជ្រាវលើការអភិវឌ្ឍវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចដោយទទួលខុសត្រូវ និងមាននិរន្តរភាពនៅក្នុងតំបន់
- បន្តសហការជាមួយមជ្ឈមណ្ឌលបណ្ឌិត្យសភាវប្បធម៌ និងទេសចរណ៍ចិនដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការកម្ពុជា-ចិន ក្នុងគោលបំណងលើកស្ទួយកិច្ចសហប្រតិបត្តិការកម្ពុជា-ចិន "ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥"
- បន្តលើកកម្ពស់សមត្ថភាពមន្ត្រីរាជការតាមរយៈការបណ្តុះបណ្តាល ដោយសហការជាមួយដៃគូជាតិ និងអន្តរជាតិ

## ៤. ការគ្រប់គ្រង និងសម្រួលការធ្វើដំណើរទេសចរណ៍

- បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការសម្រួលការធ្វើដំណើរ និងពង្រឹងសមត្ថភាពបដិសណ្ឋារកិច្ចស្វាគមន៍ភ្ញៀវទេសចរនៅច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីផ្តល់ភាពកក់ក្តៅ ភាពរួសរាយរាក់ទាក់ និងបទពិសោធន៍ល្អក្នុងការធ្វើដំណើរ។

## ៥. ការពង្រឹងយន្តការអភិបាលកិច្ចទេសចរណ៍

- បន្តពង្រឹងការគ្រប់គ្រង និងរបៀបរបបការងារគោចរលិខិតតាមបែបបទនីតិវិធីរដ្ឋបាល ការងារពិធីការ ការធ្វើរបាយការណ៍បូកសរុប និងកំណត់ហេតុអង្គប្រជុំនានា ដោយបញ្ចូលការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កភាពងាយស្រួល និងឆាប់រហ័ស

- លើកកម្ពស់ការពង្រឹងសន្តិសុខសុវត្ថិភាពទេសចរនៅតាមបណ្តាមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ និងចូលរួមអនុវត្តសកម្មភាពគាំទ្រដល់សន្តិសុខនិងសុវត្ថិភាពទេសចរ និងភាពទាក់ទាញកម្ពុជា
- បន្តពង្រឹងយុទ្ធនាការ លុបបំបាត់ជំងឺគ្រុនចាញ់ក្នុងវិស័យទេសចរណ៍ នៅតាមបណ្តាខេត្តគោលដៅដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ២០២៥
- បន្តជំរុញការងារកំណែទម្រង់រដ្ឋបាលសាធារណៈក្រសួងទេសចរណ៍
- បន្តសហការជាមួយលេខាធិការដ្ឋានកំណែទម្រង់រដ្ឋបាលសាធារណៈដើម្បីពិនិត្យឡើងវិញវិភាគមុខងារ រចនាសម្ព័ន្ធរបស់ក្រសួងទេសចរណ៍
- បន្តពិនិត្យ និងសម្រួលរចនាសម្ព័ន្ធរបស់ក្រសួងទេសចរណ៍។

## ៦. យន្តការគាំទ្រវិស័យទេសចរណ៍

- បន្តរៀបចំសេចក្តីសម្រេចរួម រវាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងក្រសួងទេសចរណ៍ សម្រាប់ឆ្នាំ២០២៥
- បន្តចុះពិនិត្យ វាយតម្លៃ និងគាំទ្របច្ចេកទេសដល់រដ្ឋបាលរាជធានី ខេត្ត (អង្គភាពច្រកចេញចូលតែមួយ) មន្ទីរជំនាញ និងរដ្ឋបាលក្រុង ស្រុក លើការងារគ្រប់គ្រង ដឹកនាំ ចាត់ចែង និងអនុវត្តមុខងារវិស័យទេសចរណ៍ បានផ្ទេរ និងប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បន្តរៀបចំការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ នីតិវិធី បែបបទ និងបច្ចេកទេសនៃការអនុវត្តមុខងាររបស់មន្ត្រីអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញ
- បន្តសហការរៀបចំទីក្រុងទេសចរណ៍គ្មានផ្សែងបារីនៅឆ្នាំ២០២៥ នៅតាមក្រុង/ស្រុក/ខណ្ឌដែលជាគោលដៅទាក់ទាញទេសចរណ៍
- បន្តអនុវត្តសូចនាករដែលក្រសួងទេសចរណ៍ត្រូវបំពេញស្របតាម **"គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨"** របស់រាជរដ្ឋាភិបាល និងលើកកម្ពស់ការទប់ស្កាត់ការរីករាលមេរោគអេដស៍ ជំងឺអេដស៍ នៅតាមបណ្តាខេត្តគោលដៅ

## ៧. ការងារសាលាវិជ្ជាជីវៈទេសចរណ៍

- រៀបចំប្រគល់ ទទួលអគារសាលាវិជ្ជាជីវៈទេសចរណ៍ទាំង២ នៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ
- បន្តជំរុញការបំពាក់សម្ភារៈ និងឧបករណ៍ បរិក្ខាសម្រាប់ការបណ្តុះបណ្តាល និងសម្ភារៈការិយាល័យឱ្យចប់សព្វគ្រប់ នៅត្រីមាសទី១ ឆ្នាំ២០២៥
- បន្តជំរុញការរៀបចំអនុក្រឹត្យស្តីពីការបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអនុក្រឹត្យ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលសាលាវិជ្ជាជីវៈទេសចរណ៍
- បន្តរៀបចំអនុក្រឹត្យ និងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពចំណុះសាលា
- ជ្រើសរើសមន្ត្រី បុគ្គលិក និងគ្រូ សម្រាប់បម្រើការងារនៅសាលាវិជ្ជាជីវៈទេសចរណ៍ ដំណាក់កាលដំបូង សម្រាប់ឆ្នាំ២០២៥ ដើម្បីអនុវត្តការងារសាលា ឆ្ពោះទៅការដាក់ឱ្យដំណើរកាលនៅត្រីមាសទី៣ ឆ្នាំ២០២៥

- រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល និងមន្ត្រី
- រៀបចំផែនការសកម្មភាព និងថវិកា៖ មានគម្រោងថវិកាសាលាឆ្នាំ២០២៥ និងបន្តរៀបចំផែនការសកម្មភាព ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៦-២០២៨
- បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំតារាងតុល្យការទុនគ្រាដំបូង និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- រៀបចំបណ្តាញឌីជីថល វេបសាយ ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រង (SMS) និងប្រព័ន្ធបណ្តុះបណ្តាលតាមអនឡាញ (LMS)
- រៀបចំកម្មវិធីសម្ពោធជាផ្លូវការ នៅត្រីមាសទី៤ ឆ្នាំ២០២៥។

## VII. សេចក្តីសន្និដ្ឋាន

សមិទ្ធផលដ៏ធំធេង និងជាទីមោទនៈ ដែលវិស័យទេសចរណ៍សម្រេចបានក្នុងឆ្នាំ ២០២៤ កន្លងមកនេះ ពោលគឺការទទួលបាននូវទេសចរអន្តរជាតិប្រមាណ ៦,៧ លាននាក់ ធៀប ២០១៩ (មុនវិបត្តិកូវីដ-១៩) ទទួលបានចំនួនជាង ៦,៦ លាននាក់ ព្រមទាំងទេសចរផ្ទៃក្នុងកើនដល់ជាង ២២,៥ លាននាក់ នេះសបញ្ជាក់ច្បាស់ថាពិតជាមិនអាចកាត់ផ្តាច់ចេញពីការខិតខំប្រឹងប្រែង យកចិត្តទុកដាក់ និងការដឹកនាំចង្អុលបង្ហាញដោយផ្ទាល់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រគន្លឹះនានា រួមទាំងការចូលរួមយ៉ាងសកម្មក្នុងការជំរុញ គាំទ្រ និងសហការអនុវត្តពីបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ប្រជាពលរដ្ឋ និងជាពិសេស **ឯកឧត្តមរដ្ឋមន្ត្រី** ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការក្រសួងទេសចរណ៍ តាំងពីថ្នាក់ជាតិរហូតដល់រាជធានីខេត្ត ដែលបានខិតខំយកអស់កម្លាំងកាយចិត្ត រួមសាមគ្គីគ្នាចូលរួមជំរុញ និងអនុវត្តការងារ ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។ ស្របនឹងកំណើនឡើងវិញនៃចំនួនទេសចរ មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ក៏មានសន្ទុះរីកចម្រើននៅតាមគោលដៅទេសចរណ៍ នៅទូទាំងប្រទេស ដោយស្តារបាន និងផ្តល់ឱកាសការងារបន្ថែមជូនប្រជាពលរដ្ឋ និងជំរុញសកម្មភាពសេដ្ឋកិច្ចផ្ទៃក្នុងកាន់តែប្រសើរឡើង។ តាមការព្យាករកម្ពុជាអាចនឹងទទួលបានការទស្សនារបស់ទេសចរអន្តរជាតិប្រមាណពី ៧,២ ទៅ ៧,៥ លាននាក់ និងទេសចរជាតិប្រមាណពី ២២,៦៣ ទៅ ២៣ លាននាក់ នៅឆ្នាំ២០២៥។

ស្ថិតក្នុងបរិការណ៍នៃនិន្នាការមិនប្រាកដប្រជានាពេលបច្ចុប្បន្នរបស់ពិភពលោក ដែលបណ្តាលមកពីកត្តាសង្គ្រាម ភាពរឹតរវផ្នែកសេដ្ឋកិច្ច ការប្រកួតប្រជែងរបស់មហាអំណាច គ្រោះធម្មជាតិ វិស័យទេសចរណ៍កម្ពុជាបាននិងកំពុងបន្តប្រឈមបញ្ហាខាងក្រៅ និងខាងក្នុងមួយចំនួនដូចជា៖ ការប្រែប្រួលស្ថានភាពទីផ្សារទេសចរណ៍សកលលោក និងតំបន់បណ្តាលមកពីភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច គោលនយោបាយសន្តិសុខបច្ចេកវិទ្យាសុវត្ថិភាពភ្ញៀវ ការកើនឡើងថ្លៃនៃការធ្វើដំណើរ និងផលិតផលទេសចរណ៍ កម្លាំងនៃការប្រកួតប្រជែង ការងារឃោសនាផ្សព្វផ្សាយ គុណភាពសេវាកម្ម ព្រមទាំងការចូលរួមជំរុញគាំទ្រពីភាគីពាក់ព័ន្ធ។

ជាការឆ្លើយតប ការជំរុញរៀបចំគោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ អមដោយយន្តការអនុវត្ត និងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព បន្តគិតគូរលើការជំរុញពិពិធកម្ម គំនិតច្នៃប្រឌិត នវានុវត្តន៍ដើម្បីបង្កើនឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជាទាំងកម្រិតតំបន់ និងសកលលោក គឺជាប្រការដ៏ចាំបាច់។

ការគ្រប់គ្រង និងអភិវឌ្ឍគោលដៅទេសចរណ៍ ការជំរុញសកម្មភាពទេសចរណ៍ផ្ទៃក្នុង និងការទាក់ទាញទេសចរអន្តរជាតិក្នុងការទស្សនាកម្សាន្ត ព្រមទាំងការធ្វើធុរកិច្ចប្រកបដោយសុវត្ថិភាព ផាសុកភាព និងទទួលបានផលប្រយោជន៍សេដ្ឋកិច្ច សង្គម។ ការអប់រំលើកទឹកចិត្ត ការយល់ច្បាស់អំពីសារៈសំខាន់របស់វិស័យទេសចរណ៍ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដោយឈរលើអភិក្រមនៃភាពជាដៃគូ ចតុភាគី "**រដ្ឋ ឯកជន ប្រជាពលរដ្ឋ ដៃគូ អភិវឌ្ឍន៍**" ចាំបាច់ត្រូវតែទទួលបានការយកចិត្តទុកដាក់ពង្រឹងឱ្យកាន់តែល្អប្រសើរបន្ថែមទៀត។

ការអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព និងបរិយាបន្ន គឺពិតជាមានសារៈសំខាន់សម្រាប់រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម នាំមកនូវចំណូល បង្កើតនិងបង្កើនឱកាសមុខរបរ និងការងារ និងលើកស្ទួយកិត្តិនាមកម្ពុជាលើឆាកអន្តរជាតិ ព្រមទាំងធ្វើឱ្យកម្ពុជា "**ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ**" ជាគោលដៅទេសចរណ៍លំដាប់ពិភពលោក ប្រកបដោយភាពរីករាយ សុខសុវត្ថិភាព និងផាសុកភាព "**ជាទឹកដីពិសិដ្ឋ**" សម្រាប់ការទស្សនានិងរស់នៅ៕

# ឧបសម្ព័ន្ធ ១

# របាយការណ៍ស្ថិតិទេសចរណ៍

# ឆ្នាំ២០២៤

# Key results

## *International tourist arrivals recover pre-pandemic levels in 2024*

- International tourism virtually recovered (99%) pre-pandemic levels in 2024, with most destinations exceeding 2019 numbers.
- 2024 marks the consolidation of international tourism recovery from its worst crisis ever, four years after the outbreak of the COVID-19 pandemic.
- An estimated 1.4 billion international tourists (overnight visitors) were recorded around the world in 2024, an increase of 11% over 2023, or 140 million more.
- Results were driven by strong post-pandemic demand, robust performance from large source markets globally, as well as the ongoing recovery of destinations in Asia and the Pacific.
- The Middle East remained the strongest-performing region when compared to 2019, with international arrivals climbing 32% above pre-pandemic levels in 2024, though 1% compared to 2023.
- Europe welcomed 1% more arrivals than in 2019 and 5% over 2023, while Africa saw a 7% increase in arrivals compared to 2019 and 12% more than in 2023.
- The Americas recovered 97% (-3% over 2019) of its pre-pandemic arrivals, and Asia and the Pacific 87% (-13% over 2019).
- By subregions, North Africa (+22%) and Central America (+17%) saw the strongest performance in 2024 over 2019.
- According to preliminary estimates, receipts reached USD 1.6 trillion in 2024, about 3% more than in 2023 and 4% more than in 2019 (real terms). International tourism receipts had already recovered pre-pandemic levels in 2023. Total export revenues from tourism (receipts and passenger transport) are estimated at a record USD 1.9 trillion in 2024, about 3% higher than 2019.
- International tourist arrivals are expected to grow 3% to 5% in 2025 compared to 2024.
- Based on the latest survey of UN Tourism Panel Experts, about 64% of professionals expect 'better' or 'much better' performance in 2025 compared to 2024.
- The positive outlook for the sector is reflected in the latest UN Tourism Confidence Index, with a score of 130 for 2025 (on a scale of 0 to 200 where 100 indicates similar expected performance).
- Economic and geopolitical challenges continue to pose significant risks to confidence levels.

**International Tourist Arrivals** (% change over 2019)




Source: UN Tourism (January 2025) * Provisional data

**International Tourism Receipts** (% change over 2019)[1]




Source: UN Tourism (January 2025) * Provisional data

[1]Local currencies, constant prices

## Inbound tourism

### *International tourist arrivals reach 1.4 billion in 2024, an increase of 11% over 2023*

- International tourist arrivals virtually recovered (99%) pre-pandemic levels in 2024, with most destinations exceeding 2019 numbers.
- 2024 marks the consolidation of the recovery of international tourism from its worst crisis ever, four years after the outbreak of the COVID-19 pandemic.
- An estimated 1.4 billion international tourists (overnight visitors) were recorded around the world in 2024, an increase of 11% over 2023, or 140 million more.
- Results were driven by strong post-pandemic demand, robust performance from large source markets globally, as well as the ongoing recovery of destinations in Asia and the Pacific. Increased air connectivity and enhanced visa facilitation also supported international travel.
- The last three months of the year were particularly strong, with arrivals exceeding pre-pandemic levels by 3%, 1% and 1% respectively.
- The year 2024 saw extraordinary levels in visitor spending, with tourism earnings growing faster than arrivals in many destinations, compared to 2019.
- The complete recovery of international tourism is in line with the scenarios for 2021-2024 prepared by UN Tourism in December 2020, which pointed to a recovery to 2019 levels in 2-and-half to 4 years. Results fall within the third scenario, which projected a return to pre-pandemic years by the end of 2024.
- While a global recovery was achieved in 2024, results vary across regions. Europe, the Middle East and Africa all surpassed pre-pandemic numbers in 2024, while the Americas came close (-3%) and Asia and the Pacific remained 13% below 2019 levels due to slower lifting of restrictions.

### *The Middle East, Europe and Africa performed strongest in 2024 as compared to 2019*

- The **Middle East** (95 million arrivals) remained the strongest-performing region when compared to 2019, with international arrivals climbing 32% above pre-pandemic levels in 2024, though 1% compared to 2023.
- Some Middle Eastern destinations reported strong results in the first ten to twelve months of 2024 when compared to 2019, among which Qatar (+137%), Saudi Arabia (+69%) and Egypt (+23%).
- **Africa** (74 million) welcomed 7% more arrivals compared to 2019 and 12% more than in 2023. Ethiopia (+40%), and Morocco (+35%) both reported double-digit growth and Tunisia (+9%), Kenya (+9%) also exceeded 2019 numbers.
- **Europe**, the world's largest destination region, saw 747 million international arrivals in 2024 (+1% above 2019 and 5% over 2023), supported by strong intraregional demand. All subregions surpassed pre-pandemic levels, except for Central and Eastern Europe where many destinations are still suffering from the lingering effects of the Russian aggression on Ukraine.
- The highest growth in Europe in the first ten to twelve months of 2024 was reported by Albania (+80%), Andorra (+35%), Malta and Serbia (both +29%), where arrivals climbed well above 2019 figures.
- Among the larger destinations, Portugal reported 18% more arrivals than in 2019 and Denmark 17% more, while Greece and Türkiye both recorded 14% more and Spain 10%. A total of 21 European destinations surpassed pre-pandemic levels during this period.
- The **Americas** (213 million) recovered 97% of pre-pandemic arrivals with the Caribbean and Central America already exceeding 2019 levels fueled by strong US outbound travel. The region saw a 7% growth over 2023.
- El Salvador (+81%), Curaçao (+51%), Colombia (+37%), Guatemala, (+33%), the Dominican Republic (+32%), Aruba (+27%), Panama (+17%) and Chile (+16%) were among the strongest performers in the first ten to twelve months of 2024 when compared to pre-pandemic levels.
- **Asia and the Pacific** (316 million) continued to experience a rapid recovery, where arrivals reached 87% of its pre-pandemic numbers as compared to 66% at the end of 2023. International arrivals grew 33% in 2024, an increase of 78 million from 2023.

**International Tourist Arrivals by (Sub)region**

(Percent changes are over 2019)

| | (millions) | | | | | | Share (%) | Change (%) over 2019² | | | | | Half-yearly/ quarterly data series Change (%) 2024 over 2019 | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2019 | 2020 | 2021 | 2022 | 2023 | 2024* | 2024* | 20/19 | 21/19 | 22/19 | 23/19 | 24/19* | H1 | H2 | Q1 | Q2 | Q3 | Q4 |
| **World** | **1465** | **406** | **460** | **975** | **1305** | **1445** | **100** | **-72.3** | **-68.6** | **-33.4** | **-10.9** | **-1.3** | **-2.6** | **-0.2** | **-2.1** | **-3.0** | **-1.4** | **1.6** |
| Advanced economies¹ | *776* | *221* | *240* | *546* | *716* | *775* | *53.6* | *-71.5* | *-69.0* | *-29.6* | *-7.7* | *-0.1* | *-1.0* | *0.7* | *-0.4* | *17.5* | *15.8* | *27.3* |
| Emerging economies¹ | *689* | *186* | *220* | *429* | *589* | *670* | *46.4* | *-73.1* | *-68.1* | *-37.7* | *-14.5* | *-2.8* | *-4.5* | *-1.2* | *-3.8* | *-1.4* | *-0.1* | *2.0* |
| *By UNWTO regions:* | | | | | | | | | | | | | | | | | | |
| ***Europe*** | ***742.4*** | ***239.4*** | ***301.3*** | ***609.5*** | ***708.4*** | ***747.3*** | ***51.7*** | ***-67.8*** | ***-59.4*** | ***-17.9*** | ***-4.6*** | ***0.7*** | ***1.5*** | ***0.1*** | ***2.2*** | ***1.0*** | ***-0.6*** | ***1.4*** |
| Northern Europe | 82.1 | 23.7 | 21.9 | 67.1 | 78.3 | 85.8 | 5.9 | -71.1 | -73.3 | -18.3 | -4.7 | 4.6 | 4.6 | 4.5 | 5.7 | 3.8 | 4.7 | 4.2 |
| Western Europe | 205.2 | 83.5 | 87.6 | 182.8 | 207.9 | 209.7 | 14.5 | -59.3 | -57.3 | -10.9 | 1.3 | 2.2 | 3.0 | 1.6 | 4.7 | 1.9 | 2.3 | 0.3 |
| Central/Eastern Eur. | 150.9 | 43.8 | 53.0 | 94.1 | 113.7 | 123.4 | 8.5 | -71.0 | -64.9 | -37.7 | -24.7 | -18.2 | -20.7 | -18.9 | -19.9 | -21.3 | -20.4 | -16.7 |
| Southern/Medit. Eur. | 304.2 | 88.4 | 138.9 | 265.5 | 308.5 | 328.4 | 22.7 | -71.0 | -54.4 | -12.7 | 1.4 | 7.9 | 10.3 | 6.3 | 12.3 | 9.3 | 4.1 | 11.0 |
| *- of which EU-27* | *539.2* | *182.8* | *222.3* | *454.3* | *525.6* | *551.1* | *38.1* | *-66.1* | *-58.8* | *-15.7* | *-2.5* | *2.2* | *3.1* | *1.6* | *4.2* | *2.5* | *0.8* | *3.0* |
| ***Asia and the Pacific*** | ***362.7*** | ***58.9*** | ***26.7*** | ***93.3*** | ***237.7*** | ***315.9*** | ***21.9*** | ***-83.7*** | ***-92.6*** | ***-74.3*** | ***-34.4*** | ***-12.9*** | ***-17.7*** | ***-7.7*** | ***-18.5*** | ***-16.9*** | ***-9.2*** | ***-6.3*** |
| North-East Asia | 170.3 | 20.3 | 10.9 | 20.5 | 94.9 | 146.1 | 10.1 | -88.1 | -93.6 | -88.0 | -44.3 | -14.2 | -23.1 | -4.3 | -25.0 | -21.3 | -7.6 | -0.9 |
| South-East Asia | 138.6 | 25.5 | 3.3 | 42.3 | 99.0 | 121.8 | 8.4 | -81.6 | -97.6 | -69.5 | -28.6 | -12.1 | -12.3 | -11.0 | -13.4 | -11.0 | -11.4 | -10.7 |
| Oceania | 17.5 | 3.6 | 0.9 | 6.8 | 12.9 | 14.5 | 1.0 | -79.4 | -95.1 | -61.3 | -26.3 | -17.2 | -16.5 | -18.5 | -14.9 | -18.5 | -19.6 | -17.5 |
| South Asia | 36.3 | 9.6 | 11.7 | 23.8 | 30.9 | 33.4 | 2.3 | -73.5 | -67.8 | -34.4 | -14.8 | -7.8 | -11.7 | -4.7 | -9.3 | -14.6 | -1.3 | -7.5 |
| ***Americas*** | ***219.3*** | ***69.7*** | ***81.8*** | ***157.2*** | ***200.1*** | ***213.5*** | ***14.8*** | ***-68.2*** | ***-62.7*** | ***-28.3*** | ***-8.8*** | ***-2.6*** | ***-3.3*** | ***-2.1*** | ***-0.2*** | ***-6.3*** | ***-4.5*** | ***0.4*** |
| North America | 146.6 | 46.5 | 57.2 | 101.9 | 126.8 | 137.1 | 9.5 | -68.3 | -61.0 | -30.5 | -13.5 | -6.5 | -6.8 | -6.3 | -3.7 | -9.3 | -8.1 | -4.2 |
| Caribbean | 26.1 | 10.4 | 14.5 | 23.6 | 28.1 | 28.0 | 1.9 | -60.1 | -44.4 | -9.7 | 7.9 | 7.3 | 6.6 | 7.8 | 6.9 | 6.2 | 7.6 | 7.9 |
| Central America | 10.9 | 3.1 | 4.7 | 9.3 | 11.5 | 12.8 | 0.9 | -71.6 | -57.1 | -15.3 | 5.4 | 17.4 | 17.4 | 17.3 | 18.2 | 16.6 | 15.7 | 18.7 |
| South America | 35.6 | 9.8 | 5.3 | 22.4 | 33.6 | 35.6 | 2.5 | -72.6 | -85.0 | -37.1 | -5.6 | -0.1 | -4.2 | 4.2 | 0.0 | -10.0 | -0.4 | 8.5 |
| ***Africa*** | ***68.8*** | ***18.8*** | ***19.9*** | ***47.2*** | ***65.6*** | ***73.6*** | ***5.1*** | ***-72.7*** | ***-71.1*** | ***-31.4*** | ***-4.7*** | ***6.9*** | ***6.3*** | ***8.4*** | ***5.9*** | ***6.6*** | ***5.7*** | ***11.7*** |
| North Africa | 25.6 | 5.6 | 6.6 | 19.1 | 26.9 | 31.3 | 2.2 | -78.2 | -74.4 | -25.4 | 5.0 | 22.1 | 23.4 | 22.1 | 23.0 | 23.7 | 14.1 | 34.9 |
| Subsaharan Africa | 43.2 | 13.3 | 13.3 | 28.1 | 38.7 | 42.3 | 2.9 | -69.3 | -69.2 | -35.0 | -10.5 | -2.1 | -5.0 | -3.1 | -3.8 | -6.2 | -3.2 | -3.0 |
| ***Middle East*** | ***71.6*** | ***19.4*** | ***30.5*** | ***68.0*** | ***93.5*** | ***94.8*** | ***6.6*** | ***-72.9*** | ***-57.4*** | ***-5.1*** | ***30.5*** | ***32.4*** | ***34.4*** | ***32.6*** | ***42.3*** | ***26.1*** | ***25.4*** | ***40.2*** |
| *Memorandum³* | | | | | | | | | | | | | | | | | | |
| ASEAN | 138.6 | 25.5 | 3.3 | 42.3 | 99.0 | 121.7 | 8.4 | -81.6 | -97.6 | -69.5 | -28.6 | -12.1 | -12.3 | -11.0 | -13.5 | -11.0 | -11.4 | -10.7 |
| G20 | 1000.4 | 300.1 | 348.4 | 719.0 | 899.7 | 991.7 | 68.6 | -70.0 | -65.2 | -28.1 | -10.1 | -0.9 | -1.5 | -0.4 | -0.5 | -2.1 | -1.6 | 1.6 |
| GCC | 47.7 | 13.4 | 18.3 | 47.8 | 68.2 | 69.0 | 4.8 | -71.9 | -61.7 | 0.1 | 42.8 | 44.7 | 46.2 | 43.1 | 56.3 | 34.7 | 34.9 | 51.1 |
| LDCs | 34.2 | 9.8 | 7.5 | 17.1 | 27.4 | 30.9 | 2.1 | -71.3 | -78.0 | -50.0 | -19.8 | -9.5 | -12.2 | -9.5 | -16.1 | -7.9 | -7.8 | -11.0 |
| LLDCs | 50.2 | 12.0 | 13.1 | 31.9 | 44.5 | 49.7 | 3.4 | -76.2 | -73.8 | -36.4 | -11.4 | -1.1 | -3.3 | -0.5 | -5.8 | -1.1 | -0.5 | -0.5 |
| SIDS | 40.1 | 9.6 | 11.4 | 25.7 | 36.5 | 39.2 | 2.7 | -76.1 | -71.6 | -35.8 | -8.9 | -2.2 | -3.4 | -1.3 | -1.1 | -5.9 | -0.7 | -2.0 |

Source: World Tourism Organization (UN Tourism) (Data as collected by UN Tourism, January 2025)

* Provisional data

¹ Classification based on the International Monetary Fund (IMF).

² Arrows (↑) indicate percentage change above 1000. (See Methodological Notes).

³ ASEAN: Association of Southeast Asian Nations, G20: Group of Twenty, GCC: Gulf Cooperation Council, LDCs: Least Developed Countries, LLDCs: Landlocked Developing Countries, SIDS: Small Island Developing States. (See Methodological Notes)

See box in page 'A-2' for explanation of abbreviations and symbols used.

For regularly updated data, please check the *UN Tourism Tracker:* https://www.unwto.org/unwto-tourism-recovery-tracker

## Tourism Highlights

International Tourist Arrivals, Average Length of Stays, Hotel Occupancy, International Tourism Receipts & Tourism Sector Share to the GDP in 1993 - 2024

| Years | Int'l Tourist Arrivals | | Average Length | Hotel Occupancy | Int'l Tourism Receipts | Tourism Sector Share |
|---|---|---|---|---|---|---|
| | Number | Change (%) | of Stays (Days) | (%) | (Million USD) | to the GDP (%) |
| 1993 | 118,183 | - | N/A | N/A | N/A | |
| 1994 | 176,617 | 49.4 | N/A | N/A | N/A | |
| 1995 | 219,680 | 24.4 | 8.0 | 37.0 | 100 | |
| 1996 | 260,489 | 18.6 | 7.5 | 40.0 | 118 | |
| 1997 | 218,843 | -16.0 | 6.4 | 30.0 | 103 | |
| 1998 | 286,524 | 30.9 | 5.2 | 40.0 | 166 | |
| 1999 | 367,743 | 28.3 | 5.5 | 44.0 | 190 | |
| 2000 | 466,365 | 26.8 | 5.5 | 45.0 | 228 | |
| 2001 | 604,919 | 29.7 | 5.5 | 48.0 | 304 | |
| 2002 | 786,524 | 30.0 | 5.8 | 50.0 | 379 | |
| 2003 | 701,014 | -10.9 | 5.5 | 50.0 | 347 | |
| 2004 | 1,055,202 | 50.5 | 6.3 | 52.0 | 578 | 13.9 |
| 2005 | 1,421,615 | 34.7 | 6.3 | 52.0 | 832 | 14.1 |
| 2006 | 1,700,041 | 19.6 | 6.5 | 54.8 | 1,049 | 14.0 |
| 2007 | 2,015,128 | 18.5 | 6.5 | 54.8 | 1,400 | 13.9 |
| 2008 | 2,125,465 | 5.5 | 6.7 | 62.7 | 1,595 | 12.5 |
| 2009 | 2,161,577 | 1.7 | 6.5 | 63.6 | 1,561 | 9.9 |
| 2010 | 2,508,289 | 16.0 | 6.5 | 65.7 | 1,786 | 10.8 |
| 2011 | 2,881,862 | 14.9 | 6.5 | 66.2 | 1,912 | 10.8 |
| 2012 | 3,584,307 | 24.4 | 6.3 | 68.5 | 2,210 | 11.5 |
| 2013 | 4,210,165 | 17.5 | 6.8 | 69.5 | 2,547 | 12.0 |
| 2014 | 4,502,775 | 7.0 | 6.5 | 67.6 | 2,736 | 12.2 |
| 2015 | 4,775,231 | 6.1 | 6.8 | 70.2 | 3,012 | 12.0 |
| 2016 | 5,011,712 | 5.0 | 6.3 | 68.9 | 3,212 | 11.9 |
| 2017 | 5,602,157 | 11.8 | 6.6 | 71.3 | 3,638 | 12.3 |
| 2018 | 6,201,077 | 10.7 | 7.0 | 72.2 | 4,375 | 12.7 |
| 2019 | 6,610,592 | 6.6 | 6.2 | 63.5 | 4,919 | 12.1 |
| 2020 | 1,306,143 | -80.2 | Jan - Mar: 6.2<br>Apr - Dec: 30.0 | Jan - Mar: 78.9<br>Apr - Dec: 8.3 | 1,023 | 3.0 |
| 2021 | 196,495 | -85.0 | 30.0 | 15.5 | 184 | 1.8 |
| 2022 | 2,276,626 | 1058.6 | 13.5 | 75.1 | 1,415 | 3.6 |
| 2023 | 5,453,231 | 139.5 | 7.6 | 76.5 | 3,083 | 7.5 |
| 2024 | 6,700,125 | 22.9 | 7.1 | 77.8 | 3,637 | 9.4 |

**International Tourist Arrivals to Cambodia**

| Months | 2019 | 2020 | 2021 | 2022 | 2023 | 2024 | Change (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | 20/19 | 21/20 | 22/21 | 24*/19 | 2024*/23 |
| **Q1** | **1,877,853** | **1,155,226** | **70,901** | **159,546** | **1,291,539** | **1,582,677** | **-93.9** | **125.0** | **709.5** | **-15.7** | **22.5** |
| Jan | 647,206 | 547,963 | 20,567 | 44,910 | 402,943 | 540,023 | -96.2 | 118.4 | 797.2 | -16.6 | 34.0 |
| Feb | 597,483 | 383,863 | 20,580 | 50,411 | 434,503 | 448,551 | -94.6 | 145.0 | 761.9 | -24.9 | 3.2 |
| Mar | 633,164 | 223,400 | 29,754 | 64,225 | 454,093 | 594,103 | -86.7 | 115.9 | 607.0 | -6.2 | 30.8 |
| **Q2** | **1,460,621** | **27,600** | **31,659** | **347,216** | **1,288,393** | **1,583,820** | **14.7** | **996.7** | **271.1** | **8.4** | **22.9** |
| Apr | 537,656 | 4,841 | 11,938 | 81,939 | 430,129 | 533,932 | 146.6 | 586.4 | 424.9 | -0.7 | 24.1 |
| May | 472,952 | 10,475 | 8,757 | 101,979 | 442,114 | 524,390 | -16.4 | 1064.5 | 333.5 | 10.9 | 18.6 |
| Jun | 450,013 | 12,284 | 10,964 | 163,298 | 416,150 | 525,498 | -10.7 | 1389.4 | 154.8 | 16.8 | 26.3 |
| **Q3** | **1,475,832** | **64,854** | **29,114** | **759,010** | **1,346,950** | **1,634,035** | **-55.1** | **2507.0** | **77.5** | **10.7** | **21.3** |
| Jul | 502,421 | 20,689 | 9,984 | 236,697 | 457,412 | 575,733 | -51.7 | 2270.8 | 93.2 | 14.6 | 25.9 |
| Aug | 519,502 | 23,028 | 9,163 | 254,813 | 464,637 | 548,828 | -60.2 | 2680.9 | 82.3 | 5.6 | 18.1 |
| Sep | 453,909 | 21,137 | 9,967 | 267,500 | 424,901 | 509,474 | -52.8 | 2583.9 | 58.8 | 12.2 | 19.9 |
| **Q4** | **1,796,286** | **58,463** | **64,821** | **1,010,854** | **1,526,349** | **1,899,593** | **10.9** | **1459.5** | **51.0** | **5.8** | **24.5** |
| Oct | 481,782 | 20,210 | 12,759 | 310,182 | 480,330 | 574,206 | -36.9 | 2331.1 | 54.9 | 19.2 | 19.5 |
| Nov | 602,042 | 18,184 | 18,933 | 338,101 | 510,231 | 626,319 | 4.1 | 1685.8 | 50.9 | 4.0 | 22.8 |
| Dec | 712,462 | 20,069 | 33,129 | 362,571 | 535,788 | 699,068 | 65.1 | 994.4 | 47.8 | -1.9 | 30.5 |
| **Total** | **6,610,592** | **1,306,143** | **196,495** | **2,276,626** | **5,453,231** | **6,700,125** | **-85.0** | **1058.6** | **139.5** | **1.4** | **22.9** |




*Source: Tourism Statistics Department, MOT.*

## CAMBODIA: TOURISM STATISTICS REPORT IN 2024

### I. INBOUND TOURISM

1. International tourist arrivals in January - December 2024

| | Inbound tourism | | | | Share (%) | Change (%) | | |
|---|---|---|---|---|---|---|---|---|
| | 2019 | 2022 | 2023 | 2024 | 2024* | 23/22 | 24*/19 | 2024*/23 |
| **Air** | **4,403,995** | **791,603** | **1,866,231** | **2,396,937** | **35.8** | **135.8** | **-45.6** | **28.4** |
| Phnom Penh Int'l Airport (PNH) | 2,071,907 | 609,667 | 1,365,735 | 1,752,583 | 26.2 | 124.0 | -15.4 | 28.3 |
| Siem Reap Angkor Int'l Airport (SAI) | 1,665,365 | 165,180 | 484,742 | 615,126 | 9.2 | 193.5 | -63.1 | 26.9 |
| Sihanouk Int'l Airport (KOS) | 666,723 | 16,756 | 15,754 | 29,228 | 0.4 | -6.0 | -95.6 | 85.5 |
| **Land and Waterways** | **2,206,597** | **1,485,023** | **3,587,000** | **4,303,188** | **64.2** | **141.5** | **95.0** | **20.0** |
| Land | 2,049,748 | 1,467,157 | 3,520,730 | 4,218,811 | 63.0 | 140.0 | 105.8 | 19.8 |
| Waterways | 156,849 | 17,866 | 66,270 | 84,377 | 1.3 | 270.9 | -46.2 | 27.3 |
| **Total** | **6,610,592** | **2,276,626** | **5,453,231** | **6,700,125** | **100.0** | **139.5** | **1.4** | **22.9** |

2. Top ten markets arrivals in January - December 2024




| | Thailand | Vietnam | China (RPC) | Lao PDR | U.S.A | Korea (ROK) | Indonesia | France | U.K | Japan |
|---|---|---|---|---|---|---|---|---|---|---|
| 2024 | 2,146,674 | 1,340,587 | 848,952 | 334,448 | 214,529 | 192,305 | 166,795 | 131,738 | 115,148 | 112,718 |
| 2023 | 1,820,460 | 1,019,812 | 547,798 | 372,285 | 184,870 | 170,171 | 127,178 | 106,625 | 96,973 | 86,411 |
| Share (%) | 32.0 | 20.0 | 12.7 | 5.0 | 3.2 | 2.9 | 2.5 | 2.0 | 1.7 | 1.7 |
| Change (%) | 17.9 | 31.5 | 55.0 | -10.2 | 16.0 | 13.0 | 31.2 | 23.6 | 18.7 | 30.4 |

### II. OUTBOUND TOURISM

Outbound tourism in January - December 2024

| | Outbound tourism | | | | Change (%) | | |
|---|---|---|---|---|---|---|---|
| | 2019 | 2022 | 2023 | 2024 | 23/22 | 24*/19 | 2024*/23 |
| Cambodia Outbound Tourists | 2,038,284 | 970,292 | 1,819,504 | 1,845,462 | 87.5 | -9.5 | 1.4 |
| International Tourists Departure | 6,222,834 | 2,082,792 | 5,254,619 | 6,379,772 | 152.3 | 2.5 | 21.4 |

### III. INTERNAL TOURISM

Domestic and foreign visitors' arrivals to the regions in January - December 2024

| | Jan - Dec 2023 | | Jan - Dec 2024 | | Change (%) 2024*/23 | |
|---|---|---|---|---|---|---|
| | KHM | FOR | KHM | FOR | KHM | FOR |
| Phnom Penh | 6,587,351 | 1,211,676 | 9,086,884 | 2,268,253 | 37.9 | 87.2 |
| Siem Reap Angkor | 1,731,445 | 798,069 | 2,202,150 | 1,023,688 | 27.2 | 28.3 |
| Coastal Zone | 8,254,182 | 424,794 | 8,800,773 | 467,576 | 6.6 | 10.1 |
| Preah Sihanouk | 4,846,200 | 315,996 | 4,334,635 | 318,491 | -10.6 | 0.8 |
| Eco-tourism Zone | 549,927 | 27,119 | 629,243 | 40,221 | 14.4 | 48.3 |
| Others | 1,620,468 | 122,358 | 1,800,738 | 186,317 | 11.1 | 52.3 |
| **Total** | **18,743,373** | **2,584,016** | **22,519,788** | **3,986,055** | **20.1** | **54.3** |

**Note:**

KHM: Cambodia visitors

FOR: Foreign visitors

*Source: Tourism Statistics Department, MOT.*

## International Tourist Arrivals to Cambodia by Country of Residence in January - December 2024

*(by all means of transportation)*

| Regions / Country of Residence | 2023 | 2024 Purposes of Visit: Holiday | Business | Others | Total | Female | Share 2024* (%) | Change 2024*/23 (%) |
|---|---|---|---|---|---|---|---|---|
| **Grand Total** | **5,453,231** | **5,166,093** | **1,393,198** | **140,834** | **6,700,125** | **2,957,889** | **100.0** | **22.9** |
| **Asia and the Pacific** | **4,628,294** | **4,361,675** | **1,323,085** | **45,111** | **5,729,871** | **2,521,638** | **85.5** | **23.8** |
| **ASEAN (Southeast Asia)** | **3,549,025** | **3,660,630** | **568,688** | **6,313** | **4,235,631** | **2,070,376** | **63.2** | **19.3** |
| Brunei Darussalam | 545 | 465 | 76 | 0 | 541 | 247 | 0.0 | -0.7 |
| Indonesia | 127,178 | 51,585 | 114,928 | 282 | 166,795 | 49,884 | 2.5 | 31.2 |
| Lao PDR | 372,285 | 328,231 | 6,142 | 75 | 334,448 | 184,227 | 5.0 | -10.2 |
| Malaysia | 87,825 | 59,714 | 33,100 | 1,446 | 94,260 | 23,852 | 1.4 | 7.3 |
| Myanmar | 14,390 | 22,486 | 14,429 | 61 | 36,976 | 18,812 | 0.6 | 157.0 |
| Philippines | 62,268 | 52,990 | 16,029 | 123 | 69,142 | 41,176 | 1.0 | 11.0 |
| Singapore | 43,879 | 39,417 | 5,899 | 579 | 45,895 | 14,367 | 0.7 | 4.6 |
| Thailand | 1,820,460 | 2,070,183 | 73,659 | 2,832 | 2,146,674 | 1,038,252 | 32.0 | 17.9 |
| Timor Leste | 383 | 198 | 115 | 0 | 313 | 98 | 20.0 | -18.3 |
| Vietnam | 1,019,812 | 1,035,361 | 304,311 | 915 | 1,340,587 | 699,461 | 20.0 | 31.5 |
| **Northeast Asia** | **869,881** | **529,249** | **697,181** | **13,435** | **1,239,865** | **368,660** | **18.5** | **42.5** |
| China | 547,798 | 261,652 | 584,138 | 3,162 | 848,952 | 231,587 | 12.7 | 55.0 |
| Hong Kong (China) | 98 | 157 | 14 | 0 | 171 | 60 | 0.0 | 74.5 |
| Japan | 86,411 | 84,833 | 26,732 | 1,153 | 112,718 | 39,164 | 1.7 | 30.4 |
| Korea (ROK) | 170,171 | 147,958 | 38,522 | 5,825 | 192,305 | 70,404 | 2.9 | 13.0 |
| Macau (China) | 1 | 9 | 2 | 0 | 11 | 2 | 0.0 | 1000.0 |
| Mongolia | 891 | 1,196 | 180 | 3 | 1,379 | 692 | 0.0 | 54.8 |
| Taiwan (China) | 64,511 | 33,444 | 47,593 | 3,292 | 84,329 | 26,751 | 1.3 | 30.7 |
| **Southern Asia** | **104,409** | **81,563** | **48,785** | **72** | **130,420** | **25,847** | **1.9** | **24.9** |
| Afghanistan | 88 | 446 | 54 | 1 | 501 | 157 | 0.0 | 469.3 |
| Bangladesh | 21,053 | 6,434 | 10,722 | 11 | 17,167 | 1,082 | 0.3 | -18.5 |
| Bhutan | 170 | 184 | 60 | 2 | 246 | 115 | 0.0 | 44.7 |
| India | 68,836 | 58,743 | 18,850 | 39 | 77,632 | 20,526 | 1.2 | 12.8 |
| Iran | 1,054 | 1,206 | 194 | 0 | 1,400 | 377 | 0.0 | 32.8 |
| Maldives | 257 | 275 | 44 | 1 | 320 | 99 | 0.0 | 24.5 |
| Nepal | 2,940 | 2,863 | 3,533 | 8 | 6,404 | 1,139 | 0.1 | 117.8 |
| Pakistan | 6,570 | 8,974 | 13,085 | 6 | 22,065 | 1,296 | 0.3 | 235.8 |
| Srilanka | 3,441 | 2,438 | 2,243 | 4 | 4,685 | 1,056 | 0.1 | 36.2 |
| **Oceania** | **103,871** | **89,705** | **8,085** | **25,287** | **123,077** | **56,583** | **1.8** | **18.5** |
| Australia | 87,207 | 77,188 | 6,978 | 20,323 | 104,489 | 47,863 | 1.6 | 19.8 |
| Fiji | 218 | 193 | 111 | 2 | 306 | 115 | 0.0 | 40.4 |
| New Zealand | 16,446 | 12,324 | 996 | 4,962 | 18,282 | 8,605 | 0.3 | 11.2 |
| Other Asia & the Pacific | 1,108 | 528 | 346 | 4 | 878 | 172 | 0.0 | -20.8 |
| **Europe** | **562,479** | **588,503** | **44,875** | **29,981** | **663,359** | **295,134** | **9.9** | **17.9** |
| **Northern Europe** | **130,741** | **142,584** | **10,783** | **1,475** | **154,842** | **66,165** | **2.3** | **18.4** |
| Denmark | 7,673 | 8,671 | 488 | 94 | 9,253 | 4,165 | 0.1 | 20.6 |
| Finland | 3,187 | 3,276 | 282 | 94 | 3,652 | 1,237 | 0.1 | 14.6 |
| Iceland | 632 | 607 | 38 | 0 | 645 | 280 | 0.0 | 2.1 |
| Ireland | 9,338 | 9,845 | 662 | 55 | 10,562 | 4,643 | 0.2 | 13.1 |
| Norway | 5,590 | 6,283 | 349 | 219 | 6,851 | 2,889 | 0.1 | 22.6 |
| Sweden | 7,348 | 7,737 | 707 | 287 | 8,731 | 3,379 | 0.1 | 18.8 |
| United Kingdom | 96,973 | 106,165 | 8,257 | 726 | 115,148 | 49,572 | 1.7 | 18.7 |
| **Western Europe** | **222,764** | **223,142** | **19,648** | **27,975** | **270,765** | **120,316** | **4.0** | **21.5** |
| Austria | 6,615 | 8,152 | 325 | 413 | 8,890 | 3,978 | 0.1 | 34.4 |
| Belgium | 11,750 | 12,655 | 975 | 699 | 14,329 | 6,339 | 0.2 | 21.9 |
| France | 106,625 | 96,213 | 11,548 | 23,977 | 131,738 | 60,100 | 2.0 | 23.6 |
| Germany | 63,034 | 69,522 | 4,170 | 1,169 | 74,861 | 32,449 | 1.1 | 18.8 |
| Luxembourg | 518 | 627 | 15 | 7 | 649 | 265 | 0.0 | 25.3 |
| Monaco | 14 | 32 | 0 | 0 | 32 | 18 | 0.0 | 128.6 |
| Netherlands | 19,842 | 21,141 | 1,477 | 498 | 23,116 | 9,793 | 0.3 | 16.5 |
| Switzerland | 14,366 | 14,800 | 1,138 | 1,212 | 17,150 | 7,374 | 0.3 | 19.4 |
